# គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ ដំណាក់កាលទី ៣

# ព្រះរាជាណាចក្រកម្ពុជា:
# ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF)









កុម្ភៈ ២០១៤

# មាតិកា

I. សេចក្តីផ្តើម....................................................................................................................៤

II. ការពិពណ៌នាអំពីគម្រោង.......................................................................................................៨

III. ក្របខ័ណ្ឌគោលនយោបាយ គតិយុត្តិ និងរដ្ឋបាល..................................................................១៣

IV. ទិន្នន័យមូលដ្ឋាន ................................................................................................................ ២២

V. ឥទ្ធិពលផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គមរបស់គម្រោង ....................................................៣៤

VI. ដំណើរការនៃក្របខ័ណ្ឌការគ្រប់គ្រងបរិស្ថាន និងសង្គម...........................................................៤២

VII. ការផ្សព្វផ្សាយព័ត៌មាន និងការប្រឹក្សាជាសាធារណៈ.................................................................. ៤៩

VIII. ការបែងចែកទំនួលខុសត្រូវទៅតាមស្ថាប័ន...................................................................................៥២

ឧបសម្ព័ន្ធ ១. បញ្ជីវាយតម្លៃបរិស្ថាន........................................................................................ ៥៩

ឧបសម្ព័ន្ធ ២. ផែនការគ្រប់គ្រងបរិស្ថានសម្រាប់អនុគម្រោងភ្ជាស់កូនត្រី............................................ ៦៥

ឧបសម្ព័ន្ធ ៣. ការអនុវត្តបច្ចេកទេសសាងសង់ត្រឹមត្រូវ.................................................................៦៧

ឧបសម្ព័ន្ធ ៤. ក្រមបរិស្ថានសម្រាប់អនុវត្ត(ECOP) .......................................................................... ៧០

ឧបសម្ព័ន្ធ ៥: របាយការណ៍ និងការរំលេចពីលទ្ធផលនៃការផ្សព្វផ្សាយជាសាធារណៈនៃការពិភាក្សាក្រុមទៅលើគោលនយោបាយសុវត្ថិភាពក្នុងខេត្តស្ទឹងត្រែង និងខេត្តក្រចេះ (១២-១៨ កក្កដា ២០១០)..........................៨២

ឧបសម្ព័ន្ធ ៦: ការពិនិត្យឡើងវិញទៅលើសុវត្ថិភាពបរិស្ថាន និងសង្គម -សមាសភាគទី ១ និងសិក្ខាសាលាណែនាំថ្នាក់ជាតិអំពីគំរូគ្រប់គ្រងអាងទន្លេសម្រាប់តំបន់ព្រែកទាំង៤ *(៤ P)* និង ទន្លេ៣ (៣ *S)* - សមាសភាគទី ២..........១០៣

## តារាងរូបភាព

រូបភាព ១: ខេត្តគោលដៅរបស់គម្រោង ........ ៨
រូបភាព ២: តំបន់អាងរងទន្លេ៣ និង ព្រែកទាំង៤........ ៩
រូបភាព ៣: សហគមន៍នេសាទក្នុងខេត្តក្រចេះ........ ២៤
រូបភាព ៤: ព្រំដែនឬទីតាំងនៃតំបន់រ៉ាំសារក្នុងខេត្តស្ទឹងត្រែង........ ២៧
រូបភាព ៥: សហគមន៍នេសាទក្នុងខេត្តស្ទឹងត្រែង........ ២៨
រូបភាព ៦: ទីតាំងស្ថានីយ៍ភ្ញាស់កូនត្រីក្នុងខេត្តស្ទឹងត្រែង........ ៣៨
រូបភាព ៧: តារាងលំហូរនៃដំណើរការត្រួតពិនិត្យ........ ៤៨

## បញ្ជីរាយនាមតារាង

តារាង ១: សង្ខេបកម្មវិធី M-IWRM (ស៊េរីដំណាក់កាលទី៤ នៃគម្រោង)........ ៦
តារាង ២: ឈ្មោះភូមិនៅក្នុងតំបន់រ៉ាំសារ........ ២៧
តារាង ៣: គុណភាពទឹកតាមស្ថានីយ៍ត្រួតពិនិត្យនៅតំបន់សេកុង សេសាន និងស្រែពក........ ៣២
តារាង ៤: បញ្ហាសុវត្ថិភាព និងវិធានការណ៍ត្រូវអនុវត្ត........ ៤៥
តារាង ៥: ទំនួលខុសត្រូវសម្រាប់សុវត្ថិភាពបរិស្ថាន........ ៥៣

# អក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| BP | នីតិវិធីធនាគារ |
| CMU | អង្គភាពគ្រប់គ្រងសមាសភាគ |
| CNMC | គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា |
| ECOP | កូដបរិស្ថានសម្រាប់អនុវត្ត |
| EA / EIA | ការវាយតម្លៃបរិស្ថាន និងការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន |
| EMP | ផែនការគ្រប់គ្រងបរិស្ថាន |
| ESMF | ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម |
| FiA | រដ្ឋបាលជលផល |
| IEE | ការពិនិត្យផ្ទៃកបរិស្ថានដំបូង |
| IESE | ការពិនិត្យផ្ទៃកបរិស្ថាន និងសង្គមដំបូង |
| IPPF | ក្របខណ្ឌផែនការសម្រាប់ជនជាតិដើមភាគតិច |
| IPDP | ផែនការអភិវឌ្ឍសម្រាប់ជនជាតិដើមភាគតិច |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| M-IWRM 3 | គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ ដំណាក់កាលទី ៣ |
| MOE | ក្រសួងបរិស្ថាន |
| MOWRAM | ក្រសួងធនធានទឹក និងឧតុនិយម |
| MRC | គណៈកម្មការទន្លេមេគង្គ |
| NGOs | អង្គការមិនមែនរដ្ឋាភិបាល |
| OP | គោលនយោបាយប្រតិបត្តិ |
| PDOWRAM | មន្ទីរធនធានទឹក និងឧតុនិយមខេត្ត |
| RAP | ផែនការសកម្មភាពក្នុងការសាងសង់លំនៅស្ថានឡើងវិញ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RPF | ក្របខណ្ឌគោលនយោបាយក្នុងការសាងសង់លំនៅឡើងវិញ |
| WB | ធនាគារពិភពលោក |
| WWF | មូលនិធិសត្វព្រៃពិភពលោក |

# ជំពូកទី ១. សេចក្តីផ្តើម

ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមសម្រាប់ប្រទេសកម្ពុជា ត្រូវបានរៀបចំឡើង ដោយផ្អែកលើលទ្ធផលដែលកើតចេញពីការពិនិត្យផ្នែកបរិស្ថាននិងសង្គមដំបូង (IESE)ដែលត្រូវ បានបង្កើតឡើងសម្រាប់គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គតំណាក់កាលទី ៣ (M-IWRM-3)។ ក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម (ESMF) ត្រូវបានប្រើប្រាស់ដើម្បីពិនិត្យទៅលើបញ្ហាបរិស្ថាន និងសង្គម និងផលប៉ះពាល់នានាដែលជាប់ពាក់ព័ន្ធ នៅពេលដែលគម្រោងនេះ អនុវត្តនូវស៊េរីនៃសកម្មភាពជាច្រើន និងអនុគម្រោងនានា ដែលមិនទាន់ធ្វើការកំណត់បានច្បាស់លាស់ ហើយកន្លែងអនុវត្តពួកវាក៏មិនទាន់បានដឹងនៅឡើយ នៅពេលធ្វើការវាយតម្លៃទៅលើគម្រោងនេះ។ ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) ដាក់ចេញនូវគោលការណ៍ បញ្ញាត្តិ គោលការណ៍ការណែនាំ និងនីតិវិធី ដើម្បីធ្វើការវាយតម្លៃផលប៉ះពាល់របស់គម្រោងទៅលើផ្នែកបរិស្ថាន និងសង្គម។ វាក៏មានវិធានការ និងផែនការផ្សេងៗទៀតផងដែរ ដើម្បីកាត់បន្ថយ និង/ឬ សម្រាលចំពោះផលប៉ះពាល់អវិជ្ជមាន និងលើកកម្ពស់នូវអត្ថប្រយោជន៍នានា ការផ្តល់នសម្រាប់ធ្វើការប៉ាន់ប្រមាណ និងកំណត់ថវិកាចំណាយទៅលើវិធានការណ៍ទាំងអស់នោះ និងព័ត៌មានរបស់ភ្នាក់ងារដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងផលប៉ះពាល់លើគម្រោង និងការអនុវត្តវិធានការណ៍ដែលបានដាក់ចេញ។

គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គតំណាក់កាលទី ៣ (M-IWRMP-3) គឺជាតំណាក់កាលទី ៣ នៃគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ ដែលជាស៊េរីនៃគម្រោង (SOP) គាំទ្រដល់ប្រទេសឡាវ វៀតណាម កម្ពុជា និងគណៈកម្មការទន្លេមេគង្គ។ គោលបំណងសំខាន់របស់គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ (M-IWRMP) គឺដើម្បីធ្វើការគាំទ្រការអនុវត្តគម្រោងគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) នៅក្នុងអាងទន្លេមេគង្គភាគខាងក្រោមក្នុងកម្រិតថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**តំណាក់កាលនានារបស់គម្រោង M-IWRMP:** រហូតមកដល់ពេលនេះ គម្រោងនេះមាន ៤ តំណាក់កាលគឺ÷ (ក) គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គតំណាក់កាលទី ១ (M-IWRM ១) សម្រាប់គណៈកម្មការទន្លេមេគង្គ MRC និងប្រទេសឡាវ ដែលត្រូវបានអនុម័តក្នុងខែមីនា ឆ្នាំ ២០១៣ ហើយស្ថិតក្រោមការអនុវត្ត (២០១២-២០១៧) (ខ) គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គតំណាក់ទី ២ (M-IWRM ២) សម្រាប់ប្រទេសវៀតណាម ដែលត្រូវបានអនុម័តក្នុងខែ វិច្ឆិកា ឆ្នាំ ២០១៣ (២០១៣-២០១៨) (គ) គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គតំណាក់កាលទី ៣ (M-IWRM ៣)

សម្រាប់ប្រទេសកម្ពុជា ដែលកំណត់ក្នុងផែនការ ២០១៤-២០១៩ ដែលជាប្រធានបទក្នុងឯកសារក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមមួយនេះ និង (ឃ) គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ តំណាក់កាលទី ៤ (M-IWRMP៤) សម្រាប់គណៈកម្មការទន្លេមេគង្គ MRC (កំណត់ក្នុងផែនការ ២០១៦-២០២២)។ តារាងទី ១ខាងក្រោម បង្ហាញនូវសេចក្តីសង្ខេបសំខាន់ៗនៃកម្មវិធីទាំងអស់នេះ។ ការរៀបចំ ទាំងនេះកើតចេញពីភាពខុសៗគ្នានៃកម្រិតសមត្ថភាពរបស់ស្ថាប័ន និងការគ្រប់គ្រងសម្រាប់ដំណើរការ របស់ស្ថាប័នអភិវឌ្ឍន៍អន្តរជាតិនៅក្នុងប្រទេសនីមួយៗ។

គម្រោងដែលបានដាក់ចេញនេះ (ក៏ដូចជា ESMF ផងដែរ) បានផ្តោតជាអាទិភាពទៅលើការគ្រប់គ្រងធនធានជលផល និងអាងទន្លេ ពីព្រោះទាំងនេះជាចំណុចសំខាន់ៗ នៃកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាងរបស់ខ្លួនដែលកំពុងមានភាពរីកចម្រើន ។

**ចំណាយប៉ាន់ប្រមាណសម្រាប់គម្រោង** M-IWRMP: ចំណាយសម្រាប់កម្មវិធីទាំងមូល ដែលគ្របដណ្តប់ទៅលើតំណាក់កាលទាំង៤នេះ ត្រូវបានប៉ាន់ស្មានថាអស់ ៨០.៧៧ លានដុល្លារ ដែលក្នុងនោះការរួមចំណែកពីស្ថាប័នអភិវឌ្ឍន៍អន្តរជាតិ គឺ US$៨០.៨ លានដុល្លារ (ជាមួយនឹងការបំពេញបន្ថែមដោយមូលនិធិរបស់ប្រទេសឡាវ វៀតណាម និងកម្ពុជា)។

**តារាងទី 1: សេចក្តីសង្ខេបពីកម្មវិធី M-IWRMP (ស៊េរី ៤ តំណាក់កាលនៃគម្រោង)**

| ដៃគូ | សកម្មភាព | ចំណាយប៉ាន់ស្មាន (រួមបញ្ចូលទាំងមូលនិធិរបស់ប្រទេសសមភាគី) (គិតជាលានដុល្លា) |
|---|---|---|
| | M-IWRMP ១ (២០១២-២០១៧) | |
| គណៈកម្មការទន្លេមេគង្គ (MRC) | **សមាសភាគទី ១**<br>• ការគាំទ្រពីក្នុងតំបន់សម្រាប់ការពិភាក្សាពីបញ្ហាឆ្លងព្រំដែននៃ IWRM<br>• គាំទ្រក្នុងការបង្កើតវិធីសាស្រ្តសម្រាប់បរិស្ថាន<br>• ការវាយតម្លៃហានិភ័យផលប៉ះពាល់ និងហានិភ័យធម្មជានៅអាងទន្លេមេគង្គ ភាគខាងក្រោម (LMB)។<br>• ការចុះសិក្សាដល់ទីកន្លែង និង<br>• រដ្ឋបាល និងការគ្រប់គ្រងគម្រោង | ៨.០ |
| ប្រទេសឡាវ | **សមាសភាគទី ២**<br>• ការពង្រឹងស្ថាប័នសម្រាប់ MONRE ទាក់ទងទៅនឹងការគ្រប់គ្រងធនធានទឹក និង<br>**សមាសភាគទី ៣**<br>• ការគ្រប់គ្រងព្រៃលិចទឹក (សមាសភាគ ៣-១)<br>• ការគ្រប់គ្រងធនធានជលផល (សមាសភាគ ៣-២) | ១៨.៥ |
| | M-IWRMP ២ (២០១៣-២០១៨) | |
| ប្រទេសវៀតណាម | • ការគាំទ្រសម្រាប់ការពង្រឹងស្ថាប័នដែលគ្រប់គ្រងធនធានទឹកចម្រុះនៅតាមអាងទន្លេសេសាន និងស្រែពកដែលស្ថិតនៅក្នុងផ្នែកនៃប្រទេសវៀតណាម។<br>• ការបង្កើតនូវបណ្តាញត្រួតពិនិត្យធនធានទឹក នៅតាមព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសឡាវនៅមេគង្គក្រោម និងបង្កើតប្រព័ន្ធព័ត៌មាន ធនធានទឹកសម្រាប់តំបន់មេគង្គក្រោមក្នុងប្រទេសវៀតណាម។<br>• ការពង្រឹងនូវបណ្តាញព័ត៌មានជលាឧតុនិយម ប្រព័ន្ធព្យាករណ៍ និងប្រកាសអាសន្នពីទឹកជំនន់ នៅក្នុងតំបន់ខ្ពង់រាបកណ្តាល និងការគ្រប់គ្រងគម្រោង | ៣០.០ |

| | | |
|---|---|---|
| **គម្រោង M-IWRMP ៣ (២០១៤-២០១៩)** | | |
| ប្រទេសកម្ពុជា | • ការគាំទ្រសម្រាប់ធនធានជលផល និងធនធានវារីសាស្ត្រ នៅភាគខាងជើងប្រទេសកម្ពុជា និង។<br>• គាំទ្រដល់ការគ្រប់គ្រងអាងទន្លេនៅក្នុងតំបន់អាងរង សេកុង-សេសាន-ស្រែពក (ស៣)និង អាងព្រែកទាំង៤ (ព៤) និងការសម្របសម្រួលជាមួយប្រទេសពាក់ព័ន្ធ នៅភាគខាងជើងប្រទេសកម្ពុជា ។ | ១៦.៣ |
| គម្រោង M-IWRMP ៤ (២០១៥-២០២០) ក្នុងផែនការ | | |
| នឹងត្រូវធ្វើការកំណត់ដោយ គណៈកម្មការទន្លេមេគង្គ MRC និងប្រទេសពាក់ព័ន្ធ | • ការគាំទ្រទៅលើការប្រមូល និងវិភាគទិន្នន័យក្នុងតំបន់ សម្រាប់ការគ្រប់គ្រងហានិភ័យទឹកជំនន់។<br>• ការគាំទ្រទៅលើចំណេះដឹងមូលដ្ឋានផ្នែកកសិកម្ម និងជលផល និង<br>• ការគាំទ្រទៅលើការគ្រប់គ្រងធនធានទឹក និងការត្រួតពិនិត្យជលធារ និងឧតុនិយម។ | ៨.០ |
| | **សរុប** | ៨០.៨ |

គម្រោង M-IWRMP **៣** ដែលបានដាក់ចេញនេះ នឹងត្រូវអនុវត្តដោយប្រទេសកម្ពុជា។ ក្រសួងធនធានទឹក និងឧតុនិយម (MOWRAM) ជាស្ថាប័នចូលរួមសហការអនុវត្តគម្រោងនេះ ជាមួយ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដែលជាស្ថាប័នអនុវត្តសមាសភាគទី២ និងគ្រប់គ្រងគម្រោង ទាំងមូល។ រដ្ឋបាលជលផល **(FiA)** នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងជាអ្នកទទួលខុសត្រូវលើការអនុវត្តសមាសភាគទី ១។ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា **(CNMC)** នឹងទទួលខុសត្រូវទៅលើការគ្រប់គ្រងគម្រោងទាំងមូល ហើយអនុវត្តសមាសភាគទី ២។ ដូចនេះរដ្ឋបាលជលផល **(FiA)** និងគណៈកម្មាធិការជាតិទន្លេមេគង្គ **(CNMC)** នឹងទទួលខុសត្រូវក្នុងការអនុវត្ត វិធានការណ៍សុវត្ថិភាពនានាដូចដែលបានចែងនៅក្នុងក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គមនេះចំពោះសមាសភាគរៀងគ្នាទាំងអស់នោះ។ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា **(CNMC)** នឹងទទួលខុសត្រូវផងដែរក្នុងការពិនិត្យទៅលើរដ្ឋបាលជលផល (**FiA**) និងធ្វើឱ្យប្រាកដថាពួកគេបានបំពេញតួនាទីរបស់ខ្លួនទៅតាមអ្វីដែលគម្រោងបានដាក់ចេញ។

## ជំពូកទី ២ :ការពិពណ៌នាអំពីគម្រោង

**ទីតាំងភូមិសាស្ត្រ÷** គម្រោង **M-IWRMP ៣** នឹងផ្តោតលើៈ (ក) ជម្រកលូតលាស់ និងពងកូនសំខាន់ៗ របស់ត្រីនៅក្នុងទន្លេសេសាន និងទន្លេមេគង្គ នៅភាគខាងជើងនៃប្រទេសកម្ពុជា ដែលមានប្រវែង១០០ គ.មតាមបណ្តោយទន្លេមេគង្គ ដែលលាតសន្ធឹងពីកោះលង្កា (ជាប់ព្រំដែនឡាវ) មកដល់ខេត្ត ស្ទឹងត្រែង និងក្រចេះ និងភូមិនានាដែលស្ថិតនៅតាមបណ្តោយនៃទន្លេមេគង្គ (ខ) តំបន់អាងរងទន្លេ សេសាន ស្រែពក សេកុង (**ស៣**) របស់ប្រទេសកម្ពុជា រួមជាមួយតំបន់ផ្សេងៗទៀតមានព្រំប្រទល់ជាប់នឹងប្រទេស ឡាវ កម្ពុជា និងវៀតណាម និងដែនទន្លេមួយចំនួន (គ) តំបន់អាងរងនៅភាគខាងកើតខេត្តក្រចេះ ដែលមាន ព្រែកព្រះ ព្រែកគ្រៀង ព្រែកកំពី និងព្រែកតេ (**ព៤**)។ រូបទី ១ ខាងក្រោមបង្ហាញពីខេត្តដែលជាតំបន់គម្រោង និងរូបទី ២ បង្ហាញពីតំបន់អាងរងស៣ និងព៤។




**រូបទី ១: ខេត្តគោលដៅគម្រោង**

(*ប្រភព:* http://www.nationsonline.org )




**រូបទី ២: តំបន់អាងរង ស៣ និង៤ព**

(*ប្រភព:* ដកស្រង់ពី http://ppcrcambodia.files.wordpress.com/2012/11/cnmc-1104-iwrm-cam.pdf)

**មូលហេតុដែលកំណត់នូវសមាសភាគ និងសកម្មភាព ដែលបានដាក់ចេញ÷** ដោយមើលឃើញពីការកើនឡើងយ៉ាងលឿននូវការទាញយកប្រយោជន៍ពីធនធានទឹក ដូចជាគម្រោងវិនិយោគប្រព័ន្ធស្រោចស្រព និងវារីអគ្គិសនីនៅផ្នែកខាងលើនៃប្រទេសកម្ពុជា រាជរដ្ឋាភិបាលកម្ពុជាបានកំណត់នូវបញ្ហាជាអាទិភាពដូចខាងក្រោម សម្រាប់អាងទន្លេមេគង្គភាគខាងក្រោម÷

- ការបង្កើតឱ្យមានសហគ្រប់គ្រងតាមរយៈនេសាទសហគមន៍ ដែលរួមមានការ បង្កើនភាពធន់របស់សហគមន៍នេសាទ ទៅនឹងការប្រែប្រួលដែលអាចកើតមាននៃទិសដៅនៃលំហូរ ទឹក និងផលស្តុកត្រីដែលបណ្តាលមកពីការអភិវឌ្ឍវារីអគ្គិសនីនៅផ្នែកខាងលើ និងការបង្កើតក្របខណ្ឌដើម្បីត្រួតពិនិត្យផលប៉ះពាល់នានា។ តំបន់អាទិភាពគឺស្ថិត នៅប៉ែក ខាង ជើងនៃប្រទេសកម្ពុជា ដែលជាតំបន់សំបូរជម្រកសត្វសំខាន់ៗ (ដែលភាគច្រើនគេហៅថា អន្លង់ ជ្រៅៗ ដែលរាយប៉ាយនៅតាមដងទន្លេមេគង្គប្រវែង ១០០គម ដូចដែលបាន ពណ៌នាខាងលើ) តែមានការគាំទ្រជាប្រព័ន្ធតិចតួចពីដៃគូអភិវឌ្ឍន៍នានាក្នុងការរៀបចំគ្រប់គ្រង ធនធានេជលផលឱ្យបានល្អ។
- ការបង្កើតគោលការណ៍នានានៃការគម្រោងគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) ក្នុងតំបន់អាងសំខាន់ៗដើម្បីធានានូវការអភិវឌ្ឍប្រកបដោយចិរភាព និងទាក់ទាញចំណាប់អារម្មណ៍សាធារណៈ

ជនទៅលើកត្តាសង្គម និងបរិស្ថាន។ ជាពិសេស រាជរដ្ឋាភិបាលកម្ពុជាបានកំណត់នូវ (ក)តំបន់អាងរង ព៤ ដើម្បីឆ្លើយតបទៅនឹងការកើនឡើងយ៉ាងលឿននៃការរុករករ៉ែ និងការកាប់ព្រៃឈើ និងធ្វើឲ្យតំបន់នេះក្លាយជាគំរូសម្រាប់តំបន់ដៃទន្លេផ្សេងៗទៀត និងការកសាងស្តីពីជំនួយបច្ចេកទេសដែលបានគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី (**ADB**) ក្នុងការប្រមូលព័ត៌មានលើធនធានទឹកនៅក្នុងតំបន់អាងរង និងលើកកម្ពស់ការយល់ដឹងរបស់ភាគីដែលពាក់ព័ន្ធទៅលើគម្រោង M-**IWRMP** និង(ខ) តំបន់អាងរង ស៣ ដើម្បីអភិវឌ្ឍការគ្រប់គ្រងរួមជាមួយប្រទេសវៀតណាម ដែលរួមមានទាំងការត្រួតពិនិត្យរួមទៅលើការប្រើប្រាស់ទឹក និងផលប៉ះពាល់របស់វា ការចែករំលែក និងការវិភាគទិន្នន័យ។

ឆ្លើយតបនឹងអាទិភាពរបស់រាជរដ្ឋាភិបាល គម្រោងគម្រោងគ្រប់គ្រងធនធានទឹកចម្រុះដំណាក់កាលទី៣ (**M-IWRMP-3**) លើកឡើងនូវសមាសភាគចំនួន ២ ដូចខាងក្រោម÷

***សមាសភាគទី១÷ ការគាំទ្រការគ្រប់គ្រងធនធានជលផល និងវារីវប្បកម្ម (១០.៨លានដុល្លា)÷*** គោលបំណងរបស់សមាសភាគនេះ គឺដើម្បីបង្កើតការគ្រប់គ្រងដ៏ត្រឹមត្រូវនៅតាមដងទន្លេមេគង្គចាប់ពីខេត្តក្រចេះ ដល់ស្ទឹងត្រែង និងទន្លេសេកុង នៅភាគខាងជើងប្រទេសកម្ពុជា ដែលជាជម្រកធម្មជាតិដ៏សំខាន់ជាច្រើន ដូចជាតំបន់រ៉ាំសារក្នុងខេត្តស្ទឹងត្រែង ឧទ្យានជាតិ តំបន់ការពារសត្វព្រៃ និងព្រៃការពារ (មើលសមាភាគទី៣ខាងក្រោម)។ ការងារនេះ នឹងសម្រេចបានតាមរយៈ (ក) ការបង្កើតសហគមន៍នេសាទ (**CFi**) និង(ខ) ការពង្រឹងសមត្ថភាពវិស័យសាធារណៈក្នុងការតាមដាន និងត្រួតពិនិត្យ ការសិក្សាស្រាវជ្រាវ និងប្រលែងផលស្តុកត្រីចូលក្នុងធម្មជាតិវិញ។ សមាសភាគនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើបទពិសោធន៍នៃអង្គការដែលផ្តល់សេវាផ្នែកសហគមន៍នានា (CSOs) ដែលបម្រើការយ៉ាងសកម្មនៅតាមមូលដ្ឋានក និងចែកចេញជាផ្នែកតូចៗផ្សេងៗទៀត ដូចទៅនឹងសមាសភាគទី ៣-២ របស់គម្រោង M-IWRMP ១ (មើលតារាងទី ១ ខាងលើ)។

(១-១) ជំរុញការអភិវឌ្ឍន៍ សហគមន៍នេសាទ ដែលរួមមាន (ក)ការបង្កើតអង្គភាពគ្រប់គ្រងជលផលដោយផ្អែកលើសហគមន៍នេសាទ (ខ)ការបង្កើតផែនការគ្រប់គ្រងសហគមន៍នេសាទ (គ)ការសាកល្បងពីមធ្យោបាយចិញ្ចឹមជីវិតផ្សេងៗទៀត ដូចជាការចិញ្ចឹមសត្វ ការធ្វើវារីវប្បកម្ម និងការដាំដំណាំលក្ខណៈគ្រួសារ (ឃ)ការពង្រឹងសមត្ថភាពអាជ្ញាធរឃុំ សង្កាត់ និង(ង)ការគាំទ្រការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចនៅក្នុងភូមិ ដែលស្ថិតក្នុងសហគមន៍នេសាទ។

(១-២) ការពង្រឹងការគ្រប់គ្រងវិស័យជលផលសាធារណៈ រួមមាន (ក)ការប្រមូលទិន្នន័យផលចាប់ត្រី ការត្រួតពិនិត្យនិងការជំរុញអនុវត្តច្បាប់ (ខ)ការគាំទ្រវារីវប្បកម្ម និងស្តុកប្រភេទត្រីក្នុងស្រុកតាម

រយៈការសាងសង់ស្ថានីយ៍ភ្ញាស់កូនត្រីខ្នាតតូច នៅខេត្តស្ទឹងត្រែង (គ)ការផ្តល់ជំនួយបច្ចេកទេស និងគាំទ្រផ្នែកដឹកជញ្ជូនដល់ការិយាល័យខណ្ឌរដ្ឋបាលជលផល ដែលរួមមានការស្ថាបនាអាគារការិយាល័យតូចមួយ (ឃ)ការសិក្សាសមាសភាគបច្ចេកទេស ដើម្បីវាយតម្លៃពីផលប៉ះពាល់រចនាសម្ព័ន្ធធនធានទឹកទឹកមួយចំនួនទៅលើវិស័យជលផល និង(ង)ការសិក្សាស្រាវជ្រាវលើប្រភេទសំខាន់ៗដែលបានជ្រើសរើស។

(១-៣) រដ្ឋបាល និងការគ្រប់គ្រងសមាសភាគ រួមមាន ការគាំទ្រការផ្នែកភស្តុភា សម្ភារៈការិយាល័យ និងចំណាយប្រតិបត្តិការបន្ថែម។

***សមាសភាគទី២៖ ការគាំទ្រការគ្រប់គ្រងអាងទន្លេនៅភាគខាងជើងប្រទេសកម្ពុជា (៥.៥ លានដុល្លារ)៖*** សមាសភាគនេះ មានគោលបំណង (ក)ជួយរដ្ឋាភិបាលបង្កើននូវការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាពនៅក្នុងតំបន់អាងរង ព៤[1] ដែលគ្របដណ្តប់លើខេត្តក្រចេះ និងមណ្ឌលគិរី និងភាគខាងក្រោមនៃតំបន់ ស៣[2] ដែលគ្របដណ្តប់ខេត្ត ស្ទឹងត្រែង មណ្ឌលគិរី និងរតនគិរី (មើលរូបទី១ និង២) (ខ)ផ្តល់សមត្ថភាពរៀបចំផែនការ និងត្រួតពិនិត្យសម្រាប់ការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាពខ្ពស់។ សកម្មភាពរបស់សមាសភាគនេះត្រូវបានរៀបចំឡើងដើម្បីកសាងទៅលើបទពិសោធស្តីពីការគាំទ្រ IWRM សម្រាប់តំបន់ ស៣ និងការងារជំនួយបច្ចេកទេសនៅតំបន់ ព៤ ដែលធ្លាប់គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ ការងារក្នុងតំបន់ ស៣ ផ្តោតជាបឋមទៅលើសំបន់ ស២ (សេសាន-ស្រែពក) ជាមុនសិន ដែលជាតំបន់រួមគ្នារវាងកម្ពុជា និងវៀតណាម ដែលនឹងរួមចំណែកក្នុងការអភិវឌ្ឍទំនាក់ទំនងទ្វេភាគីជាមួយភាគីវៀតណាមលើកិច្ចសហការគ្រប់គ្រងធនធានទឹក។

សមាសភាគនេះ នឹងផ្តោតលើសកម្មភាពដូចខាងក្រោមសម្រាប់អនុវត្តនៅតំបន់ ស៣ និងព៤៖

- (២-១)ការគាំទ្រការអនុវត្តគម្រោង **M-IWRMP** នៅភាគឦសានប្រទេសកម្ពុជា ដែលគ្របដណ្តប់លើតំបន់ ស៣ និងព៤ ដែលរួមមាន៖ (ក)ការពង្រឹងសមត្ថភាពមន្ទីរគ្រប់គ្រងធនធានទឹក និងឧតុនិយម នៅក្នុងខេត្តគោលដៅចំនួន៤ (ក្រចេះ ស្ទឹងត្រែង មណ្ឌលគិរី និងរតនគិរី) (ខ)ការគាំទ្រ

[1] តំបន់ ព៤នៃប្រទេសកម្ពុជា សំដៅលើតំបន់អាងទន្លេព្រែកព្រះ ព្រែកគ្រៀង ព្រែកកាំពី និងព្រែកតេ។ តំបន់ព៤ ស្ថិតនៅភាគខាងកើតប្រទេសកម្ពុជា ច្រាំងខាងឆ្វេងទន្លេមេគង្គ ដែលគ្របដណ្តប់លើផ្ទៃក្រឡាប្រមាណ ១២ ៤៧២ គម២ និងផ្ទៃដីខេត្តក្រចេះ និងមណ្ឌលគិរី។

[2] តំបន់អាងរងទន្លេសេសាន ស្រែពក និងសេកុង (ស៣) ស្ថិតនៅប៉ែកអាគ្នេយ៍អាងទន្លេមេគង្គ និងមានផ្ទៃរងទឹកភ្លៀងប្រមាណ ៧៨ ៦៥០គម២។ តំបន់ ស៣ លាតសន្ធឹងលើផ្ទៃដីប្រទេសកម្ពុជា ៣៣% ឡាវ ២៩% និងវៀតណាម ៣៨%។

ការរៀបចំបែប បទបច្ចេកទេស ស្ថាប័ន និងច្បាប់ សម្រាប់ការគ្រប់គ្រងតំបន់អាងទន្លេនៃគម្រោង M-IWRMP (គ) ការធ្វើផែនការគ្រប់គ្រងធនធានទឹក (ការធ្វើបច្ចុប្បន្នភាពព័ត៌មាន និងផែនការតំបន់អាងទន្លេ) ក្នុងតំបន់អាងរង ស៣ និងព៤ (ឃ) ការសិក្សាបច្ចេកទេសធនធានទឹក (ការគ្រប់គ្រងសារធាតុកករ គុណភាពទឹក) និង(ង)ការផ្សារភ្ជាប់សហគមន៍ និងអាជ្ញាធរមូលដ្ឋានក្នុងការគ្រប់គ្រងធនធានទឹក (ឧ.បង្កើនការយល់ដឹងលើ ការគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយធម្មជាតិ (DRM) ការចូលរួមត្រួតពិនិត្យគុណភាពទឹក និងសកម្មភាពសាកល្បង)។

- (២-២) ការគាំទ្រការត្រួតពិនិត្យធនធានទឹក ការគ្រប់គ្រងព័ត៌មាន និងកិច្ចពិភាក្សាពីបញ្ហាព្រំដែនរួមដែលរួមមាន (ក)ការពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពការរៀបចំប្រព័ន្ធព័ត៌មានថ្នាក់ជាតិស្ដីពីការគ្រប់គ្រងធនធានទឹក (ខ)ការរៀបចំទិន្នន័យរួមគ្នាសម្រាប់នាយកដ្ឋានជលសាស្ត្រ និងការងារទន្លេ និងនាយកដ្ឋានឧតុនិយមសម្រាប់ការគ្រប់គ្រងធនធានទឹកនៅក្នុងតំបន់ ស៣ និងព៤ និង(គ)ការពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានជលឧតុនិយម (រួមទាំងការស្ថាបនា និងទំនើបកម្មស្ថានីយ៍ឧតុនិយមជលសាស្ត្រនៅតំបន់ព៤ និងស៣) និង(ឃ)ការគាំទ្រកម្មវិធីវិនិយោគសម្រាប់ការចែករម្លែកព័ត៌មានឆ្លងព្រំដែន ដែលនឹងត្រូវកំណត់ក្រោមកិច្ចចរចារឆ្លងដែន ទៅតាម APL-១ សមាសភាគ ១-១។
- (២-៣) ការគ្រប់គ្រងគម្រោង និងសមាសភាគរួមមានការគាំទ្រផ្នែកភស្តុភា សម្ភារៈការិយាល័យ និងចំណាយប្រតិបត្តិការបន្ថែម ការត្រួតពិនិត្យ និងវាយតម្លៃជារួម ការគ្រប់គ្រងហិរញ្ញវត្ថុ និងប្រព័ន្ធសុវត្ថិភាព។

# ជំពូកទី ៣ ក្របខណ្ឌគោលនយោបាយ គតិយុត្តិ និងរដ្ឋបាល

ការអនុវត្តគម្រោង នឹងធ្វើឡើងស្របទៅតាមច្បាប់ជាតិ និងគោលនយោបាយសុវត្ថិភាពនានារបស់ធនាគារពិភពលោកដែលពាក់ព័ន្ធ។

## ៣.១. ច្បាប់ជាតិ និងបទបញ្ញា

ច្បាប់ និងបទបញ្ញាខាងក្រោម ត្រូវអនុវត្តចំពោះគម្រោង÷

**១.*ក* ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ** (រដ្ឋសភាអនុម័ត ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៦)។ ច្បាប់នេះមានគោលដៅ÷

- ការពារ លើកកម្ពស់គុណភាពបរិស្ថាន និងសុខភាពពលរដ្ឋដោយធ្វើការទប់ស្កាត់ ការកាត់បន្ថយ និងការត្រួតពិនិត្យការបំពុល។
- វាយតម្លៃហេតុប៉ះពាល់បរិស្ថាន មុននឹងចេញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ចំពោះរាល់គម្រោងដែលបានស្នើឡើង។
- ធានាឲ្យមានការអភិរក្ស ការអភិវឌ្ឍ ការគ្រប់គ្រង និងការប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរនូវធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា
- លើកទឹកចិត្ត និងផ្តល់លទ្ធភាពឲ្យសាធារណជនចូលរួមក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។
- បង្ក្រាបអំពើទាំងឡាយណាដែលធ្វើឲ្យប៉ះពាល់ដល់បរិស្ថាន។

**ជាពិសេស មាត្រាខាងក្រោមត្រូវអនុវត្ត÷**

- មាត្រា ៦ និងមាត្រា ៧ ដែលចែងពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- មាត្រា ៨ ដែលចែងអំពីការអភិរក្សធនធានធម្មជាតិ និង
- មាត្រា ១៤ និងមាត្រា ១៥ ដែលចែងពីការត្រួតពិនិត្យ កំណត់ត្រា និងអធិការកិច្ចនៅតាមទីតាំងអភិវឌ្ឍធនធានធម្មជាតិ។

**១.*ខ* ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌** (រដ្ឋសភាអនុម័ត ថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០០៦) ច្បាប់នេះមានគោលដៅ÷ ថែរក្សា ការពារបេតិកភណ្ឌវប្បធម៌ជាតិ និងសម្បត្តិវប្បធម៌ទូទៅ ប្រឆាំងនឹងការបំផ្លិចបំផ្លាញ ការប្រែក្លាយ ការប្តូររូបរាង ការជីកុរករក ការផ្ទេរកម្មសិទ្ធិ ការនាំចេញ និងការនាំចូល

ដោយខុសច្បាប់។ បេតិកភណ្ឌវប្បធម៌ជាតិ គឺជាសម្បត្តិវប្បធម៌ដែលត្រូវបានបង្កើតឡើង ឬក៏បានឃើញនៅក្នុងទឹកដីនៃមាតុភូមិ(មាត្រា ២)។ មាត្រាផ្សេងៗទៀត ត្រូវអនុវត្តក្នុងគម្រោងនេះមាន មាត្រា៣ (ចែងអំពីច្បាប់នេះ អនុវត្តទៅលើសម្បត្តិវប្បធម៌ ជាចលនៈ និងអចលនៈទោះជាកម្មសិទ្ធិសាធារណៈក្តី ឬឯកជនក្តី មាត្រា ៦ (ចែងពីរមណីយដ្ឋានដែលត្រូវការពារ) មាត្រា ៣៨ និង៣៨ (ចែងពីការប្រទះឃើញដោយចៃដន្យ) និងមាត្រា ៤០ (ចែងពីសិទ្ធិអំណាចក្នុងការជីករុករក)។

**១.គ ច្បាប់ជលផល (អនុម័ត ៣០ មីនា ២០០៦)**÷ដូចមានចែងក្នុងមាត្រា១ និង២ ច្បាប់នេះមានគោលបំណង÷

- ធានានូវការគ្រប់គ្រងជលផល និងធនធានជលផល ជំរុញកិច្ចអភិវឌ្ឍវារីវប្បកម្ម ការគ្រប់គ្រងផលិតកម្ម និងការកែច្នៃ លើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋាន ដើម្បីបម្រើផលប្រយោជន៍សង្គម សេដ្ឋកិច្ចនិងបរិស្ថាន រួមទាំងការអភិរក្សជីវៈចម្រុះ និងមរតកវប្បធម៌ធម្មជាតិ ប្រកបដោយនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- និងធានានូវសិទ្ធប្រើប្រាស់ធនធានជលផល ជាប្រពៃណីរបស់សហគមន៍មូលដ្ឋាន

ច្បាប់នេះមានវិសាលភាពអនុវត្តលើជលផលទាំងអស់ ទាំងប្រភេទជលផលដែលកើតឡើងដោយធម្មជាតិ ទាំងជលផលកែច្នៃ និងទវារីវប្បកម្ម។ ច្បាប់នេះជាឯកសារគតិយុត្តិគន្លឹះសម្រាប់សមាសភាគទី ១។ មាត្រា ៤ (ចែងពីធនធានជលផល) និងមាត្រា ៦២ (ចែងពីកន្លែងនេសាទរបស់សហគមន៍) ត្រូវបានយកទៅអនុវត្ត។

នៅថ្ងៃទី ១២ សីហា ឆ្នាំ ២០០៩ រាជរដ្ឋាភិបាល បានចុះហត្ថលេខាលើអនុក្រឹត្យ ស្របទៅតាមច្បាប់ស្តីជលផល ដែលកំណត់ប្រភេទវារីសត្វទជិតផុតពូជចំនួន ៥៨ប្រភេទ ដែលរួមមាន ត្រីទឹកសាប ២៩ ប្រភេទថនិកសត្វ និងសត្វល្មូន។ អនុក្រឹត្យនេះ ចែងអំពីប្រភេទសត្វទឹកសាប និងសត្វសមុទ្រណាដែលត្រូវហាមឃាត់មិនឲ្យមានការដឹកជញ្ជូន ឬជួញដូរ លុះត្រាតែសត្វទាំងនោះ កំពុងត្រូវបានគេចិញ្ចឹម ឬក៏ការធ្វើអាជីវកម្មទាំងនោះ អនុលោមតាមច្បាប់ជលផលក្នុងស្រុក និងអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វព្រៃជិតផុតពូជ Wild Fauna and Flora (CITES) ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នក្នុងឆ្នាំ ១៩៩៧។ ក្នុងចំណោមប្រភេទសត្វទឹកសាបជិតផុតពូជ មានប្រភេទត្រីទឹកសាប ១៩ ប្រភេទ និងអណ្តើកចំនួន៧ប្រភេទ ព្រមទាំងក្រពើសៀម និងសត្វផ្សោត។ CITES បានចាត់ទុក ៧ ប្រភេទនៃប្រភេទសត្វទឹកសាបទាំង ២៩ ថាត្រូវបានគំរាមកំហែងជាមួយនឹងការជិតផុតពូជដែលក្នុងនោះរួមមានក្រពើ និងត្រីផ្សោត ក៏ដូចជា ប្រភេទ ត្រីត្រីរាជ និងត្រីគល់រាំង។ ប្រភេទសត្វទឹកសាបដែល

រងការគំរាមកំហែងជិតផុតពូជដ៏ទៃទៀត មានត្រីនាគ (formosus Scleropages) និង ត្រីបបែលធ្មេញរណា (microdon Pristis) និងអណ្តើកមួយប្រភេទដែលរស់នៅតំបន់ព្រៃកោងកាង (Batagur baska)។

ប្រភេទសត្វសមុទ្រជិតផុតពូជ បានកំណត់ដោយអនុក្រឹត្យ ដែលរួមមាន ថនិកសត្វសមុទ្រចំនួន ១២ ប្រភេទ ប្រភេទត្រីនិងខ្យងសមុទ្រ ៦ប្រភេទ អណ្តើក៥ប្រភេទ ត្រី ៣ប្រភេទ ក្តាមក្រចកសេះ ២ ប្រភេទ និងក្រពើ ១ប្រភេទ ព្រមទាំងផ្កាថ្ម និងរុក្ខជាតិសមុទ្រ។

**១.ឃ អនុក្រឹត្យទី ២៧ ស្តីពីការត្រួតពិនិត្យការបំពុលទឹក** (អនុម័តថ្ងៃទី៦ខែមេសាឆ្នាំ ១៩៩៩) ។

គោលបំណងនៃអនុក្រឹត្យនេះ គឺដើម្បីទប់ស្កាត់ និងត្រួតពិនិត្យការបំពុលទឹក ដើម្បីការពារសុខភាពមនុស្ស និងអភិរក្សជីវចម្រុះ(មាត្រា១)។ ច្បាប់នេះអនុវត្តលើប្រភពទាំងអស់នៃការបំពុល និងសកម្មភាពដែលបង្កឱ្យមានការបំពុលនៅតាមដែនទឹកសាធារណៈ (មាត្រា ២)។ មាត្រា ១៩ (ការត្រួតពិនិត្យការបំពុលទឹក) បង្ហាញពីកាតព្វកិច្ចរបស់ក្រសួងបរិស្ថាន (MoE) ដែលត្រូវអនុវត្តជាគំរូនៅទីតាំងបញ្ចេញកាកសំណល់រាវពីកន្លែងភ្ញាស់កូនត្រីដែលបានស្នើឡើង។ លើសពីនេះទៀត “ដំណើរការផលិតកម្មជលផល” ត្រូវចាត់ទុកថា ជាប្រភពបំពុលមួយដែលត្រូវបានតម្រូវឱ្យមានការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិនមុនពេលបញ្ចេញ ឬដឹកជញ្ជូនសំណល់រាវចេញ។

**១.ង អនុក្រិត្យទី៣៦ស្តីពីការគ្រប់គ្រងកាកសំណល់រឹង** (អនុម័តថ្ងៃទី ១៧ ខែមេសាឆ្នាំ ១៩៩៩)

បទប្បញ្ញត្តិទូទៅនៃអនុក្រឹត្យនេះគឺដើម្បីធានាឲ្យការគ្រប់គ្រងកាកសំណល់រឹងដោយសុវត្ថិភាពស្របតាមលក្ខណៈបច្ចេកទេស ក្នុងគោលបំណងដើម្បីធានាបាននូវការការពារសុខភាពមនុស្ស និងការអភិរក្សជីវចម្រុះ (មាត្រា១) ។ អនុក្រឹត្យនេះ អនុវត្តរាល់សកម្មភាពទាំងអស់ដែលទាក់ទងនឹងការចោល ការផ្ទុក ការប្រមូល ការកែច្នៃ ការដឹកជញ្ជូន ការចោលសំរាម និងកាកសំណល់ដែលគ្រោះថ្នាក់ (មាត្រា ២)។

**១.ច អនុក្រិត្យទី ៤២ស្តីពីការបំពុលខ្យល់ និងរំខានដោយសម្លេង** (អនុម័តថ្ងៃទី ១០ កក្កដា ២០០០)

បទប្បញ្ញត្តិទូទៅនៃអនុក្រឹត្យនេះគឺដើម្បីការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈ ពីការបំពុលខ្យល់ និងការបំពុលដោយសំលេងរំខានតាមរយៈការត្រួតពិនិត្យ ការទប់ស្កាត់ និងសកម្មភាពបន្ធូរបន្ថយ (មាត្រា១)។ អនុក្រឹត្យនេះត្រូវបានអនុវត្តលើគ្រប់ប្រភពទាំងអស់នៃការបំពុលខ្យល់ និងការរំខានដោយសំលេង ទាំងប្រភពដែលអាចចល័តបាន និងប្រភពដែលមិនអាចចល័តបាន (មាត្រា២)។

**១.ធ. ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក** (អនុម័តថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៧)

គោលបំណងទូទៅនៃច្បាប់នេះ គឺដើម្បីជំរុញការគ្រប់គ្រងប្រកបប្រសិទ្ធិភាព និងមាននិរន្តរភាពនៃធនធានទឹកនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីសម្រេចបានការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងសុខមាលភាពរបស់ប្រជាជន។ ច្បាប់នេះកំណត់÷ (ក) សិទ្ធិនិងកាតព្វកិច្ចនៃអ្នកប្រើប្រាស់ទឹក (ខ) គោលការណ៍ជាមូលដ្ឋាននៃការគ្រប់គ្រងធនធានទឹកនិង (គ) ការចូលរួមរបស់អ្នកប្រើប្រាស់ទឹក និងសមាគមន៍ប្រើប្រាស់ទឹកក្នុងការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃធនធានទឹក។ ច្បាប់នេះ គឺជាក្របខ័ណ្ឌច្បាប់មូលដ្ឋានសំខាន់សម្រាប់សមាសភាគទី ២ នៃគម្រោង។ គម្រោងនេះផ្អែកសំខាន់លើមាត្រា ៤ (មូលដ្ឋាននៃគោលការណ៍ IWRM) មាត្រា ៨, ៩, និង ១០ (ក្រសួងធនធានទឹក និងឧតុនិយម ជាទីភ្នាក់ងារដែលទទួលខុសត្រូវក្នុងការរៀបចំផែនការ និងត្រួតពិនិត្យធនធានទឹក) មាត្រា ៣៤ (ទន្លេអន្តរជាតិ)។ ច្បាប់នេះក៏បានដាក់ចេញបទប្បញ្ញត្តិស្តីពីការបែងចែក ការផ្តល់អាជ្ញាប័ណ្ណ និងដំណោះស្រាយវិវាទលើបញ្ហាទឹក។

**២.គោលនយោបាយសុវត្ថិភាពមួយចំនួនរបស់ធនាគារពិភពលោកដែលត្រូវអនុវត្ត**

នេះ គឺជាគម្រោងប្រភេទ ខ និងឧបករណ៍សម្រាប់អនុវត្តគោលនយោបាយរួមមានក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) ក្របខណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ ( RPF ) និងក្របខណ្ឌផែនការជនជាតិដើមភាគតិច ( IPPF )។

***OP/BP ៤.០១* (ការវាយតំលៃបរិស្ថាន):** គោលនយោបាយសុវត្ថិភាពរបស់ធនាគារពិភពលោកស្តីពីការវាយតំលៃបរិស្ថាន (OP ៤.០១) នឹងត្រូវបានអនុវត្តដោយសារតែសកម្មភាពគម្រោងនេះនឹងទាក់ទងនឹង (ក) ការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗនៅជនបទ (ឧ.ផ្លូវចូលក្នុងភូមិ ស្ពានសម្រាប់ថ្មើជើងជាដើម) និងការសាងសង់ស្ថានីយ៍ភ្ញាស់កូនត្រីខ្នាតតូចនៅខេត្តស្ទឹងត្រែង (ខាងក្រៅតំបន់រ៉ាំសារ- សូមមើលចំនុច V)- ស្ថិតនៅក្រោមសមាសភាគទី ១ និង (ខ) ការសាងសង់ស្ថានីយ៍ត្រួតពិនិត្យជលសាស្រ្ត តាមបណ្តោយទន្លេសេកុង និងសេសាន ស្ថិតក្រោមសមាសភាគទី ២។ ផលប៉ះពាល់រួមនៃគម្រោងដែលបានស្នើឡើង បរិស្ថានមានលក្ខណៈវិជ្ជមានដោយសារគម្រោងនេះមានគោលបំណងកាត់បន្ថយសម្ពាធនៃការនេសាទត្រី និងបង្កើតក្របខណ្ឌសម្រាប់ការគ្រប់គ្រងដ៏ត្រឹមត្រូវនៃធនធានជលផល និងជំរកត្រី។ ផលប៉ះពាល់ពីស្ថានីយ៍ភ្ញាស់កូនត្រីដែលគ្រោងនឹងបង្កើតអាចចាត់ទុកស្ថិតនៅក្នុងកម្រិតដែលអាចគ្រប់គ្រងបាន ។

នៅក្នុងគោលការណ៍ ស្ថានីយ៍ភ្ញាស់កូនត្រីត្រូវបានបង្កើតឡើងដើម្បីកែច្នៃទឹក និងកាត់បន្ថយការបញ្ចេញកាកសំណល់។ ការបញ្ចេញកាកសំណល់ប្រចាំឆ្នាំ ត្រូវគេប៉ាន់ប្រមាណថាមានតិចជាងមួយភាគពីរពាន់នៃលំហូរទន្លេសេកុង (ប៉ាន់ប្រមាណថាមានចំនួន ៩០ ពាន់លានម៉ែត្រគូប ) នៅចំណុចបញ្ចេញកាកសំណល់នេះ។ មុនពេលបង្ហូរហូរចូលទឹកទន្លេ កាកសំណល់ចេញពីសកម្មភាពភ្ញាស់កូនត្រី នឹងឆ្លងកាត់ស្រះចម្រោះសារធាតុផ្សេងៗ ដើម្បីកាត់បន្ថយការបំពុលទន្លេណាមួយដែលអាចកើតមាន។ ផែនការគ្រប់គ្រងបរិស្ថាន (EMP) នឹងត្រូវបានរៀបចំក្នុងអំឡុងពេលអនុវត្តគម្រោង នៅពេលដែលការរៀបចំលំអិតត្រូវបានបង្កើតឡើង និងមុនពេលចាប់ផ្តើមការងារស្ថានីយ៍ភ្ញាស់កូនត្រី។

ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានពីគម្រោងនេះ រួមមានកង្វះដីសម្រាប់ការប្រើប្រាស់ផ្សេងៗទៀត ធូលី សម្លេងរំខាន និងសំណល់ពីការងារខ្នាតតូចផ្សេងៗ។ ទោះជាយ៉ាងណា ផលប៉ះពាល់ទាំងនេះត្រូវបានវាយតម្លៃថាមានទំហំតូច កើតមានតែក្នុងតំបន់គម្រោង និងមានលក្ខណៈបណ្តោះអាសន្នប៉ុន្នោះ។ ផលប៉ះពាល់ទាំងនេះ អាចកាត់បន្ថយបានយ៉ាងស្រួលតាមរយៈការអនុវត្តតាមក្រមបរិស្ថានសម្រាប់ការអនុវត្ត (ECOPs) ។

**OP/BP *៤.០៤* (ជម្រកធម្មជាតិ):** គម្រោងនេះ អនុវត្តទៅតាមគោលនយោបាយប្រតិបត្តិសុវត្ថិភាពរបស់ធនាគារពិភពលោក នៅតាមតំបន់លំនៅស្ថានធម្មជាតិ (OP 4.04) ដោយសារតែសកម្មភាពនៅក្រោមសមាសភាគទី ១ និងទី ២ គ្រោងនឹងអនុវត្តនៅតាមភូមិដែលមានទីតាំងស្ថិតនៅតាមបណ្តោយដងទន្លេមេគង្គនៅភាគខាងជើងប្រទេសកម្ពុជា។ ខណៈពេលដែលការជ្រើសរើសភូមិពិតប្រាកដនឹងត្រូវធ្វើអំឡុងពេលអនុវត្តគម្រោង សមាសភាគមួយនៃតំបន់គម្រោងអាចនឹងត្រូវធ្វើនៅក្នុងតំបន់រ៉ាំសារក្នុងខេត្តស្ទឹងត្រែង។

ផលប៉ះពាល់ជារួមនៃគម្រោងនេះ នឹងមានលក្ខណៈវិជ្ជមាន ដោយសារការវិនិយោគដែលបានស្នើឡើងនេះនឹងអនុញ្ញាតឱ្យយើងអាចប្រមូល និងវិភាគទិន្នន័យជលសាស្ត្រ និងគុណភាពទឹក (ពោលគឺកម្រិតសារធាតុកំបោរ) នៅក្នុងតំបន់អាងរង ព៣ និងស៤ និងបង្កើតឲ្យការគ្រប់គ្រងធនធានជលផលដ៏ល្អប្រសើរតាមភូមិនេសាទដែលបានជ្រើសនៅតាមបណ្តោយដងទន្លេមេគង្គក្នុងខេត្តចំនួនពីរ (ក្រចេះ និងស្ទឹងត្រែង) តាមរយៈការចូលរួមរបស់សហគមន៍។

ខេត្តក្រចេះ និងស្ទឹងត្រែង ស្ថិតនៅក្នុងតំបន់ដ៏សំខាន់សម្រាប់ការគ្រប់គ្រងធនធានជលផលក្នុងទន្លេមេគង្គ ដែលលាតសន្ធឹងប្រវែងប្រមាណ ២០០ គីឡូម៉ែត្រ ពីខេត្តចំប៉ាសាក់ (ភាគខាងត្បូងប្រទេស

ឡាវ) មកខេត្តក្រចេះ។ ផ្នែកនៃទន្លេមេគង្គដែលស្ថិតនៅក្នុងខេត្តគោលដៅទាំងពីរត្រូវបានគេស្គាល់ថាជាជំរកល្អតលាស់សត្វសំខាន់ៗជាច្រើន ដែលហៅថាអន្លង់ទឹកជ្រៅ ។ តំបន់ទាំងនេះ គឺជាជម្រកដ៏សំខាន់ទាំងក្នុងអំឡុងរដូវប្រាំង និងរដូវពងកូន សម្រាប់ប្រភេទសត្វជាច្រើនដែលធ្វើបម្លាស់ទីឆ្លាយឆ្លងកាត់តំបន់នេះ រួមទាំងប្រភេទត្រជិតផុតពូជដូចជាត្រីរាជ និងត្រីគល់រាំង និងថនិកសត្វដូចជាត្រីផ្សោត។ ដូច្នេះ គម្រោងនេះ នឹងរួមចំណែកដល់ការអភិរក្សជីវៈចំរុះ។ តំបន់រ៉ាំសារត្រូវបានកំណត់ឡើងក្នុងឆ្នាំ ២០០៦ នៅក្នុងខេត្តស្ទឹងត្រែង (សូមមើលរូបទី ៤)។ បច្ចុប្បន្នក្រសួងបរិស្ថាន បានកំពុងបញ្ចប់សេចក្តីព្រាងស្តីពីផែនការគ្រប់គ្រងតំបន់រ៉ាំសារ ដោយមានជំនួយពីមូលនិធិព្រៃពិភពលោកសម្រាប់ធម្មជាតិ (អង្គការ WWF) ហើយការបង្កើតឡើងកន្លែងនេសាទសហគមន៍ (CFi) ត្រូវបានកំណត់ថាជាគន្លឹះដ៏សំខាន់សម្រាប់ការគ្រប់គ្រងតំបន់រ៉ាំសា។

ក្នុងសេចក្តីព្រាងស្តីពីផែនការគ្រប់គ្រងតំបន់រ៉ាំសារនាពេលបច្ចុប្បន្ន បានរាប់បញ្ចូលនូវភូមិចំនួន ២១ ហើយសមាសភាគទី១ នៃគម្រោងនឹងគាំទ្រដល់ភូមិទាំងនេះដើម្បីបង្កើត ឬពង្រឹងកន្លែងនេសាទសហគមន៍ (CFis)។

ដើម្បីផ្តល់នូវការលើកទឹកចិត្តដល់ភូមិនេសាទ ក្នុងការជួយពង្រឹងការគោរពច្បាប់នៅតាមតំបន់ការពារដែលបានកំណត់ សមាសភាគទី១គួរផ្តល់ការគាំទ្រផងដែរដល់ការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធជនបទ និងការសាកល្បងពីសកម្មភាពចិញ្ចឹមជីវិតបន្ថែមផ្សេងៗទៀត (ឧទាហរណ៍ ស្រះគ្រួសារសម្រាប់កសិកម្ម) ដើម្បីទ្រទ្រង់ដល់ជីវភាពរស់នៅ និងកាត់បន្ថយការធ្វើនេសាទនៅក្នុងធម្មជាតិ។ សកម្មភាពទាំងនេះត្រូវបានអនុញ្ញាតតាមសេចក្តីព្រាងស្តីពីផែនការគ្រប់គ្រងតំបន់រ៉ាំសារនាពេលបច្ចុប្បន្ន ។ ការវិនិយោគទាំងនេះនឹងមិនបណ្តាលឱ្យមានផលប៉ះពាល់ធំដុំណាមួយឡើយ ដោយសារតែវាមានទ្រង់ទ្រាយតូច និងមានភាពសាមញ្ញ។ ជាពិសេស ការសាកល្បងពីរបរចិញ្ចឹមជីវិតមួយចំនួន (ភាគច្រើនទៅលើការធ្វើវារីវប្បកម្ម ការចិញ្ចឹមសត្វ និងសួនដំណាំគ្រួសារ)ដែលមានលក្ខណៈកម្រិតគ្រួសារ និងហេដ្ឋារចនាសម្ព័ន្ធនៅតាមជនបទ ដែលរួមមានការស្តារឡើងវិញនូវស្ពានសម្រាប់ថ្មើរជើង ផ្លូវថ្មើរជើងក្នុងភូមិ សាលារៀន និងមណ្ឌលសុខភាពខ្នាតតូច នឹងមិនបណ្តាលឲ្យប៉ះពាល់ដល់បរិស្ថានជាដុំកំភួនណាមួយទេ។ ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធតំបន់ជនបទទាំងនេះនឹងត្រូវកំណត់ដោយភាគីពាក់ព័ន្ធ និងអនុម័តដោយឃុំនីមួយៗ។ ផលប៉ះពាល់តិចតួច ដែលបណ្តាលមកពីការងារសាងសង់នានានឹងត្រូវកាត់បន្ថយ ឬបំបាត់ចោលតាមរយៈការអនុវត្តនូវបច្ចេកទេសវិស្វកម្មត្រឹមត្រូវ និងកូដបរិស្ថានសម្រាប់ការអនុវត្ត (ECOP)។ សេចក្តីសង្ខេបនៃសេចក្តីព្រាងស្តីពីផែនការគ្រប់គ្រងតំបន់រ៉ាំសារនាពេលបច្ចុប្បន្ន

ត្រូវបានភ្ជាប់ក្នុងឧបសម្ព័ន្ធទី ៧ ដែលរួមមានទាំងឈ្មោះភូមិទាំង ២១ ផងដែរ។ ដើម្បីធានាថាការអនុវត្តគម្រោងនេះអនុលោមទៅតាមផែនការគ្រប់គ្រងតំបន់រំសារ គណៈកម្មាធិការត្រួតពិនិត្យថ្នាក់ជាតិ ដែលនឹងត្រួតពិនិត្យការអនុវត្តគម្រោងនេះនឹងមានតំណាងមកពីក្រសួងបរិស្ថានផងដែរ។

ក្នុងតំបន់អាងរង ពា៣ និងស៤ (គ្របដណ្តប់ ខេត្តក្រចេះ ស្ទឹងត្រែង មណ្ឌលគិរី និងរតនៈគិរី) ការអនុវត្តសមាសភាគទី ២ នឹងជួយពង្រឹងសមត្ថភាពបច្ចេកទេស និងការគ្រប់គ្រងរបស់គណៈកម្មាធិការទន្លេមេគង្គជាតិកម្ពុជា (CNMC) និងក្រសួងធនធានទឹក និងឧតុនិយម (MOWRAM) ឱ្យនាំមុខគេ ក្នុងការគាំទ្រដល់ការអភិវឌ្ឍធនធានទឹកប្រកបដោយចិរភាពនៅក្នុងប្រទេសកម្ពុជា។ ការសាងសង់មានតែមួយគត់គឺការស្ថាបនាស្ថានីយ៍ត្រួតពិនិត្យធនធានទឹកខ្នាតតូចដែលនឹងមិនបង្កផលប៉ះពាល់ធំដុំណាមួយដល់បរិស្ថានទេ។ ដូចករណីខាងលើដែរ ផលប៉ះពាល់តិចតួចណាមួយនឹងត្រូវកាត់បន្ថយ ឬលុបបំបាត់តាមរយៈការអនុវត្តនូវបច្ចេកទេសវិស្វកម្មត្រឹមត្រូវ និងកូដបរិស្ថានសម្រាប់ការអនុវត្តន៍ (ECOP)។

***OP/BP ៧.៥០* ( គម្រោងនៅលើផ្លូវទឹកអន្តរជាតិ ):** ទន្លេមេគង្គ គឺជាផ្លូវទឹកអន្តរជាតិ ហើយគោលនយោបាយប្រតិបត្តិ ៧.៥០ (OP) ត្រូវបានអនុវត្តតាម។ គម្រោងនេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ ដែលមានប្រទេសថៃ វៀតណាម កម្ពុជានិងឡាវ នៅឯកិច្ចប្រជុំក្រុមប្រឹក្សាគណៈកម្មការទន្លេ មេគង្គ នៅក្នុងខែវិច្ឆិកា ឆ្នាំ ២០០៩ ដោយតម្រូវឲ្យមានការជូនដំណឹងដល់រដ្ឋពាក់ព័ន្ធ។ ក្នុងអំឡុងពេលនៃការរៀបចំគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គដំណាក់កាលទី១ (M-IWRM-1) ធនាគារពិភពលោក ក្នុងនាមប្រទេសកម្ពុជា បានជូនដំណឹងដល់ប្រទេសចិន និងប្រទេសមីយ៉ាន់ម៉ា ដែលមិនមែនជាសមាជិកនៃគណៈកម្មការទន្លេមេគង្គអំពីសមាសភាគទី ១ នៃគម្រោង (គាំទ្រការគ្រប់គ្រងវិស័យជលផល និងធនធានទឹក ) ដែលរួមទាំងគម្រោងស្នើសាងសង់ស្ថានីយ៍ភ្ជាស់កូនត្រី នៅថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០១០។ មិនមានការឆ្លើយតបណាមួយត្រូវបានផ្តល់ដោយប្រទេសទាំងពីរឡើយ ដូច្នេះសម្រាប់ គោលបំណងនៃ OP ៧.៥០ ដែលតម្រូវឲ្យមានការជូនដំណឹងដល់ប្រទេសដែលពាក់ព័ន្ធក្នុងទន្លេមេគង្គ គឺរួចរាល់សព្វគ្រប់។ គម្រោងវិនិយោគ ដែលបានស្នើឡើងនៅក្រោមសមាសភាគទី ២ គឺសុទ្ធតែជំនួយបច្ចេកទេសដែលរួមមានការបង្កើតស្ថានីយ៍ត្រួតពិនិត្យឧតុនិយមជលសាស្ត្រ ដែលមានគោលបំណងដើម្បីត្រួតពិនិត្យលើផ្ទៃទឹក និងមិនប៉ះពាល់ដល់លំហូរ ឬបរិមាណទឹកទន្លេឡើយ។ ដូច្នេះគម្រោងនេះ ស្ថិតក្នុងប្រភេទនៃគម្រោងវិនិយោគមានចែងក្នុងកថាខ័ណ្ឌ (ខ )នៃ OP ៧.៥០ ដែលជាករណីលើកលែងមិនបាច់ជូនដំណឹងប្រទេសពាក់ព័ន្ធ។

**OP/BP** *៤.១២* **(ការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត):** គម្រោងនេះ អនុលោមតាមគោលនយោបាយសុវត្ថិភាពរបស់ធនាគារពិភពលោក ( OP ៤.១២ ) ដោយសារតែគម្រោងនេះទាក់ទងនឹងការទិញដីទំហំតូចៗ។ គម្រោងវិនិយោគដែលបានស្នើគឺមានទំហំតូច និងត្រលប់ទៅរកសភាពដើមវិញដោយធម្មជាតិ ប៉ុន្តែគម្រោងនេះ អាចជាប់ទាក់ទងនឹងភាពស្របច្បាប់នៃការប្រើប្រាស់ដីក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចនៅតាមសហគមន៍ លើសពីនេះទៀត ក្នុងការអភិវឌ្ឍផែនការគ្រប់គ្រងសហគមន៍នេសាទ តំបន់អភិរក្សមច្ឆជាតិ អាចនឹងត្រូវបង្កើតឡើងដែលនឹងកាត់បន្ថយសកម្មភាពនេសាទទៅលើធនធានក្នុងអំឡុងពេលមួយចំនួនក្នុងមួយឆ្នាំ។ គោលនយោបាយនេះនឹងត្រូវគ្របដណ្តប់ដោយឯកសារក្របខណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅឡើងវិញ (RPF) ដែលនឹងត្រូវចេញផ្សាយដាច់ដោយឡែកពីគ្នា ។

**OP/BP** *៤.១០* **(ជនជាតិភាគដើម) :** នៅខេត្តស្ទឹងត្រែង និងខេត្តក្រចេះ នៃប្រទេសកម្ពុជាប្រហែល ៨ ភាគរយនៃចំនួនប្រជាជនសរុប ត្រូវបានគេចាត់ទុកជាក្រុមជនជាតិភាគតិចដែលក្នុងនោះមាន ចិន និង/ឬ វៀតណាមមួយចំនួនធំ និងជនជាតិដើមភាគតិចប្រាំពីរក្រុមទៀត:÷ព្នង គួយ មិលខុញ ក្រអុល ស្ទៀង និងទំពួន។ នៅខេត្តមណ្ឌលគិរី និងរតនៈគិរីមានក្រុមជនជាតិភាគតិច ១១ ក្រុមគិតជាភាគរយចន្លោះពី ២៥% ទៅ ៤0% នៃចំនួនប្រជាជនក្នុងខេត្តសរុប ក្នុងក្រុមជនជាតិដែលធំជាងគេគឺព្នង និងទំពួន។ ដូច្នេះ គោលនយោបាយសុវត្ថិភាពរបស់ធនាគារពិភពលោកសម្រាប់ជនជាតិដើមភាគតិច (OP៤.១0) នឹងត្រូវអនុវត្តតាម។ សហគមន៍ជនជាតិដើមភាគតិចដែលចូលរួមនៅក្នុងគម្រោងនេះត្រូវបានរំពឹងថានឹងទទួលបានផលប្រយោជន៍ពីសកម្មភាពវិនិយោគ និងការគាំទ្រជីវភាពរស់នៅ។ គោលនយោបាយនេះ នឹងត្រូវបានគ្របដណ្តប់ដោយឯកសារក្របខណ្ឌស្តីពីការរៀបចំផែនការសម្រាប់ជនជាតិដើមភាគតិច ( IPPF ) ដែលត្រូវបានចេញផ្សាយដោយឡែកពីគ្នា។ ចំផែនការសម្រាប់ជនជាតិដើមភាគតិច (IPPF) រួមជាមួយនឹងក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) និងក្របខណ្ឌផែនការនៃការតាំងលំនៅដ្ឋានឡើងវិញ (RPF) ត្រូវបានបង្ហាញដល់ក្រុមជនជាតិដើមភាគតិច ដែលមានការព្រួយបារម្ភចំពោះគម្រោងនេះ និងបង្ហាញដល់ការិយាល័យនៃមន្ទីរធនធានទឹក និងឧតុនិយមនៃខេត្តគោលដៅទាំង៤របស់គម្រោង។

**ការពិគ្រោះយោបល់ជាសាធារណៈ និងការផ្សព្វផ្សាយពត៌មាន÷** អនុលោមតាមគោលនយោបាយរបស់ធនាគារពិភពលោកស្តីពីសិទ្ធិទទួលព័ត៌មាន និង OP ៤.0១ ( ការវាយតំលៃបរិស្ថាន )។ ម្ចាស់គម្រោងត្រូវផ្តល់សេចក្តីសង្ខេបអំពីគោលបំណងរបស់គម្រោងដែលបានស្នើឡើង ការពិព័រណ៌នាគម្រោងព្រម

ទាំងផលប៉ះពាល់ដែលអាចកើតមាន និងវិធានការកាត់បន្ថយសម្រាប់ក្រុមដែលត្រូវពិគ្រោះយោបល់ មុនពេលពិគ្រោះយោបល់ ដើម្បីធានាថាពួកគេមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យមើលឡើងវិញ និងបញ្ចេញនូវទស្សនៈរបស់ពួកគេក្នុងអំឡុងពេលនៃការពិគ្រោះយោបល់។ ការពិគ្រោះយោបល់ជាសាធារណៈត្រូវបានធ្វើឡើងនៅក្នុងខេត្តគោលដៅ គឺក្រចេះនិងស្ទឹងត្រែង ដោយមានការចូលរួមពីភាគីពាក់ព័ន្ធសំខាន់ក្នុង ឆ្នាំ ២០១០, ២០១១ និង ២០១៣។ មតិយោបល់ និងអនុសាសន៍របស់ភាគីពាក់ព័ន្ធត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការវាយតម្លៃបរិស្ថាន ( EA )។ ឧបករណ៍សុវត្ថិភាពចុងក្រោយ ដូចជាក្របខណ្ឌគោលនយោបាយនៃការតាំងលំនៅដ្ឋានឡើងវិញ (RPF) ក្របខណ្ឌផែនការជនជាតិភាគតិច (IPPF) និងក្របខណ្ឌគ្រប់គ្រងសង្គម និងបរិស្ថាន (ESMF) នឹងត្រូវបាន ផ្សព្វផ្សាយ ជាសាធារណៈតាមរយៈគេហទំព័ររបស់គណៈកម្មាធិការទន្លេមេគង្គជាតិកម្ពុជា (CNMC) និងគេហទំព័រ តាមបណ្តាខេត្តរបស់គម្រោងជាភាសាក្នុងស្រុក (ខ្មែរ) ឯកសារ (hard copies)ត្រូវបានបង្ហាញនៅការិយាល័យតាមឃុំ សង្កាត់ទាំងអស់ដែលស្ថិតក្នុងតំបន់គម្រោងទាំងអស់ ដែលអាចឱ្យភាគីពាក់ព័ន្ធ ជាពិសេសអ្នកទទួលឥទ្ធិពលពីគម្រោងអាចស្វែងរកព័ត៌មានបាន។ ឯកសារ ESMF IPPF និង RPF ជាភាសាអង់គ្លេសនឹងអាចរកបានតាមរយៈ InfoShop របស់ធនាគារ នៅថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១៤។ ផែនការគ្រប់គ្រងបរិស្ថាន (EMP) នេះក៏នឹងត្រូវបង្ហាញឡើងវិញក្នុង Infoshop មុនពេលអនុវត្តគម្រោង។ សិក្ខាសាលាពិគ្រោះយោបល់ស្តីពីការរៀបចំគម្រោងនេះនឹងត្រូវធ្វើឡើងនៅចុងខែមីនា ឆ្នាំ ២០១៤ នៅខេត្តក្រចេះ ។ លទ្ធផលចំនួន ៣ ត្រូវបានគេរំពឹងថានឹងទទួលបានពីសិក្ខាសាលាពិគ្រោះយោបល់នេះ:

(ក) អង្គការសង្គមស៊ីវិល និងសហគមន៍នេសាទ យល់ដឹងអំពីគោលបំណងរបស់គម្រោងនេះ (ខ) មេរៀនដែលបានសិក្សា (ជោគជ័យនិងបរាជ័យ) នៃការគ្រប់គ្រងធនធានទឹក/សហគមន៍នេសាទ នឹងត្រូវបានចែករំលែក និង (គ) ដើម្បីទទួលបានយោបល់លើរបៀបដើម្បីឱ្យការគ្រប់គ្រងធនធានទឹក/សហគមន៍នេសាទប្រកបដោយចិរភាព។

# ជំពូក ៤ : ទិន្នន័យមូលដ្ឋាន

គម្រោងនេះ គ្រប់ដណ្តប់ទៅលើខេត្តចំនួន ៤ (ក្រចេះ ស្ទឹងត្រែង មណ្ឌលគិរី និងរតនគិរី) នៅភាគខាងជើងប្រទេសកម្ពុជា។ ក្នុងផ្នែកនេះនឹងផ្តល់នូវព័ត៌មានសំខាន់អំពីខេត្តក្នុងគម្រោងទាំងនេះ ដោយរួមបញ្ចូលនូវព័ត៌មានភូមិសាស្ត្រ អាកាសធាតុ ប្រជាសាស្ត្រ និងសេដ្ឋកិច្ច។ គួរកត់សំគាល់ដែរថា ផ្នែកទី ១ គ្រប់ដណ្តប់តែទៅលើខេត្តក្រចេះ និងស្ទឹងត្រែង ហើយផ្នែកទី ២ គ្រប់ដណ្តប់ទៅលើគ្រប់ផ្នែកនៃខេត្តទាំង ៤ (រូបភាពទី ១ និងទី ២)។

## ៤. ១. ខេត្តក្រចេះ

**លក្ខណៈជាទូទៅ:** ខេត្តក្រចេះស្ថិតនៅភាគខាងកើតនៃប្រទេស ហើយព្រំដែនខាងជើងជាប់ទៅនឹងខេត្តស្ទឹងត្រែង ព្រំដែនខាងកើតជាប់ខេត្តមណ្ឌលគិរី ព្រំដែនខាងលិចជាប់ខេត្តកំពង់ធំ ហើយព្រំដែនខាងត្បូងជាប់ខេត្តកំពង់ចាម។ ខេត្តនេះ ត្រូវបានហូរកាត់ដោយទន្លេមេគង្គពីជើងទៅត្បូង ហើយនឹងដីសណ្តរតូចៗរបស់វាផងដែរ។ អត្រាប្រជាជនក្នុងខេត្តក្រចេះ គឺផ្តុំនៅតាមតំបន់ក្បែរច្រាំងទន្លេមេគង្គសហគមន៍ភាគច្រើន គឺស្ថិតនៅចន្លោះជាមធ្យមពី ០.៣ ទៅ ១ គីឡូម៉ែត្រពីទន្លេមេគង្គ និងទន្លេសេកុង (ដៃទន្លេធំមួយរបស់ទន្លេមេគង្គ)។ ឆ្ងាយពីតំបន់ដីព្រៃលិចទឹក ដង់ស៊ីតេអត្រាប្រជាជនមានកម្រិតទាបស្ទួចស្តើង ហើយតំបន់ដែលគ្របដណ្តប់ដោយព្រៃមិនប៉ាល់ មានភាគច្រើនក្នុងខេត្តនេះ។

**អត្រាប្រជាជនៈ** ខេត្តនេះ មានគ្រួសារចំនួន ៦៨,១៧១ ជាមួយនឹងចំនួនប្រជាជនសរុប ៣៣១,៥៩២ នាក់ (គណៈកម្មាធិការជាតិវិមជ្ឈការល និងវិសហមជ្ឈការល (NCDD), ២០១០)។ នៅក្នុងចំណោម ពួកគេ ១៧.១៨ភាគរយនៃប្រជាជនសរុបមកពីជនជាតិដើមភាគតិចចំនួន ៧ក្រុម និងក្រុមជនជាតិភាគតិចចំនួន៣ក្រុមដែលមានដូចជា ភ្នង (១៣,៩៣៤ នាក់ ឬ ៤.២០ភាគរយ) កួយ (៩,១៩៤ នាក់ ឬ២.៧៧ ភាគរយ) ស្ទាង (៥,៥៩៥ នាក់ ឬ ១.៦៧ភាគរយ) មិល (៣,៦៩៦ នាក់ ឬ ១.១១ ភាគរយ) ក្រោល (៣,៧៥៨ នាក់ ឬ ១.១៣ ភាគរយ) ថ្មូន (១,០១១ នាក់ ឬ ០.៣០ ភាគរយ) កោញ (៨៧១ នាក់ ឬ០.២៦ភាគរយ) ខ្មែរឥស្លាម( ១៦,៧៧១ ឬ ៥.០៦ភាគរយ) វៀតណាម (២,១២១ នាក់ ឬ ០.៦៤ ភាគរយ) និងឡាវ (១២នាក់ ឬ ០.០០៤ភាគរយ)។

**សេដ្ឋកិច្ច:** ត្រីផ្សោត គឺជាចំនុចនៃការយកចិត្តទុកដាក់ចំពោះការអភិវឌ្ឍនៃវិស័យទេសចរណ៍នៅក្នុងខេត្តមួយនេះ។ មួយក្នុងចំណោមសកម្មភាពសេដ្ឋកិច្ចនៅក្នុងខេត្តក្រចេះ គឺការនេសាទធនធានជលផល ហើយខេត្តនេះ ត្រូវបានចាត់ទុកជាខេត្តទី ៦ ដែលធ្វើការនេសាទត្រី (ចំណាត់ថ្នាក់ទី ៥ សម្រាប់ធនធាន

ជលផលក្នុងប្រទេស)។ ទីតាំងសហគមន៍នេសាទ (CFis) នៅក្នុងខេត្តក្រចេះ គឺមានបង្ហាញក្នុងរូបភាពទី ៣។

**បញ្ហាអេកូឡូហ្ស៊ី និងបរិស្ថាន:** ការលាតសន្ធឹងនៃទន្លេមេគង្គកាត់ទីរួមខេត្ត ក្រុងក្រចេះ គឺជាទីកន្លែងសម្រាប់ត្រីផ្សោតទឹកសាបដែលងាយរងគ្រោះ។ ផ្នែកនៃទន្លេមេគង្គនេះត្រូវបានកំណត់ជាតំបន់អភិរក្សត្រីផ្សោត ហើយជាតំបន់ការពារអន្លង់ជ្រៅមួយចំនួន តែទោះជាយ៉ាងណាវាមិនមានតំបន់ការពារសត្វព្រៃនោះឡើយនៅតាមតំបន់ទន្លេមេគង្គក្នុងខេត្តក្រចេះ។ តំបន់អភិរក្សសត្វព្រៃភ្នំព្រិចស្ថិតក្នុងស្រុកស្នួលជាប់ទៅនឹងខេត្តមណ្ឌលគិរីគឺស្ថិតនៅក្រៅតំបន់របស់គម្រោង។ ដូចមានកត់សំគាល់ពីខាងលើការគ្រប់គ្រងធនធានជលផលនៅក្នុងទន្លេមេគង្គជាបញ្ហាកំពុងធ្វើការដោះស្រាយ។ បន្ថែមពីនេះ វាមាននូវការព្រួយបារម្ភទាក់ទិននឹងផលប៉ះពាល់នៃការសាងសង់នូវទំនប់វារីអគ្គិសនីនៅមេគង្គលើ (ប្រទេសវៀតណាម) ហើយនឹងភាពកង្វក់ ឬបំពុលដែលកើតពីការរ៉ែងរ៉ែនៅតំបន់ខាងលើ (ក្នុងប្រទេសកម្ពុជា) ទៅលើគុណភាពទឹកទន្លេ។ ព័ត៌មានមិនផ្លូវការមួយដែលនិយាយថាកម្រិតល្អក់នៃទឹកទន្លេមានការកើនឡើងរៀងរាល់ឆ្នាំ ហើយវាប៉ះពាល់ទៅដល់វិស័យទេសចរណ៍ទៀតផង។

**អាកាសធាតុ:** អាកាសធាតុក្នុងខេត្តមានលក្ខណៈដូចតទៅ÷

(ក) រដូវរងារ: វិច្ឆិកា- មីនា (១៨-២៦ $^0$C)

(ខ) រដូវក្តៅ: មីនា- ឧសភា (២៧ -៣៥ $^0$C) និង

(គ) រដូវភ្លៀង: ឧសភា - តុលា (២៦-៣៤ $^0$C សំណើមមានដល់ ៩០ភាគរយ)។




**រូបភាពទី ៣: សហគមន៍នេសាទក្នុងខេត្តក្រចេះ**

### ៤.២. ខេត្តស្ទឹងត្រែង

**លក្ខណៈទូទៅ:** ខេត្តស្ទឹងត្រែង គឺជាខេត្តដែលស្ថិតនៅភាគខាងជើងបំផុតនៃប្រទេសកម្ពុជា ហើយស្ថិតនៅផ្នែកខាងលើបំផុតនៃទន្លេមេគង្គនៃប្រទេសកម្ពុជា។ ខេត្តស្ទឹងត្រែងដែលគ្របដណ្តប់លើផ្ទៃដី ១១,០៩២ គីឡូម៉ែត្រការ៉េ គឺជាខេត្តដែលមានអត្រាប្រជាជនតិច ហើយដាច់ស្រយាលនៅភាគខាងជើង

ឈៀងខាងកើតនៃប្រទេសកម្ពុជា។ វាមានព្រំដែនខាងជើងជាប់នឹងប្រទេសឡាវ (ខេត្តចម្ប៉ាសាក់) ខាងកើតជាប់នឹងខេត្តរតនគិរី ខាងលិចជាប់នឹងខេត្តព្រះវិហារ និងខាងត្បូងជាប់នឹងខេត្តក្រចេះ និងខេត្តកំពង់ធំ។ ខេត្តនេះចែកចេញជា ៥ស្រុក ៣៤ឃុំ និង ១២៨ភូមិ។

**អត្រាប្រជាជនៈ** ខេត្តស្ទឹងត្រែង មានគ្រួសារសរុបចំនួន ២២,៨៧០ ជាមួយនឹងចំនួនប្រជាជនសរុប ១១២,២៣៧ នាក់។ ក្នុងនោះ ១២.៣៨ ភាគរយគឺជាជនជាតិដើមភាគតិចចំនួន ១០ក្រុម និងក្រុមជនជាតិភាគតិចចំនួន ៣ក្រុមដែលមានឈ្មោះដូចជា ជនជាតិព្នង (៦៥២នាក់ ឬ ០.៥៨ភាគរយ) កួយ (៤,៣៥៨ ឬ ៣.៨៨ភាគរយ) ស្ទាង (១៥១នាក់ ឬ ០.១៣ភាគរយ) ទំពួន (១៧នាក់ ឬ ០.០២ភាគរយ) ចារ៉ាយ (៣នាក់ ឬ ០.០០៣ ភាគរយ) គ្រឹង (៨៨២នាក់ ឬ ០.៧៩ភាគរយ) កាវិត ( ៣,០៤១នាក់ ឬ ២.៧១ភាគរយ) លុន (៥៤៩នាក់ ឬ ០.៤៩ភាគរយ) កាចក (៣នាក់ ឬ ០.០០៣ភាគរយ) ប៉ាវ (៥៩១នាក់ ឬ ០.៥៣ភាគរយ) ខ្មែរឥស្លាម (៣,១៧០នាក់ ឬ ២.៨២ភាគរយ) វៀតណាម (៤៣៧ នាក់ ឬ ០.៣៩ភាគរយ) និងឡាវ (៤៣នាក់ ឬ ០.០៤ភាគរយ)។

**សេដ្ឋកិច្ចៈ** សេដ្ឋកិច្ចរបស់ខេត្តស្ទឹងត្រែង គឺភាគច្រើនផ្អែកទៅលើការនេសាទ។ ខេត្តនេះជាប់ចំណាត់លេខ ២ ខាងនេសាទត្រី ហើយជាប់ចំណាត់លេខ ១ ខាងធនធានជលផលនៅក្នុងប្រទេស។ ស្រដៀងទៅនឹងខេត្តក្រចេះផងដែរ ភូមិជាច្រើនមានទីតាំងនៅតាមបណ្តោយទន្លេមេគង្គដែនទន្លេ និងពឹងផ្អែកទៅលើការនេសាទសម្រាប់សន្តិសុខស្បៀង និងការរស់នៅ។

**បញ្ហាអេកូឡូហ្ស៊ី និងបរិស្ថានៈ** ខេត្តស្ទឹងត្រែង មានលក្ខណៈគ្របដណ្តប់ទៅដោយព្រៃឈើច្រើនមានដង់ស៊ីតេប្រជាជនទាប។ ខេត្តនេះមានឧទ្យានវិរៈជ័យស្ថិតនៅភាគខាងលិច។ ការលាតសន្ធឹងទន្លេមេគង្គក្នុងខេត្តស្ទឹងត្រែង ត្រូវបានគេចាត់ទុកជាតំបន់សក្តានុពលមួយជាតំបន់រ៉ាំសារក្នុងឆ្នាំ ១៩៩៤ (Asian Wetlands Bureau ១៩៩៤)។ ក្នុងឆ្នាំ ១៩៩៩ វាត្រូវបានគេចាត់បញ្ចូលនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានអភិរក្ស និងការពារធម្មជាតិរបស់ក្រសួងបរិស្ថាន។ នៅថ្នាក់មូលដ្ឋាននៃតំបន់នោះ មន្ទីរបរិស្ថានខេត្តទទួលការមើលថែរក្សា គ្រប់គ្រងទៅលើតំបន់រ៉ាំសារនេះ។ តំបន់រ៉ាំសារ (រូបភាពទី ៤) គ្របដណ្តប់លើផ្ទៃដីប្រវែងប្រហែល ៣៧ គីឡូម៉ែត្រតាមបណ្តោយទន្លេមេគង្គក្នុងខេត្តស្ទឹងត្រែងដែលក្នុងនោះមានភូមិចំនួន ២១ ឃុំចំនួន ៣ និងសង្កាត់ចំនួន ១។ នៅតាមបណ្តោយនៃតំបន់នេះ សហគមន៍នេសាទមានចំនួន ២១ ដែលបង្កើតឡើងផ្សេងៗគ្នា (មើលតារាងទី ២ និងរូបភាពទី ៥)។ បច្ចុប្បន្នស្ថានីយ៍ភ្ញាស់កូនត្រីមានទីតាំងស្ថិតនៅក្បែរទន្លេសេកុង ហើយប្រហែល ៧ គីឡូម៉ែត្រពីព្រំប្រទល់តំបន់រ៉ាំសារ។ តំបន់រ៉ាំសារមានផ្នែកចំនួន ២ ជាមួយនឹងដីកោះមួយចំនួន ផ្លូវទឹកបើកនៅក្នុងតំបន់កោះគី។

តំបន់រ៉ាំសារសំបូរទៅដោយជីវចម្រុះច្រើនបែបដែលសំខាន់មិនត្រឹមតែចំពោះប្រទេសកម្ពុជាទេ ប៉ុន្តែវាមានសារសំខាន់ទាំងក្នុងតំបន់ និងជាសកលផងដែរ។ ការសិក្សាថ្មីៗ បានសរសេរថា ប្រភេទសត្វកម្រ និងរងទទួលគ្រោះថ្នាក់មួយចំនួនបានរកឃើញនៅក្នុងតំបន់រ៉ាំសារនេះ (Bambaradeniya *et al*. ២០០៦, Timmins ២០០៦, Boonratana *et al*. ២០០៥, Sarinder Singh ២០០៦, Kong Kim Sreng and Lopez, ២០០៦, Sala Phum, ២០០៦)។

វាមិនទាន់មានការសិក្សាជាលក្ខណៈប្រព័ន្ធណាមួយទាក់ទិនទៅនឹងត្រី ក្នុងតំបន់រ៉ាំសារនេះនៅឡើយទេ។ ប្រភេទត្រីច្រើនជាង ៨៥០ ត្រូវបានរកឃើញនៅក្នុងទន្លេមេគង្គក្រោម និងទន្លេសាប ហើយអាចចែកចេញជា ២ក្រុម គឺក្រុមត្រីស និងក្រុមត្រីខ្មៅ។ ក្រុមត្រីសត្រូវការកម្រិតអុកស៊ីសែនខ្ពស់នៅក្នុងទឹក និងកម្រិត pH ទាបជាងក្រុមត្រីខ្មៅ។ ពួកវាផ្លាស់ទីជាទៀងទាត់រវាងបឹងទន្លេសាប និងទន្លេមេគង្គលើនៅតាមដៃនានានៅក្នុងតំបន់រ៉ាំសារនៅពេលទឹកទន្លេឡើងក្នុងខែវស្សា។ ដូចនេះ ពួកត្រីនេះបង្កើតបានជាប្រភពត្រីសំខាន់មួយនៅតំបន់រ៉ាំសារ។ ក្រុមត្រីខ្មៅ គឺជាត្រីដែលនៅក្នុងបឹងទន្លេសាបជាអចិន្ត្រៃយ៍ (Ashwell, ១៩៩៧)។ តាមរយៈការសិក្សាលម្អិតទៅលើត្រីក្នុងតំបន់រ៉ាំសារ លោក វង្ស (២០០៤) បានរកឃើញត្រីចំនួន ១៦៧ ប្រភេទ ហើយនៅមានច្រើនប្រភេទទៀតដែលនឹងត្រូវរកឃើញ។ ក្នុងចំណោមប្រភេទដែលបានរកឃើញមាន ២១ប្រភេទ ត្រូវបានកំណត់ថាជាប្រភេទត្រីសំខាន់នៅក្នុងតំបន់រ៉ាំសារ ដូចដែលមានបង្ហាញក្នុងតារាងទី ២។ រូបភាពទី ៥ បង្ហាញពីទីតាំង របស់ សហគមន៍នេសាទ (CFis) នៅក្នុងខេត្តនេះ។




**រូបភាពទី ៤: ព្រំដែននៃតំបន់រ៉ាំសារក្នុងខេត្តស្ទឹងត្រែង**

**តារាង ទី ២: ឈ្មោះភូមិនៅក្នុងតំបន់រ៉ាំសារ**

| ល.រ | សហគមន៍នេសាទ | ភូមិ | ឃុំ | ស្រុក |
|---|---|---|---|---|
| ១ | ថៅតាម៉ៅមានជ័យ | កំភុនសេសាន | កំភុន | ថាឡាបរិវ៉ាត់ |
| ២ | អន្លង់ស្វាយ | អន្លង់ស្វាយ | អូររ៉ៃ | ថាឡាបរិវ៉ាត់ |
| ៣ | ក្រោម | ក្រោម | ព្រះរំកិល | ថាឡាបរិវ៉ាត់ |
| ៤ | កណ្ដាល | កណ្ដាល | ព្រះរំកិល | ថាឡាបរិវ៉ាត់ |
| ៥ | លើ | លើ | ព្រះរំកិល | ថាឡាបរិវ៉ាត់ |
| ៦ | ក្រឡាព្រះ | ក្រឡាព្រះ | ព្រះរំកិល | ថាឡាបរិវ៉ាត់ |
| ៧ | កោះល្វរ | កោះល្វរ | ព្រះរំកិល | ថាឡាបរិវ៉ាត់ |
| ៨ | កោះ ផ្ដៅ | កោះផ្ដៅ | អូរស្វាយ | ថាឡាបរិវ៉ាត់ |
| ៩ | អូរស្វាយ | អូរស្វាយ | អូរស្វាយ | ថាឡាបរិវ៉ាត់ |
| ១០ | អូររុន | អូររុន | អូរស្វាយ | ថាឡាបរិវ៉ាត់ |
| ១១ | កោះកី | កោះកី | កោះស្នែង | ថាឡាបរិវ៉ាត់ |
| ១២ | ចោមធំ | ចោមធំ | កោះស្នែង | ថាឡាបរិវ៉ាត់ |

| | | | | |
|---|---|---|---|---|
| ១៣ | កោះស្នែង | កោះស្នែង | កោះស្នែង | ថាឡាបរិវ៉ាត់ |
| ១៤ | កោះស្រឡៅ | កោះស្រឡៅ | កោះស្នែង | ថាឡាបរិវ៉ាត់ |
| ១៥ | កោះឈើទាលតូច | កោះឈើទាលតូច | ព្រះរិកិល | ថាឡាបរិវ៉ាត់ |
| ១៦ | កោះឈើទាលធំ | កោះឈើទាលធំ | ព្រះរិកិល | ថាឡាបរិវ៉ាត់ |
| ១៧ | វឿនសាន | វឿនសាន | អូរស្វាយ | ថាឡាបរិវ៉ាត់ |
| ១៨ | កោះហិប | កោះហិប | អូរស្វាយ | ថាឡាបរិវ៉ាត់ |
| ១៩ | ឃេ | ឃេ | សាមគ្គី | ស្ទឹងត្រែង |
| ២០ | កោះខនឌិន | កោះខនឌិន | សាមគ្គី | ស្ទឹងត្រែង |
| ២១ | ថ្មី | ថ្មី | សាមគ្គី | ស្ទឹងត្រែង |




**រូបភាពទី ៥: សហគមន៍នេសាទក្នុងខេត្តស្ទឹងត្រែង**

### ៤.៣. ខេត្តមណ្ឌលគិរី

**លក្ខណៈទូទៅ:** ខេត្តមណ្ឌលគិរី មានផ្ទៃដីសរុប ១៤,២៨៨ គីឡូម៉ែត្រការ៉េ មានចម្ងាយប្រហែល ៣៧៥ គីឡូម៉ែត្រពីទីក្រុងភ្នំពេញ ស្ថិតនៅភាគខាងត្បូងឈៀងខាងកើត (ស្ថិតនៅកម្ពស់ ប្រហែល ២០០-១០០០ ម៉ែត្រពីនីវ៉ូទឹកសមុទ្រ)។ ខេត្តនេះមានព្រំប្រទល់ខាងកើត និងខាងត្បូងជាប់នឹងប្រទេសវៀតណាម ខាងជើងជាប់នឹងខេត្តរតនគិរី ហើយខាងលិចជាប់នឹងខេត្តក្រចេះ។ វាជាខេត្តដែលធំ និងមានប្រជាជនតិចបំផុតនៅក្នុងប្រទេសកម្ពុជា។ ទន្លេសំខាន់ៗចំនួន ២ ហូរកាត់ខេត្តមួយនេះ គឺទន្លេព្រែកច្បារ និងទន្លេព្រែកទេរ។ សណ្ឋានដីក្នុងខេត្តនេះ គឺជាតំបន់ខ្ពង់រាបសំបូរភ្នំ ដែលភាគច្រើនគ្របដណ្តប់ទៅដោយព្រៃឈើ និងជ្រលងរាក់ៗផងដែរ។

**អត្រាប្រជាជន:** ប្រជាជនសរុបមានចំនួន ៤៤,៩១៣ នាក់ មានដង់ស៊ីតេ ៣.១៤នាក់ក្នុង ១គីឡូ ម៉ែត្រការ៉េ។ ពីឆ្នាំ ២០០៧ ចំនួនប្រជាជនសរុបក្នុងខេត្តបានកើនឡើង ៦ ភាគរយ ក្នុងឆ្នាំ ២០០៨ ហើយធ្លាក់ចុះវិញពី ៦ភាគរយ ទៅ ២ភាគរយក្នុងឆ្នាំ២០០៩ ហើយបានកើនឡើងម្តងទៀតពី ២ភាគរយទៅ ៨ភាគរយក្នុងឆ្នាំ២០១០។ ក្នុងចំណោមចំនួនប្រជាជននេះ ៧០.៧០ភាគរយ ចេញមកពីជនជាតិដើមភាគតិចចំនួន ៩ក្រុម និងក្រុមជនជាតិភាគតិចចំនួន ៣ មានដូចជា ជនជាតិព្នង (៣៦,៩៩២នាក់ ឬ ៥៩.៤៦ភាគរយ) កួយ (២៣ នាក់ ឬ ០.០៤ភាគរយ) ស្ទាង (៤៩២នាក់ ឬ ០.៧៩ភាគរយ) មិល (៣៥៥នាក់ ឬ ០.៥៧ភាគរយ) ក្រោល (១,០៨១នាក់ ឬ ១.៧៤ភាគរយ) ថ្មូន (៤៩នាក់ ឬ ០.០៨ភាគរយ) ទំពួន (៣២នាក់ ឬ ០.០៥ភាគរយ) ចារ៉ាយ (២៥៥នាក់ ឬ ០.៣៦ភាគរយ) គ្រៀង (៨០នាក់ ឬ ០.១៣ភាគរយ) និងក្រុមជនជាតិភាគតិច ដូចជា ខ្មែរឥស្លាម ( ៣,៤៥៥នាក់ ឬ ៥.៤៤ភាគរយ) វៀតណាម (៨៧នាក់ ឬ ០.១៣ភាគរយ) និងឡាវ (១,១៣០នាក់ ឬ ១.៨២ភាគរយ)។

**សេដ្ឋកិច្ច:** ភាគច្រើននៃជនជាតិដើមភាគតិច ដែលរស់នៅក្នុងខេត្តមណ្ឌលគិរី ជាកសិករចិញ្ចឹមជីវិតដោយសំអាងលើវិធីសាស្រ្តដាំដុះប្រពៃណី ប្រម៉ាញ់ និងអនុផលព្រៃឈើ។ អ្នកផ្សេងទៀតដាំកាហ្វេ ស្ត្របឺរី កៅស៊ូ និងស្វាយចន្ទី។ វប្បធម៌ចំណាស់មួយនេះជឿទៅលើព្រលឹងដែលផ្តើមចេញពីការជឿលើវិញ្ញាណសត្វ។ ផលិតផលស្រាអង្ករដំល្បី ដែលជាផលិតផលល្អមួយក្នុងចំណោមផលិតផលនានាក្នុងប្រទេស គឺមានភាពដុះដាលក្នុងតំបន់នេះ។ នៅទីនោះមានវិស័យទេសចរណ៍តូចមួយដែលផ្តល់នូវទីផ្សារសម្រាប់ជនជាតិដើមភាគតិចលក់ផលិតផលដែលធ្វើដោយដៃ ដូចជាខ្សែដៃ ខ្សែក កន្សែង និងក្រម៉ា។ តែទោះជាយ៉ាងណា ការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងតំបន់ថ្មីៗនេះបានកើនឡើងជាមួយនឹងការទាញយកធនធានធម្មជាតិ ដែលជាពិសេសធនធានរ៉ែ និងការដាំដំណាំកៅស៊ូ។

**បញ្ហាអេកូឡូហ្ស៊ី និងបរិស្ថាន÷** នៅក្នុងខេត្តនេះ តំបន់អភិរក្សសំខាន់ៗចំនួន ៤ ត្រូវបានបង្កើតឡើងរួមមាន (ក) តំបន់អភិរក្សជីវចម្រុះតំបន់សីម៉ាដោយមានផ្នែកខ្លះនៅក្នុងខេត្តក្រចេះ (៣០៥,៤៤០ ហិចតា) (ខ) ព្រៃអភិរក្សមណ្ឌលគីរី (៤២៩,៤៣៨ហិចតា) (គ) ភ្នំព្រិចលំផាត់ និង (ឃ) ជម្រកសត្វព្រៃណាំលា។ តំបន់អភិរក្សជីវចម្រុះសីមា និងព្រៃអភិរក្សមណ្ឌលគីរី ត្រូវបានបង្កើតឡើងដោយក្រឹត្យរបស់ក្រសួងក្នុងឆ្នាំ២០០២ ហើយត្រូវបានគ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ ស្ថិតក្រោមដែនសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ។ តំបន់ភ្នំព្រិច និងជម្រកសត្វព្រៃណាំលាត្រូវបានប្រកាសដាក់ជាតំបន់ការពារដោយអនុក្រឹត្យឆ្នាំ១៩៩៣។ តំបន់ជម្រកសត្វព្រៃលំផាត់ក្នុងខេត្តមណ្ឌលគីរីគឺមានផ្នែកខ្លះនៅក្នុងខេត្តរតនគីរី ហើយតំបន់ជម្រកសត្វព្រៃស្នួល គឺមានផ្នែកខ្លះក្នុងខេត្តក្រចេះ។ តំបន់ជម្រកសត្វព្រៃទាំង ៤នេះ គឺស្ថិតនៅក្រោមក្រសួងបរិស្ថាន។

ការដាំចំការកៅស៊ូ និងការរុករករ៉ែ បាននាំឲ្យមានផលប៉ះពាល់អវិជ្ជមានមួយចំនួន រួមមានសំណឹកដី និងការបាត់បង់គុណភាពជាដើម។ ទោះបីជាមានការកាប់បំផ្លាញព្រៃឈើយ៉ាងណាក៏ដោយ ជាពិសេសកើតចេញពីការអភិវឌ្ឍយ៉ាងគំហុកទៅលើការរុករករ៉ែ ខេត្តមណ្ឌលគីរី ក៏នៅតែជាខេត្តមួយដែលមានដីដាំព្រៃបម្រុងទុកធំជាងគេបំផុតក្នុងប្រទេសកម្ពុជា។

### ៤.៤. ខេត្តរតនគីរី

**លក្ខណៈទូទៅ:** ខេត្តរតនគីរីស្ថិតនៅភាគខាងជើងឈៀងខាងកើតនៃខ្ពង់រាប (ខ្ពស់ជាងនីវ៉ូទឹកសមុទ្រពី ២០០ ទៅ ៤០០ម៉ែត្រ) មានចំងាយ ៦៣៦ គីឡូម៉ែត្រពីទីក្រុងភ្នំពេញ។ ខេត្តនេះមានព្រំប្រទល់ខាងជើងជាប់ជាមួយនឹងប្រទេសឡាវ ខាងកើតជាប់វៀតណាម ខាងត្បូងជាប់ខេត្តមណ្ឌលគីរី និងខាងលិចជាប់ខេត្តស្ទឹងត្រែង។ មានទន្លេចំនួន២ ហូរកាត់ខេត្តមួយនេះ គឺទន្លេស្រែពក និងទន្លេសេសាន។ ផ្ទៃដីសរុបមានប្រហែលជា ១០,៧៨៩ គីឡូម៉ែត្រការ៉េ។ រហូតមកដល់ឆ្នាំ ២០០២ ខេត្តរតនគីរី គឺស្ថិតនៅដាច់ស្រយាល ហើយដំណើរការនៃការផ្តល់សេវា និងការចូលរួមក្នុងកិច្ចដំណើរការអភិវឌ្ឍសេដ្ឋកិច្ចក៏នៅមានកម្រិតទាបនៅឡើយ។

**អត្រាប្រជាជន:** ខេត្តដែលសំបូរថ្មដាច់ស្រយាលពីគេនេះ មានក្រុមជនជាតិដើមភាគតិច ៧០ភាគរយដែលគេហៅថា "ជនជាតិដើម"។ ក្នុងខេត្តនេះ មាន ៣២,៩៤៧ គ្រួសារ តំណាងឲ្យចំនួនប្រជាជនសរុប ១៥៦,៧០៥ នាក់។ ក្នុងឆ្នាំ ២០០៧ គេរកឃើញថាតាំងពីឆ្នាំ ២០០៧មក ចំនួនប្រជាជនក្នុងខេត្តនេះបានកើតឡើង ៥ភាគរយក្នុងឆ្នាំ ២០០៨ និង ២០០៩។ ក្នុងចំណោមប្រជាជនសរុបទាំងនោះ ៧១.៤២ ភាគរយមកពីក្រុមជនជាតិដើមភាគតិច ចំនួន ៩ក្រុម និងក្រុមជនជាតិភាគតិចចំនួន ៣ មានដូចជាជន

ជាតិព្នង (៤៦៦នាក់ ឬ ០.៣០ភាគរយ) ក្ងួយ (១នាក់ ឬ ០.០០១ភាគរយ) ស្ទាង (១២១ នាក់ ឬ ០.០៨ ភាគរយ) ទំពួន (៣៣,៥០៦នាក់ ឬ ២១.៣៨ភាគរយ) ចារ៉ាយ (២៤,៨៣៤នាក់ ឬ ១៥.៨៥ ភាគរយ) គ្រឹង (២២,១២២នាក់ ឬ ១៤.១២ភាគរយ) កាវិត (២,៩៤៧នាក់ ឬ ២.៧៨ ភាគរយ) ប្រៅ (៨,៩៨៥នាក់ ឬ ៥.៧៣ភាគរយ) និងក្រុមជនជាតិភាគតិច ដូចជាឥស្លាម (២,៥០១នាក់ ឬ ១.៦ភាគរយ)វៀតណាម (៧៩៥នាក់ឬ ០.៥១ភាគរយ) និងឡាវ (១១,២៤៩នាក់ ឬ ៧.១៨ភាគរយ)។ ភាគច្រើននៃពួកគេរស់នៅក្នុងព្រៃជ្រៅ នៅលើទួលភ្នំ និងភ្នំជាលក្ខណៈភូមិតូចៗដាច់ៗពីគ្នា។ ជារឿយៗ ពួកគេរស់នៅដោយពឹងផ្អែកទៅលើការដាំដុះប្រពៃណី (ការធ្វើចំការផ្លាសទី) ការប្រមាញ់ និងការប្រមូលផ្លែឈើព្រៃ។ វប្បធម៌ចំណាស់មួយនេះ មានជំនឿទៅលើព្រលឹង ដែលកើតចេញពីកការជឿទៅលើព្រលឹងរបស់សត្វ។

**សេដ្ឋកិច្ចៈ**ភាគច្រើននៃប្រជាជនម្ចាស់ស្រុកទាំងអស់ដែលរស់នៅក្នុងខេត្តរតនគិរី គឺប្រកបរបរកសិកម្មចិញ្ចឹមជីវិតមួយចំនួនទៀតដាំដុះដំណាំសម្រាប់លក់ ដូចជាស្វាយចន្ទី ឬសណ្តែកដី។ នៅទីនោះមានជនជាតិខ្មែរ និងវៀតណាមដែលជាអ្នកមានកម្រិតជីវភាពខ្ពស់ដែលកាន់កាប់ទៅលើដីចំការធំៗនៅជុំវិញក្រុងបានលុង ហើយដាំនូវសណ្តែកដី កាហ្វេ និងស្វាយចន្ទី។ តែទោះជាយ៉ាងណាខេត្តរតនគិរីមានអត្រាប្រជាជនទាប ដែលធ្វើឱ្យខេត្តនេះមិនមានទីផ្សារគ្រប់គ្រាន់ដើម្បីប្រកួតប្រជែងជាមួយនឹងខេត្តផ្សេងៗបាននៅឡើយ។ ខេត្តរតនគិរីមានសក្តានុពលខាងដំណាំកៅស៊ូ ហើយកៅស៊ូភាគច្រើនត្រូវបាននាំចេញទៅប្រទេសវៀតណាម។ ដោយសារតែមានការអភិវឌ្ឍឡើងវិញ នាពេលបច្ចុប្បន្ន មានផ្លូវជាតិ លេខ ១៩ ដែលឆ្លងកាត់ទីក្រុងបាលុង វិស័យពាណិជ្ជកម្មក្នុងវិស័យកៅស៊ូនេះនឹងកាន់តែកើនឡើងបន្តទៀត។ ខេត្តរតនគិរីសំបូរទៅដោយធនធានរ៉ែមានតម្លៃ ដូចជា មាស ត្បូង រ៉ែក្រានីត និងរ៉ែត្បូង Onyx។ ឧស្សាហកម្មរ៉ែ កំពុងរីកលូតលាស់ជាបណ្តើរៗ បើទោះជានៅមានលក្ខណៈតូចនៅឡើយក៏ដោយ។

**បញ្ហាអេកូឡូហ្ស៊ី និងបរិស្ថានៈ** នៅក្នុងខេត្តនេះ ឧទ្យានជាតិវីរជ័យ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៤ ដោយក្រសួងបរិស្ថាន លើផ្ទៃដីសរុប ៣.៣២៥ គីឡូម៉ែត្រការ៉េ ហើយវាជាឧទ្យានជាតិធំជាងគេក្នុងចំណោមឧទ្យានជាតិ ៧ក្នុងប្រទេសកម្ពុជា។ វាផ្តល់នូវទេសភាពសម្រាប់ការទស្សនាមិនគួរឱ្យជឿនូវភាពលាតសន្ធឹងធំធេង និងសត្វព្រៃដែលមាននៅក្នុងឧទ្យាននេះ។ ឧទ្យានជាតិវីរជ័យស្ថិតក្នុងខេត្តរតនគិរី និងស្ទឹងត្រែង។ វាក៏មានព្រំប្រទល់ជាប់ទៅនឹងប្រទេសឡាវផងដែរ។ ប៉ុន្តែតំបន់គម្រោងដែលគ្រោងនឹងប្រតិបត្តិមិនមានក្នុងតំបន់ឧទ្យានជាតិនេះឡើយ ។

ដូចទៅនឹងខេត្តមណ្ឌលគិរី ការរុករករ៉ែ និងដំណាំចំការ ដែលបានធ្វើឲ្យមានសំណឹកដី និងគុណភាពទឹកធ្លាក់ចុះនៅក្នុងស្ទឹង និងទន្លេដែលធ្វើឲ្យប៉ះពាល់ដល់ធនធានមច្ឆាជាតិ។

**អាកាសធាតុ:** ខេត្តរតនគិរី មានអាកាសធាតុដូចនឹងតំបន់ដទៃក្នុងប្រទេសដែរ វាមាននូវរដូវចំនួន ៣ រដូវភ្លៀងពីខែ មិថុនា-តុលា (ទាបជាង២៧ $^{0}$C) រដូវរងារពីខែវិច្ឆិកា - កុម្ភៈ (ខ្ពស់ជាង ២៤ $^{0}$C) និងរដូវក្តៅពីខែ មីនា-ឧសភា សីតុណ្ហភាពពី ២០ ដល់ ៣០ $^{0}$C។ ខេត្តរតនគិរីមានសីតុណ្ហភាពជាមធ្យមពេញមួយឆ្នាំ គឺទាបជាងតំបន់ផ្សេងៗក្នុងប្រទេសកម្ពុជា (លើកលែងខេត្តមណ្ឌលគិរី)។

### ៤.៥ គុណភាពទឹកក្នុងតំបន់ ស ៣

គុណភាពទឹកក្នុងតំបន់ ស៣ ដែលបានទិន្នន័យពីស្ថានីយ៍ចំនួន ៤ ក្នុងកំឡុងពីឆ្នាំ ២០០៤ ដល់ ២០០៨ (ទិន្នន័យ MOWRAM,២០០៤-២០០៨) ត្រូវបានគេវាយតម្លៃធៀបទៅនឹងប្រភេទនៃគុណភាពទឹកចំនួន ៣ប្រភេទ÷ (ក) សន្ទស្សន៍គុណភាពទឹកសម្រាប់ជីវិតវារីសត្វ (ខ) សន្ទស្សន៍គុណភាពទឹកសម្រាប់មនុស្សប្រើ និង(គ) សន្ទស្សន៍គុណភាពទឹកសម្រាប់ប្រើប្រាស់ក្នុងវិស័យកសិកម្ម។ ដោយអនុវត្តទៅតាមគោលការណ៍ណែនាំរបស់ MRC សន្ទស្សន៍គុណភាពទឹកសម្រាប់វារីសត្វក្នុងទឹក ត្រូវបានវាយតម្លៃធៀបនឹងប៉ារ៉ាមត្រចំនួន ៦ ដូចជា (ក) អុកស៊ីសែនរលាយក្នុងទឹក (DO), (ខ)កម្រិត pH (ការ វាស់កម្រិតជាតិអាស៊ីត/អាល់កាឡាំង), (គ) សារធាតុ $NH_3$ (អាម៉ូញ៉ាក់), (ឃ) ការចម្លងកម្តៅ, (ង) សារធាតុ $NO_3/NO_2$, និង (ច) សារធាតុ P (ផូស្វ័រ)។

ជាទូទៅ គុណភាពទឹក គឺមានលក្ខណៈល្អ ប៉ុន្តែវាកំពុងតែវិវត្តបន្តិចម្តងៗទៅរកការខូចនូវគុណភាពទឹកជាពិសេស គឺដោយសារតែការរីកធំឡើងនូវការធ្វើសកម្មភាពសេដ្ឋកិច្ចនានា នៅតំបន់ខាងលើនៃទន្លេទាំងនៅក្នុងប្រទេសកម្ពុជា និងប្រទេសវៀតណាម។

**តារាងទី ៣: គុណភាពទឹកនៅស្ថានីយ៍ត្រួតពិនិត្យ ទន្លេសេកុង សេសាន និងស្រែពក**

| ប៉ារ៉ាម៉ែត្រគុណភាពទឹក | សេកុង សៀមប៉ាង | សេសាន អណ្តូងមាស | សេសាន ភ្នំពីរ | ស្រែពក លំផាត់ |
|---|---|---|---|---|
| Temp ($^{0}$C) | ២៨.៥ | ២៧.៨ | ២៧.៨ | ២៨.៥ |
| pH | ៧.១ | ៧.២ | ៧.២ | ៧.១ |
| TSS (mg/L) | ៤៦.១២៣ | ៣៣.៨០៨ | ៣៣.៨០៨ | ៤២.៤០២ |
| Cond (mS/m) | ៥.៣៥៧ | ៤.០០០ | ៤.៦១១ | ៦.០០៥ |

| | | | | |
|---|---|---|---|---|
| Ca (meg/L) | ០.២២០ | ០.១៣១ | ០.១៨០ | ០.២១៤ |
| Mg (meg/L) | ០.១៦១ | ០.០៩៨ | ០.១០០ | ០.១៥៨ |
| Na (mg/L) | ០.១៣១ | ០.១៣២ | ០.១៣៧ | ០.១៧៤ |
| K (mg/L) | ០.០២៥ | ០.០៤០ | ០.០៤២ | ០.០៤១ |
| ALK (meg/L) | ០.៤៣៥ | ០.២៩៥ | ០.៣១៦ | ០.៤៣២ |
| Cl (meh/L) | ០.០២៨ | ០.២៩៥ | ០.១០៩ | ០.០៥៧ |
| SO៤ (meg/L) | ០.០៨០ | ០.០៨០ | ០.១០៩ | ០.១០០ |
| NO២-N (mg/L) | ០.០៧៥ | ០.១០៧ | ០.១០០ | ០.២០៥ |
| NH៤-N (mg/L) | ០.០៣៨ | ០.០៣៩ | ០.០៣៩ | ០.០៤០ |
| TOTP (mg/L) | ៧.៣៥៣ | ០.០៦៩ | ០.០៤៣ | ០.០៨៩ |
| DO (mg/L) | ២.៨២០ | ៧.៧៤០ | ៧.៦៤១ | ៧.៦៦៤ |
| CONDMN (mg/L) | | ២.០៩១ | ៣.៣៨៧ | ៣.២៣៨ |

**ប្រភព: ក្រសួងធនធានទឹក និងឧតុនិយម MOWRAM (២០០៤-២០០៨)**

ចំណាំ: ប៉ារ៉ាម៉ែត្រទាំងនេះ បង្ហាញក្នុងតារាងមួយនេះ ជាអក្សរកាត់ដូចតទៅ Temp (temperature សីតុណ្ហភាព); pH (Phosphorus កម្រិត pH); TSS (Total Suspended Solids ជាតិល្អក់ក្នុងទឹក); Cond (Conductivity ការចម្លងកម្ដៅ)។

# ជំពូកទី ៥: ផលប៉ះពាល់ដែលអាចកើតមាននៅលើបរិស្ថាន និងសង្គមរបស់គម្រោង

ដូចបាននិយាយរៀបរាប់ក្នុងផ្នែកមុន គម្រោងនេះ ត្រូវបានកំណត់ជាប្រភេទ ខ ហើយត្រូវបានដាក់ចេញនូវគោលនយោបាយសុវត្ថិភាពចំនួន ៥ មានដូចជាការវាយតម្លៃបរិស្ថាន (OP/BP ៤.០១) ជនជាតិដើមភាគតិច (OP/BP ៤.១០) ការកសាងលំនៅដ្ឋានឡើងវិញដោយស្ម័គ្រចិត្ត (OP/BP ៤.១២) ជម្រកធម្មជាតិ (OP/BP ៤.០៤) និងគម្រោងនានាលើផ្លូវទឹកអន្តរជាតិ (OP/BP ៧.៥០)។ តាមរយៈការផ្តល់នូវគោលបំណង និងទំហំរបស់គម្រោងនេះគេបានធ្វើការប៉ាន់ស្មានថាសកម្មភាពនានារបស់គម្រោងនឹងមិនបង្កឲ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅលើបរិស្ថាន និងសង្គមនោះទេ។ ការត្រួតពិនិត្យផ្នែកបរិស្ថាន និងសង្គមដំបូង (IESE) ត្រូវបានធ្វើឡើងដោយយោងទៅតាមតម្រូវការរបស់រាជរដ្ឋាភិបាល។ សកម្មភាព និងបញ្ហាត្រូវការពារជាគន្លឹះដែលនឹងត្រូវអនុវត្តដើម្បីបញ្ចៀសនូវផលប៉ះពាល់អវិជ្ជមានក្នុងអំឡុងពេលគម្រោងអនុវត្តដែលត្រូវបានសង្ខេបដូចខាងក្រោមៈ

## ៥.១. ផលប៉ះពាល់ដែលអាចកើតមានលើបរិស្ថាន និងវិធានការណ៍បន្ធូរបន្ថយ

### ៥.១.១ ផលប៉ះពាល់ដែលអាចកើតមានលើបរិស្ថានក្នុងអំឡុងពេលនៃការសាងសង់

រាល់គ្រប់សកម្មភាពវិនិយោគ និងគម្រោងខ្នាតតូចនានាដែលពាក់ព័ន្ធទៅនឹងការងារសាងសង់មាននូវនាំឲ្យកើតមាននូវផលប៉ះពាល់ជាអវិជ្ជមានដែលអាចកើតមាន ដូចជាធូលី សម្លេង កង្វក់ គ្រោះថ្នាក់ និងបញ្ហាផ្សេងៗទៀត។ សកម្មភាពរបស់គម្រោងបានស្នើសុំឲ្យសកម្មភាពដែលពាក់ព័ន្ធនឹងការងារសកម្មភាពរបស់ប្រជាពលរដ្ឋត្រូវធ្វើការកម្រិតក្នុងលក្ខខណ្ឌត្រឹមត្រូវដើម្បី (ក) ការកសាងនូវស្ថានីយ៍អង្កេតទៅលើជលវិទ្យាក្នុងតំបន់អាង ការកែលម្អនូវហេដ្ឋារចនាសម្ព័ន្ធជនបទសំខាន់ៗដែលមានស្រាប់ (ដូចជាផ្លូវភូមិ ស្ពានសម្រាប់ដើរ ។ល។) និងកសាងស្ថានីយ៍ភ្ញាស់កូនត្រីខ្នាតតូចមួយកន្លែងនៅក្នុងខេត្តស្ទឹងត្រែង (ផ្នែកទី ១)។

គ្រប់ផលប៉ះពាល់អវិជ្ជមានទាំងអស់ដែលជាប់ពាក់ព័ន្ធទៅនឹងការងារសាងសង់ពីខាងលើនេះដែលមានលក្ខណៈតូចៗនៅឡើយនឹងត្រូវកាត់បន្ថយតាមរយៈការដាក់ចេញនូវការអនុវត្តបច្ចេកទេសសាងសង់ត្រឹមត្រូវ និងកូដបរិស្ថានសម្រាប់ការអនុវត្ត ដែលនឹងផ្តល់នូវវិធានការដើម្បីកាត់បន្ថយនូវធូលីសម្លេង និងកង្វក់ ក៏ដូចជាការបន្តរក្សាការផ្តល់ការយល់ដឹងដល់សហគមន៍ក្បែរៗនោះ។

ប្រសិនបើសកម្មភាព ឬក៏អនុគម្រោងមួយចំនួនដែលបានដាក់ចេញ ត្រូវការនូវឯកសារវាយតម្លៃបរិស្ថានដោយយោងទៅតាមច្បាប់របស់បរិស្ថានជាតិ CNMC (ចំពោះផ្នែកទី ២) និង FiA (ចំពោះផ្នែកទី ១)

នឹងរៀបចំឯកសារត្រឹមត្រូវ និងការអនុញ្ញាតពីក្រសួងបរិស្ថាន ក៏ដូចជាធនាគារពិភពលោកផងដែរ។ រាល់សកម្មភាពធំៗទាំងឡាយណាដែលតម្រូវឲ្យមានការវាយតម្លៃពេញលេញ ទៅលើផលប៉ះពាល់បរិស្ថាន (EIA) ដោយរដ្ឋាភិបាល ឬធនាគារពិភពលោក នឹងត្រូវចាត់ទុកថាជាសកម្មភាព ឬគម្រោងដែលមិនបានទទួលការអនុញ្ញាតឡើយ។ ការអនុវត្តបច្ចេកទេសសាងសង់ត្រឹមត្រូវ និងក្រូដបរិស្ថានសម្រាប់អនុវត្ត (ECOPs) ដែលនឹងត្រូវដាក់បញ្ចូលក្នុងឯកសារ ឬកុងត្រាដេញថ្លៃនឹងបង្ហាញក្នុងឧបសម្ព័ន្ធទី ៤ ចំពោះគ្រោងការគ្រប់គ្រងបិស្ថាន និងសង្គមនេះ។

### ៥.១.២ ផលប៉ះពាល់បរិស្ថានដែលអាចកើតមានទៅលើជម្រកធម្មជាតិសំខាន់ៗ

ផលប៉ះពាល់ទាំងអស់នឹងត្រូវរំពឹងទុកជាផលវិជ្ជមានដោយសារតែគម្រោងនេះមានគោលដៅបង្កើតនូវការគ្រប់គ្រងជលផលបានល្អ។ ផ្នែកទី ១ មានគោលដៅគាំទ្រសហគមន៍នេសាទដើម្បីអាចរៀបចំផែនការគ្រប់គ្រងជលផលដោយខ្លួនឯង។ នេះនឹងជួយឲ្យដល់ការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីកំណត់ និងស្វែងរកលទ្ធភាពនានាដែលអាចបង្កើតនូវតំបន់អភិរក្សអេកូឡូហ្ស៊ីក្នុងទន្លេមេគង្គ ដែលជាពិសេសនៅតាមបណ្តាអន្លង់ជ្រៅៗ ដែលត្រូវបានចាត់ទុកថាសំខាន់សម្រាប់ប្រភេទសត្វដែលជិតផុតពូជ។ ផ្នែកទី ២ មានគោលដៅលើកឡើងពីបញ្ហាគុណភាពទឹក និងបង្កើតការគ្រប់គ្រងធនធានទឹកឲ្យមាននិរន្តរភាព តាមរយៈការចូលរួមពីដៃគូពាក់ព័ន្ធក្នុងការគ្រប់គ្រងអាងទន្លេ ការពង្រឹងមូលដ្ឋានចំណេះដឹង និងសមត្ថភាពចំពោះមន្ត្រីថ្នាក់ខេត្ត ដើម្បីគ្រប់គ្រង និងវិភាគធនធានទឹក រួមមានគុណភាពទឹកផងដែរ។ ការអនុវត្តផ្នែកទី ១ សម្រាប់ប្រទេសកម្ពុជានឹងធ្វើឡើងនៅតំបន់រ៉ាំសាក្នុងខេត្តស្ទឹងត្រែង។ ដូចបានលើកឡើងក្នុងចំនុចទី ២ ភូមិចំនួន ២១ ស្ថិតក្នុងតំបន់រ៉ាំសារត្រូវបានកំណត់ជាភូមិគោលដៅសំខាន់។ ការយកចិត្តទុកដាក់ជាពិសេសនឹងត្រូវផ្តល់ដើម្បីធ្វើឲ្យប្រាកដថាសកម្មភាពទាំងអស់ក្នុងតំបន់រ៉ាំសា ដូចជាការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធជនបទ នឹងត្រូវអនុវត្តជាមួយនឹងការយកចិត្តទុកដាក់ខ្ពស់ និងលក្ខណៈសមស្របជាមួយនឹងផែនការគ្រប់គ្រងក្នុងតំបន់នោះ។ សកម្មភាពទាំងឡាយនឹងត្រូវអនុវត្តយ៉ាងជិតស្និទជាមួយនឹងក្រសួងបរិស្ថាន ដែលនឹងទទួលខុសត្រូវសម្រាប់ការគ្រប់គ្រងគម្រោងហើយមូលនិធិសត្វព្រៃពិភពលោក ដែលនឹងផ្តល់នូវការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់តំបន់រ៉ាំសានេះ។ គម្រោងនេះនឹងមិនគ្រាន់តែធ្វើការគាំទ្រការស្តារឡើងវិញនូវផ្លូវថ្មើរជើង ស្ពាន សាលារៀន មន្ទីរពេទ្យដែលមានស្រាប់នោះប៉ុណ្ណោះទេ វាថែមទាំងមានសកម្មភាពផ្សេងៗទៀតដែលស្ថិតក្រោមផែនការគ្រប់គ្រងព្រៀងរបស់តំបន់រ៉ាំសានេះផងដែរ។ ការវិនិយោគដែលដាក់បានដាក់ចេញ ត្រូវតែសម្រេចដោយឃុំពាក់ព័ន្ធ និងត្រូវដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ឃុំ។ គម្រោងនេះនឹងមិនគាំទ្រការ

វិនិយោគដែលមានផលប៉ះពាល់អវិជ្ជមានខ្លាំងទៅលើជម្រកធម្មជាតិដោយផ្ទាល់ ឬដោយប្រយោល នោះទេ។ នៅពេលដែលការវិនិយោគហេដ្ឋារចនាសម្ព័ន្ធជនបទត្រូវបានកំណត់សម្រាប់ភូមិក្នុងចំណោមភូមិទាំង ២១នេះ សំណើ និងកូដបរិស្ថានសម្រាប់អនុវត្តក្នុងតំបន់នេះនឹងត្រូវបញ្ជូនទៅក្រសួងបរិស្ថានដើម្បីធ្វើការពិនិត្យ និងឯកភាពមុនការចាប់ផ្តើមផ្តល់ឲ្យនូវអ្នកម៉ៅការធ្វើការងារនេះ។ រដ្ឋបាលជលផលនឹងរៀបចំរបាយការណ៍រៀងរាល់ត្រីមាស ហើយប្រគល់ទៅធនាគារពិភពលោកដើម្បីធ្វើការពិនិត្យវា។ ក្រសួងបរិស្ថាននឹងផ្ញើអ្នកតំណាងម្នាក់ទៅគណៈកម្មាធិការគ្រប់គ្រងថ្នាក់ជាតិ។ តាមរយៈនេះ គម្រោងនឹងបញ្ជាក់លើការយល់ព្រមពេញលេញជាមួយនឹង OP/BP ៤.០៤ (ជម្រកធម្មជាតិ)។ តំបន់អភិរក្សនៅក្នុងខេត្តគោលដៅផ្សេងៗទៀតស្ថិតនៅក្នុងតំបន់ព្រៃហើយឆ្ងាយពីការវិនិយោគរូបវន្ត (ស្ថានីយ៍ ជលសាស្ត្រ និងឧតុនិយម) ដែលនឹងត្រូវអនុវត្តដោយផ្នែកទី ២។

### ៥.១.៣ ផលប៉ះពាល់បរិស្ថានដែលអាចកើតមានពីសកម្មភាពនៅស្ថានីយ៍ភ្ញាស់កូនត្រី

ការពិនិត្យទៅលើបរិស្ថានមួយត្រូវបានអនុវត្ត និងបានបង្ហាញថា គម្រោងសាងសង់ស្ថានីយ៍ភ្ញាស់កូនត្រីមិនមាននៅក្នុងតំបន់រ៉ាំសានោះទេ (រូបភាពទី ៤)។ ស្ថានីយ៍ភ្ញាស់កូនត្រីកូនត្រីនេះស្ថិតនៅប្រហែល ៧ គីឡូម៉ែត្រពីព្រំប្រទល់តំបន់រ៉ាំសា។ ផលប៉ះពាល់បរិស្ថានដែលអាចកើតមានពីសកម្មភាពប្រតិបត្តិរបស់ស្ថានីយ៍ភ្ញាស់កូនត្រីដែលត្រូវបានគ្រោងទុកក្នុងខេត្តស្ទឹងត្រែង រួមមានដូចជា (ក) ផលប៉ះពាល់ពីទឹកជំនន់ (ខ) កង្វក់ទឹក និងការបង្ហូរកាកសំណល់ពីស្ថានីយ៍ភ្ញាស់កូនត្រី (គ)ការយកភក់ចេញ និង (ឃ) ផលប៉ះពាល់ទៅលើផលស្តុកធម្មជាតិ។ ការវាយតម្លៃបរិស្ថានមួយបានសន្និដ្ឋានថា ផលប៉ះពាល់ទាំង ២ នេះមិនសូវខ្លាំងក្លានោះទេ ហើយអាចត្រូវបានបន្ធូរបន្ថយបានដោយវិធានការទាំងឡាយណាដែលសមស្រប។

- **ទីមួយ** ស្ថានីយ៍ភ្ញាស់កូនត្រី ត្រូវបានធ្វើឡើងដើម្បី ឡើងដើម្បីកែច្នៃទឹកដែលបានប្រើប្រាស់ឡើងវិញក្នុងកម្រិតដែលអាចធ្វើទៅបាននិងកាត់បន្ថយនៃទឹកកខ្វក់។ ការសិក្សាពីលទ្ធភាពបានប៉ាន់ប្រមាណថាទឹកកខ្វក់ប្រចាំឆ្នាំគឺប្រហែល ២៥០ម៉ែត្រគូប ដែលមានតិចជាងមួយភាគបួនពាន់នៃលំហូរប្រចាំឆ្នាំនៃទន្លេសេសាន ដែលទឹកកខ្វក់នេះបានហូរចូលទៅ។ ភាគច្រើនបំផុតនៃការបំពុលទឹកនេះគឺជាសារធាតុសរីរាង្គអាចទាញយកចេញបានដោយស្រះចម្រោះដែលបានបង្កើតឡើងនៅក្នុងស្ថានីយ៍ភ្ញាស់កូនត្រីដែលទឹកកខ្វក់នឹងហូរចូលទៅក្នុងស្រះនោះ មុនបង្ហូរវាទៅក្នុងទន្លេ។ សារធាតុកំណកឬកាកសំណល់នឹងកើនឡើង ហើយស្ថានីយ៍ភ្ញាស់កូនត្រីចាំបាច់ត្រូវតែស្អាតពីមួយពេលទៅមួយពេល (ពាក់កណ្តាលប្រចាំឆ្នាំ) ដោយការសម្អាតរបស់អង្គភាពរបស់រដ្ឋបាលជលផល។ ទោះជាយ៉ាងណា

កម្រិតជាតិកំណកមិនទាន់មានទំហំច្រើននោះទេ (តិចជាង ១ម៉ែត្រគូបក្នុង ១ឆ្នាំ) ហើយវាអាចត្រូវបានយកចេញពីក្នុងតំបន់ដែលបានកំណត់ក្នុងកន្លែងភ្ញាស់កូនត្រីនោះ។ កិច្ចព្រមព្រៀងជាមួយអាជ្ញាធរមូលដ្ឋាន និងប្រជាជនអំពីទីតាំងសម្អាតគឺជាការចំបាច់ មុនពេលការងារផ្សេងៗចាប់ផ្តើម។ ទោះជាយ៉ាងណា វាត្រូវបានគេប្រមើលមើលថាជាតិកំណក នឹងត្រូវស្ងួតនិងត្រូវបានគេប្រើសម្រាប់ផលិតកម្មកសិកម្ម ប្រសិនបើលទ្ធផលជាតិពុលស្ថិតក្នុងដែនកំណត់អាចទទួលយកបានដូចទៅនឹងអ្វីដែលបានអនុវត្តនៅក្នុងប្រទេសថៃ។ គ្មានសារធាតុគីមីណាមួយ (ថ្នាំសំលាប់សត្វល្អិតថ្នាំ ឬសំលាប់ស្មៅ) នឹងត្រូវបានប្រើនៅក្នុងប្រតិបត្តិការស្ថានីយ៍ភ្ញាស់កូនត្រីបានឡើយ។

- **ទីពីរ** ក៏មានការព្រួយបារម្ភជាទូទៅថាស្ថានីយ៍ភ្ញាស់កូនត្រីនឹងមានផលប៉ះពាល់លើប្រភេទត្រីក្នុងស្រុកនោះទេ។ វាគួរតែត្រូវបានកត់សម្គាល់ថា ការភ្ញាស់ត្រីនឹងគាំទ្រតែប្រភេទក្នុងស្រុកដែលមានស្រាប់ មិនមែនសម្រាប់ប្រភេទត្រីក្រៅស្រុកនោះឡើយ។ បន្ថែមពីនេះត្រីពងមេពូជនឹងត្រូវយកចេញជាប្រចាំទៀតទាត់ពីមេពូជត្រីធម្មជាតិ ដូច្នេះវានឹងមិនមានផលប៉ះពាល់ទៅលើហ្សែនទិកនោះទេ។

ផែនការគ្រប់គ្រងបរិស្ថានសាមញ្ញមួយ (EMP) ត្រូវបានរៀបចំសម្រាប់ការសាងសង់និងដំណាក់ការប្រតិបត្តិដើម្បីកំណត់ប៉ារ៉ាម៉ែត្រ និងនីតិវិធីប្រតិបត្តិការនានា និងដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថានដែលអាចកើតមានណាមួយ នេះបើយោងតាមទម្រង់បែបបទដែលបានភ្ជាប់ក្នុងឧបសម្ព័ន្ធទី ២ ។




**រូបភាពទី ៦: ទីតាំងស្ថានីយ៍ភ្ញាស់កូនត្រីក្នុងខេត្តស្ទឹងត្រែង**

## ៥.២. ផលប៉ះពាល់សង្គមដែលអាចកើតមាន និងវិធីសាស្ត្របន្ធូរបន្ថយ

### ៥.២.១. ជនជាតិដើមភាគតិច

ការអនុវត្តសមាសភាគទី ១ នឹងពាក់ព័ន្ធទៅនឹងជនជាតិដើមភាគតិច។ គម្រោងនេះនឹងអនុវត្តតាមគោលការណ៍សំខាន់នៃ គោលនយោបាយប្រតិបត្តិរបស់ធនាគារពិភពលោក ទាក់ទងនឹងជនជាតិដើមភាគតិច (OP/BP ៤.១០) ដែលធ្វើឡើងដើម្បីធានាថា÷ (ក) ដំណើរការពិគ្រោះយោបល់នេះបង្កើតឲ្យមានការពិគ្រោះយោបល់ ដែលត្រូវបានបង្ហាញអត្ថិភាព និងដោយឥតគិតថ្លៃដែលនាំដល់ការគាំទ្រសហគមន៍ទូលំទូលាយ (ខ) ជនជាតិដើមភាគតិចនឹងមិនទទួលផលប៉ះពាល់ជាអវិជ្ជមានក្នុងអំឡុងពេល ដំណើរការអភិវឌ្ឍន៍ និង (គ) ពួកគេ នឹងទទួលបាននូវអត្ថប្រយោជន៍សង្គម និងសេដ្ឋកិច្ចដែលស្របទៅនឹងវប្បធម៌។ ជនជាតិដើមភាគតិចដែលត្រូវបានប្រើសម្រាប់ M-IWRM សម្រាប់កម្ពុជារួម

បញ្ចូលទាំងអ្នកដែលរស់នៅក្នុងខេត្តស្ទឹងត្រែង ក្រចេះ និងខេត្តមណ្ឌលគិរី ហើយអាចរួមបញ្ចូលទាំងជនជាតិ ខ្មែរ ឡាវ កាវែត គួយ វៀតណាម ចិន ព្នង លន់ ប្រៅ គ្រឹង ចាម ទំពួន កាចក់ និងចារាយ។ ក្របខណ្ឌផែនការសម្រាប់ជនជាតិដើមភាគតិច (IPPF) ត្រូវបានរៀបចំជាឯកសារដោយឡែកដើម្បីផ្តល់នូវការណែនាំស្តីពីការរៀបចំផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច (IPDP) រួមទាំងដំណើរការពិគ្រោះយោបល់ និងវិធានការបន្ធូរបន្ថយមួយចំនួន នៅពេលដែលជនជាតិដើមភាគតិចទាំងអស់នោះចូលរួម។ ក្នុងគម្រោងនេះ ផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច (IPDP) នេះនឹងត្រូវបានរៀបចំនៅលើមូលដ្ឋានប្រចាំឆ្នាំមួយ និងនៅកម្រិតថ្នាក់ខេត្ត។

### ៥.២.២. ការសាងសង់លំនៅដ្ឋានឡើងវិញ និងការផ្តល់ដី

គម្រោងនេះនឹងមិនជាប់ពាក់ព័ន្ធទៅនឹងការសាងសង់លំនៅជាថ្មីឡើងវិញ ឬការផ្តល់ដីក្នុងបរិមាណធំនោះទេ ប៉ុន្តែអាចនឹងត្រូវការបរិមាណទំហំដីតូចៗមួយកន្លែងសម្រាប់ធ្វើការស្តារឡើងវិញនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធជនបទសំខាន់ៗ ការស្តារឡើងវិញ/ការសាងសង់ស្ថានីយ៍ភ្នាស់កូនត្រីតូចមួយនៅក្នុងខេត្តស្ទឹងត្រែង និងស្តារ/សាងសង់ស្ថានីយ៍ត្រួតពិនិត្យជលសាស្ត្រ។ ក្របខណ្ឌគោលនយោបាយការសាងសង់លំនៅឡើងវិញមួយ (RPF) ត្រូវបានរៀបចំជាឯកសារដោយឡែកតែឯង ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៅពេលដែលការផ្តល់ដីនោះធ្វើឡើង។ ក្របខណ្ឌគោលនយោបាយការសាងសង់លំនៅឡើងវិញ (RPF) ធ្វើការកំណត់ពីនិយមន័យមនុស្សដែលទទួលរងផលប៉ះពាល់ពីគម្រោង (PAPs) កំណត់ពីសិទ្ធិទទួលបាននិងអំណាច កំណត់ពីអត្ថន័យនៃ ផែនការសកម្មភាពសាងសង់លំនៅឡើងវិញ (RAP) និងកំណត់ពីដំណើរការពិគ្រោះយោបល់ រួមទាំងនីតិវិធីក្នុងការរិះគន់ និងតម្រូវការតាមដាន។ ផែនការសកម្មភាពសាងសង់លំនៅឡើងវិញនេះ ផ្អែកទៅលើព័ត៌មានថ្មីៗ និងអាចជឿជាក់បាន ស្តីអំពី: (ក) វិនិយោគដែលបានស្នើ និងផលប៉ះពាល់ដែលជាប់ទាក់ទងរបស់វា លើប្រជាជនដែលត្រូវជម្លាសចេញ និងក្រុមរងផលប៉ះពាល់ផ្សេងៗទៀត (ខ) បញ្ហាច្បាប់ពាក់ព័ន្ធនឹងសាងសង់លំនៅឡើងវិញ និង (គ) វិធានការបន្ធូរបន្ថយរួមទាំងសំណង ជំនួយ និងការគាំទ្រការសាងសង់លំនៅជាថ្មី។ ក្នុងគម្រោងនេះ ក្របខណ្ឌគោល នយោបាយការសាងសង់លំនៅឡើងវិញ (RAP) នឹងត្រូវបានរៀបចំនៅលើមូលដ្ឋានប្រចាំឆ្នាំមួយនិង នៅកម្រិតថ្នាក់ខេត្ត។ ការឧបត្ថម្ភដីដោយស្ម័គ្រចិត្តនឹងត្រូវអនុញ្ញាត នៅពេលដែលការធ្វើនោះត្រូវនឹងការពិព័ណ៌នានៅក្នុងក្របខណ្ឌគោលនយោបាយការសាងសង់លំនៅឡើងវិញ (RPF)។

### ៥.២.៣. ការដាក់កម្រិតទៅលើការប្រើប្រាស់ធនធាន

ការអនុវត្តនូវការគ្រប់គ្រងវិស័យជលផលក្រោមសមាសភាគទី ១ អាចនឹងដាក់កម្រិតលើការប្រើប្រាស់ធនធាន ជាពិសេសតាមរយៈកិច្ចខិតខំប្រឹងប្រែងដើម្បីពង្រឹងច្បាប់ជាតិឬបទបញ្ញត្តិក្នុងមូលដ្ឋាននៅក្នុងតំបន់ការពារ ឬតំបន់អភិរក្ស។ ភាពពាក់ព័ន្ធនេះត្រូវបានគិតគូក្នុងអំឡុងពេលការរៀបចំគម្រោង និងការផ្តល់នូវសកម្មភាពសាកល្បងជីវភាពរស់នៅខ្នាតតូចមួយចំនួនត្រូវបានរួមបញ្ចូលក្នុងសមាសភាគនេះ។ ក្នុងអំឡុងពេលមុនធ្វើការវាយតម្លៃវិធីសាស្រ្តដូចខាងក្រោមនត្រូវបានទទួលយកជាគោលការណ៍ដោយសហគមន៍មូលដ្ឋាន និងអាជ្ញាធរមូលដ្ឋាន ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិដែលធ្វើចូលរួមធ្វើសកម្មភាពនៅក្នុងតំបន់គម្រោងនេះ:

- ***ទីមួយ*** ការគ្រប់គ្រងធនធានជលផលឲ្យបានល្អប្រសើរនឹងផ្តល់ប្រយោជន៍ដល់សហគមន៍មូលដ្ឋានក្នុងរយៈពេលយូរ ដោយបង្កើតបានការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព។
- ***ទីពីរ*** ផែនការគ្រប់គ្រងធនធានជលផលនឹងត្រូវបានបង្កើតឡើងតាមរយៈការចូលរួមយ៉ាងសកម្មភាព និងភាពជាម្ចាស់របស់សហគមន៍រៀងគ្នា។
- ***និង ទីបី*** គម្រោងនេះក៏រំពឹងទុកជាវិជ្ជមានក្នុងការផ្តល់ជម្រើសការអភិវឌ្ឍជីវភាព (ដែលនឹងត្រូវបានជ្រើសរើសតាមរយៈការធ្វើផែនការចូលរួម ជាមួយប្រជាជនដែលទទួលរងផលប៉ះពាល់) ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានទាំងឡាយដែលអាចកើតមាន។

ទីភ្នាក់ងារអនុវត្តសមាសភាគនេះនឹងបញ្ចប់សកម្មភាពទៅតាមវិធីសាស្រ្តនេះ និងរក្សាឯកសារវីដេអូ និងឯកសាររបាយការណ៍ត្រឹមត្រូវ។ ប្រសិនបើប្រជាជនដែលទទួលរងផលប៉ះពាល់ជាផ្នែកមួយនៃក្រុមជនជាតិភាគតិច ដែលត្រូវបានកំណត់ដោយ OP ៤.១០ ការពិគ្រោះយោបល់នឹងអនុវត្តទៅតាមគោលការណ៍និងដំណើរការដែលបានពណ៌នាក្នុងក្របខណ្ឌផែនការជនជាតិដើមភាគតិច (IPPF) ហើយឯកសារវីដេអូ និងឯកសាររបាយការណ៍បានត្រឹមត្រូវក៏នឹងត្រូវការជាចាំបាច់ផងដែរ។ ការយកចិត្តទុកដាក់ជាពិសេសនឹងត្រូវបានផ្តល់ឱ្យដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានទៅលើស្រ្តី និងក្រុម ដែលមិនទទួលផលផ្សេងៗទៀត។

### ៥.២.៤. យេនឌ័រ (Gender)

ក្នុងអំឡុងពេលនៃការរៀបចំគម្រោង ការយកចិត្តទុកដាក់ក្នុងការលើកទឹកចិត្តស្រ្តីឲ្យដើរតួនាទីយ៉ាងសកម្មនៅក្នុងដំណើរការពិគ្រោះយោបល់នេះ។ ក្នុងអំឡុងពេលនៃការអនុវត្ត ការខិតខំប្រឹងប្រែងនឹងត្រូវ

ធ្វើជាបន្តទៀតដើម្បីធ្វើឲ្យប្រាកដថាស្ត្រីទាំងនោះ (ក) ទទួលបានការប្រឹក្សាយោបល់ ហើយការព្រួយបារម្ភរបស់ពួកគេនឹងត្រូវបានដោះស្រាយ (ខ) ទទួលបានប្រឹក្សាយោបល់ និងបណ្តុះបណ្តាលទៅលើការចិញ្ចឹមជីវិត ដែលនឹងស្តារប្រាក់ចំណូលរបស់ពួកគេ និងធ្វើឲ្យប្រសើរឡើងនូវជីវភាពរបស់ពួកគេ (គ) នឹងត្រូវបានផ្តល់ឱកាសធ្វើជាតំណាងនៅកិច្ចប្រជុំក្រុមសហគមន៍ ការពិភាក្សាក្រុម ផែនការ និងការអនុវត្ត និង(ឃ) ត្រូវធ្វើជាតំណាងស្មើភាពគ្នានៅក្នុងគណៈកម្មាធិការដោះស្រាយការបញ្ហា (GRCs) ។

# ជំពូកទី ៦ : ដំណើរការនៃក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម

## ៦.១ គោលបំណង

គោលបំណងសំខាន់នៃ ក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) គឺដើម្បីធានាថា អនុគម្រោង និងសកម្មភាពនានាដែលត្រូវបានផ្តល់ហិរញ្ញប្បទាននៅក្រោមគម្រោងនេះ នឹងមិនបង្កើតផលប៉ះពាល់អវិជ្ជមានមកលើបរិស្ថានក្នុងតំបន់ និងសហគមន៍មូលដ្ឋាន មិនតែប៉ុណ្ណោះ បញ្ហាកាកសំណល់ និង/ឬ ផលប៉ះពាល់ដែលមិនអាចជៀសវាងបានដទៃទៀតនឹងត្រូវបានកាត់បន្ថយយ៉ាងសមរម្យ ស្របទៅតាមគោលនយោបាយសុវត្ថិភាពរបស់ធនាគារពិភពលោក។ ផ្អែកលើផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន និងវិធានការកាត់បន្ថយផលប៉ះពាល់បានពិពណ៌នានៅក្នុងសមាសភាគទី ៥ ដំណើរការក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) ត្រូវបានរៀបចំឡើងសម្រាប់សកម្មភាពគន្លឹះចំនួនបី: (ក) ការត្រួតពិនិត្យអនុគម្រោង (ខ) ការរៀបចំការអនុវត្ត និង(គ) ការ ទទួលខុសត្រូវរបស់ភ្នាក់ងារពាក់ព័ន្ធ។ ដំណើរការក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (**ESMF**) នេះត្រូវបានរួមបញ្ចូលនៅក្នុងគោលការណ៍នៃនាំប្រតិបត្តិការគម្រោង (POM) ។

### ៦.១.១ការត្រួតពិនិត្យអនុគម្រោង

សម្រាប់អនុគម្រោងដែលបានកំណត់ ដំណើរការត្រួតពិនិត្យនឹងត្រូវអនុវត្តដើម្បីធានាថា គម្រោងនឹងមិនបង្កឲ្យមានផលប៉ះពាល់ផ្នែកសង្គម និង/ឬបរិស្ថាន ណាមួយឡើយ។ បញ្ជីត្រួតពិនិត្យត្រូវបានរៀបរាប់លម្អិតនៅក្នុងឧបសម្ព័ន្ធ ១ នៃក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) នេះ។ បញ្ជីត្រួតពិនិត្យផ្តោតជាបឋមលើ ទីតាំងនៃការវិនិយោគ ថាតើគម្រោងវិនិយោគនេះគ្រោងនឹងអនុវត្តឡើងក្នុងតំបន់រ៉ាំសា ឬតំបន់ការពារធម្មជាតិផ្សេងទៀតឬទេ តើតំបន់នេះមានអាវុធយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ (UXOs) ដែរឬទេ និងផលប៉ះពាល់ដែលអាចកើតមានទៅលើបេតិកភណ្ឌវប្បធម៌ជាដើម។ ដូចមានចែងនៅក្នុងកំណត់សម្គាល់នៅក្នុងបញ្ជីត្រួតពិនិត្យ គ្មានការវិនិយោគថ្មីណាមួយនឹងត្រូវអនុវត្តក្នុងតំបន់ការពារធម្មជាតិ ឬតំបន់ដែលអាចបង្កផលប៉ះពាល់ដល់សម្បត្តិបេតិកភណ្ឌវប្បធម៌ឡើយ។ លើសពីនេះទៀត ក្នុងតំបន់ រ៉ាំសារ មិនអនុញ្ញាតឲ្យមានការវិនិយោគថ្មី។ បញ្ជីត្រួតពិនិត្យក៏នឹងពិនិត្យមើលលើបញ្ហាសង្គម ដូចជាការ តាំងទីលំនៅថ្មីឡើងវិញ ជម្លោះលើកម្មសិទ្ធិដីធ្លី ក៏ដូចជាការប្រែប្រួលអាកាសធាតុ និង

ហានិភ័យគ្រោះមហន្តរាយ ផ្សេងៗទៀតក្នុងការធានាឱ្យបាននូវ និរន្តភាពយូរអង្វែង នៃការវិនិយោគនេះ។

ប្រទេសកម្ពុជាបានទទួលរងនូវការទម្លាក់គ្រាប់បែកដ៏ធ្ងន់ធ្ងរក្នុងអំឡុងសង្គ្រាមឥណ្ឌូចិន ក៏ដូចជាការប្រើប្រាស់អាវុធយុទ្ធភ័ណ្ឌយ៉ាងច្រើន ក្នុងសង្គ្រាមស៊ីវិល ដែលបង្កឲ្យមានហានិភ័យនៃគ្រាប់មិនទាន់ផ្ទុះ។ អាវុធយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះគឺជាឧបសគ្គចម្បងក្នុងការអភិវឌ្ឍកសិកម្ម និងប្រើប្រាស់ដីធ្លី។ ជា ផ្នែកមួយនៃដំណើរការពិគ្រោះយោបល់ជារួម និងដំណើរការត្រួតពិនិត្យបឋម ការវាយតម្លៃយ៉ាងឆាប់រហ័សមួយនឹងត្រូវធ្វើឡើងជាមួយសហគមន៍ផ្ទាល់ ដើម្បីសិក្សាលើអាវុធយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះដែលអាចនៅសេសសល់ទីតាំងរបស់អាវុធទាំងនោះ និងហានិភ័យដែលអាចកើតមាន។ ប្រសិនបើហានិភ័យនៃគ្រាប់មិនទាន់ផ្ទុះនៅមាន បុគ្គលិកគម្រោង នឹងទាក់ទងទីភ្នាក់ងាររដ្ឋាភិបាលដែលទទួលខុសត្រូវក្នុងការបោសសំអាតយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងស្នើឲ្យមានជំនួយក្នុងការរៀបចំផែនការ ដើម្បីសម្អាតយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះទាំងនោះ ហើយការយកគ្រាប់មិនទាន់ផ្ទុះទាំងនោះចេញអាចធ្វើឡើងដោយអង្គភាពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងអនុញ្ញាតដោយរដ្ឋាភិបាលប៉ុននោះ។ បន្ទាប់ពីមានការបោសសំអាតគ្រាប់មិនទាន់ផ្ទុះដោយមានការបញ្ជាក់ពីអង្គភាពខាងលើ ហើយគម្រោងនឹងផ្តល់នូវការគាំទ្រសម្រាប់សកម្មភាពដែលបានស្នើឡើង ។

ទាក់ទងនឹងផែនការសាងសង់ស្ថានីយ៍ភ្ញាស់កូនត្រីដែលបានគ្រោងនៅក្នុងខេត្តស្ទឹងត្រែង ផែនការគ្រប់គ្រងបរិស្ថានសាមញ្ញមួយត្រូវបានរៀបចំឡើងដើម្បីកំណត់ខ្លឹមសារ និងបទបញ្ជាសម្រាប់ប្រតិបត្តិការ (រួមបញ្ចូលទាំងការសំអាត ការយកចេញសារធាតុកណក ប្រភេទសត្វដែលអនុញ្ញាត) ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានលើបរិស្ថាន។ មាតិកា និងសេចក្តីព្រាងនៃផែនការគ្រប់គ្រងបរិស្ថាន (EMP) នេះ ត្រូវបានបញ្ចូលនៅក្នុងឧបសម្ព័ន្ធ ទី ២ នៃក្របខណ្ឌ គ្រប់គ្រងបរិស្ថាន និងសង្គម (ESMF)។

- ទីតាំងស្ថានីយ៍ភ្ញាស់កូនត្រីនៅក្នុងខេត្តស្ទឹងត្រែង និងអគារការិយាល័យនៃខណ្ឌរដ្ឋបាលជលផលខេត្តនេះ ត្រូវបានគេស្គាល់ក្នុងពេលវាយតម្លៃ ប៉ុន្តែទីតាំងពិតប្រាកដ និងវិសាលភាពនៃការងារសម្រាប់ការវិនិយោគខាងក្រោម (អនុគម្រោង) នឹងត្រូវបានកំណត់ក្នុងអំឡុងពេលនៃការអនុវត្តគម្រោង។
- ផ្អែកតាមសមាសភាគ ១-១ ការស្តារឡើងវិញ ឬការសាងសង់ហេដ្ឋារចនាសម្ព័ន្ធថ្មី នៅតាមជនបទនឹងត្រូវអនុវត្ត។ ការជ្រើសរើសសហគមន៍នេសាទគោលដៅនឹងត្រូវអនុវត្តក្នុងអំឡុងពេលអនុវត្ត

គម្រោង។ នៅពេលដែលភូមិគោលដៅត្រូវបានជ្រើសតាមផែនការប្រចាំឆ្នាំ ការពិគ្រោះយោបល់ជាមួយសហគមន៍នេសាទ និងអាជ្ញាធរឃុំ សង្កាត់ដែលពាក់ព័ន្ធនឹងត្រូវធ្វើឡើងដើម្បីកំណត់ថាការវិនិយោគជាអាទិភាពដោយផ្អែកតាមផែនការអភិវឌ្ឍន៍ឃុំសង្កាត់ដែលបានអនុម័ត។

- ផ្អែកតាមសមាសភាគ ២-៣ នឹងមានគម្រោងសាងសង់ ស្ថានីយ៍ជលសាស្ត្រថ្មី ក៏ដូចជាការស្ថាបនាឡើងវិញនៃស្ថានីយ៍ជលសាស្ត្រ និងមាត្រដ្ឋានដែលមានស្រាប់។ ទីតាំងពិតប្រាកដនៃស្ថានីយ៍ជលសាស្ត្រនឹងត្រូវបានកំណត់បន្ទាប់ពីមានការសិក្សាពីលទ្ធភាពចប់សព្វគ្រប់។

### ៦.១.២. ការរៀបចំអនុវត្ត

រដ្ឋបាលជលផល (FiA) និងគណៈកម្មាធិការទន្លេមេគង្គជាតិកម្ពុជា (CNMC) ត្រូវបានចាត់ចែងតួនាទីដឹកនាំលើការងារត្រួតពិនិត្យតាមដាន និងឃ្លាំមើលការអនុវត្តគម្រោងនេះ ព្រមទាំងត្រួតពិនិត្យលើវិធានការណ៍សុវត្ថិភាពនានា និងរបាយការណ៍វឌ្ឍនភាពរបស់គម្រោងឲ្យបានទៀងទាត់។ ក្នុងអំឡុងពេលនៃការអនុវត្តនគម្រោង រដ្ឋបាលជលផល (FiA) និងគណៈកម្មាធិការទន្លេមេគង្គជាតិកម្ពុជា (CNMC) មានតួនាទីទទួលខុសត្រូវក្នុងការធានាថា ការអនុវត្តវិធានសុវត្ថិភាព ប្រកប ដោយប្រសិទ្ធភាព (RAPs ប្រចាំឆ្នាំ IPDPs, EMP / ECOPs) ដោយធ្វើការពិគ្រោះ យោបល់ យ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន និងសហគមន៍មូលដ្ឋាន។ ធនាគារពិភពលោកនឹងធ្វើការត្រួតពិនិត្យ និងឃ្លាំមើលវិធានការណ៍សុវត្ថិភាពជាប្រចាំទាំងនៅកម្រិតគម្រោង និងកម្រិតអនុគម្រោង។

### ៦.១.៣. ការទទួលខុសត្រូវ

រដ្ឋបាលជលផល(FiA) និងគណៈកម្មាធិការទន្លេមេគង្គជាតិ កម្ពុជា (CNMC) មានតួនាទីទទួលខុសត្រូវរួមក្នុងការត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តតាមវិធានការណ៍ការពារសុវត្ថិភាពរបស់គម្រោង និងធ្វើរបាយការណ៍ទៅធនាគារ។ រដ្ឋបាលជលផល (FiA) និងគណៈកម្មាធិការទន្លេមេគង្គជាតិកម្ពុជា (CNMC) ទទួលខុសត្រូវក្នុងការរៀបចំផែនការសកម្មភាពនៃការតាំងលំនៅដ្ឋានឡើងវិញ (RAP) និងផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច(IPDP) ប្រចាំឆ្នាំ និងការផ្តល់វគ្គបណ្តុះបណ្តាលការពារសុវត្ថិភាពសម្រាប់បុគ្គលិក វិស្វករសំណង់ អ្នកពិគ្រោះយោបល់ការត្រួតពិនិត្យការសាងសង់ និងអ្នកម៉ៅការ។ រដ្ឋបាលជលផល (FiA) និងគណៈកម្មាធិការទន្លេមេគង្គជាតិកម្ពុជា (CNMC) ធានាថាអ្នកម៉ៅការគោរពបានតាមផែនការគ្រប់គ្រងបរិស្ថាន (EMP) និងការអនុវត្តកូដនៃបរិស្ថាន (ECOP)។ វិស្វករ និង / ឬ អ្នកពិគ្រោះយោបល់ការត្រួតពិនិត្យការសាងសង់វាលនឹងជួយដ្ឋបាលជលផល(FiA) និងគណៈកម្មាធិការទន្លេមេគង្គជាតិកម្ពុជា (CNMC) ដើម្បីត្រួតពិនិត្យថា តើ អ្នកម៉ៅការគោរពតាមអនុសញ្ញាបរិស្ថានឬទេ។

អាជ្ញាធរមូលដ្ឋាន និងសហគមន៍ត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងកម្មវិធីពិនិត្យតាមដាន។ ពត៌មានលំអិតបន្ថែមទៀតត្រូវបានផ្តល់ឱ្យក្នុងផ្នែកបែងចែកទំនួលខុសត្រូវសម្រាប់អង្គភាព ស្ថាប័ន។

## ៦.២ ការវាយតម្លៃលម្អិត

បន្ទាប់បញ្ចប់ការត្រួតពិនិត្យ,រដ្ឋបាលជលផល (សមាសភាគទី ១) និងគណៈកម្មាធិការទន្លេមេគង្គជាតិកម្ពុជា (សមាសភាគទី ២) នឹងអនុវត្តការវិភាគលម្អិតដើម្បីកំណត់ផលប៉ះពាល់ដែលអាចកើតមានបណ្តាលមកពីការវិនិយោគដែលបានស្នើឡើង ដោយយោងតាមលក្ខណៈវិនិច្ឆ័យដែលបានចែងក្នុងតារាងទី ៤ ខាងក្រោម។

**តារាងទី៤: បញ្ហាសុវត្ថិភាព និងវិធានការត្រូវអនុវត្ត**

| ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន | សកម្មភាពចាំបាច់ដើម្បីកាត់បន្ថយ |
|---|---|
| (១)ការបាត់បង់ដី ឬធនធានផ្សេងៗរបស់គ្រួសារណាមួយអចិន្ត្រៃយ៍ ឬបណ្តោះអាសន្ន រួមទាំងការរិតត្បិតការប្រើប្រាស់ធនធានធម្មជាតិ និង/ឬការបង្កជាឧបសគ្គក្នុងការធ្វើដំណើររបស់មនុស្ស និងសត្វ (រួមបញ្ចូលទាំងសកម្មភាពល្បាត)។ | កំណត់បរិមាណ និងលក្ខណៈនៃដីដែលត្រូវការ ម្ចាស់ដី និង/ឬបញ្ហាផ្សេងទៀត និងរៀបចំផែនការសកម្មភាពសម្រាប់ការតាំងទីលំនៅដ្ឋានឡើងវិញប្រចាំឆ្នាំ (RAP) ដើម្បីផ្តល់សំណង និង/ឬជំនួយស្របទៅតាមក្របខណ្ឌគោលនយោបាយស្តីពីការតាំងទីលំនៅថដ្ឋានឡើងវិញ (RPF) ដូចខាងក្រោម។<br><br>គម្រោងនេះនឹងគាំទ្រដល់ការបង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង លើយន្តការដោះស្រាយសារទុក្ខ និងការកសាងសមត្ថភាពយន្តការដោះស្រាយសារទុក្ខដែលមានស្រាប់ នៅលើបញ្ហាដែលទាមទារ រួមទាំងការដោះស្រាយ ឬការសម្រុះសម្រួលពាក្យបណ្តឹង ការថតទុកជាឯកសារ/រាយការណ៍ និងការត្រួតពិនិត្យដំណោះស្រាយដែលបានស្នើឡើង។ |
| (២)ជម្លោះក្នុងសង្គមដែលអាចកើតមានពីបញ្ហាសិទ្ធកាន់កាប់ និងប្រើប្រាស់ដីធ្លី និង/ឬសិទ្ធិក្នុងការប្រើប្រាស់ទឹក ឬជម្លោះ | ការបង្កើតវិធានការសម្រាប់ការដោះស្រាយជម្លោះតាមរយៈការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយអ្នកពាក់ព័ន្ធ និងដាក់បញ្ចូលទៅក្នុងដំណើរការគម្រោង តាមសហគមន៍ និង |

| | |
|---|---|
| ដែលពាក់ព័ន្ធផ្សេងៗទៀត។ | គ្រប់គ្រងរួមគ្នាដោយរាប់បញ្ចូលទាំងអ្នកសម្របសម្រួលមកពីភាគីទី៣ឬភាគីខាងក្រៅ។ បង្កើតកិច្ចព្រមព្រៀងស្តីពីការប្រើប្រាស់ធនធានភូមិ។ ការប្រើប្រាស់យន្តការគ្រប់គ្រងជម្លោះតាមមូលដ្ឋានដែលមានស្រាប់ ដូចជាការសម្របសម្រួលរបស់ចាស់ព្រឹទ្ធាចារ្យក្នុងភូមិ ឬមេកន្ទ្រាញក្រុមជនជាតិភាគតិចដើម ។ |
| (៣)អាចនឹងបង្កផលប៉ះពាល់អវិជ្ជមានដល់ជនជាតិដើមភាគតិច | អនុវត្តដំណើរការវាយតម្លៃសង្គម តាមរយៈការពិគ្រោះយោបល់ដោយឥតគិតថ្លៃ និងបានប្រាប់ជាមុន។ រៀបចំជាផែនការអភិវឌ្ឍសម្រាប់ជនជាតិដើមភាគតិច(IPDP) ប្រចាំឆ្នាំ ស្របតាមការណែនាំនៅក្នុងក្របខណ្ឌផែនការសម្រាប់ជនជាតិដើមភាគតិច (IPPF) ។<br><br>គម្រោងនេះ នឹងគាំទ្រដល់ការបង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីគម្រោង ជាភាសាផ្សេងៗនៃក្រុមជនជាតិដើមភាគតិច អំពីយន្តការដោះស្រាយសារទុក្ខ និងការកសាងសមត្ថភាពនៃអ្នកដែលចូលរួមនៅក្នុងយន្តការដោះស្រាយសារទុក្ខដែលមានស្រាប់លើបញ្ហាដែលទាមទាររួមទាំងការដោះស្រាយ ឬសម្រុះសម្រួលពាក្យបណ្តឹងពីបុគ្គល ឬក្រុមជនជាតិដើមភាគតិច ការថតទុកជាឯកសារ/សេចក្តីរាយការណ៍ និងការត្រួតពិនិត្យដំណោះស្រាយដែលបានស្នើឡើង។ |
| (៤)សកម្មភាពវិនិយោគអាចបណ្តាលឱ្យមានផលប៉ះពាល់អវិជ្ជមានដូចជាការបំពុលខ្យល់ និងទឹក ការរំខានដោយសម្លេង សំណឹកដី និងបញ្ហាសុខភាពមនុស្ស ផលប៉ះពាល់លើជីវកធម្មជាតិ និងសម្បត្តិវប្បធម៌ ហានិភ័យនៃយុទ្ធភ័ណ្ឌ | បង្កើតការពិនិត្យតាមរយៈកម្មវិធីនៅក្នុងបញ្ជីត្រួតពិនិត្យ REA( សូមមើលឧបសម្ព័ន្ធទី១)។<br><br>អនុវត្តនូវបច្ចេកទេសវិស្វកម្មត្រឹមត្រូវ និងកូដបរិស្ថានសម្រាប់ការអនុវត្ត ( សូមមើលឧបសម្ព័ន្ធទី ៣ និង ៤) និងការបង្កើតនូវផែនការគ្រប់គ្រងបរិស្ថាន EMP សម្រាប់ការ |

| | |
|---|---|
| មិនទាន់ផ្ទុះ ការអនុវត្តសកម្មភាពក្នុងតំបន់អភិរក្សវ៉ាំសា។ | សាងសង់ស្ថានីយ៍ភ្ញាស់កូនត្រីថ្មី (សូមមើលឧបសម្ព័ន្ធទី២) ក្រោមការត្រួតពិនិត្យ និងឃ្លាំមើលយ៉ាងជិតស្និទ្ធដោយផ្នែកគ្រប់គ្រងសមាសភាគ CMUs និងអាជ្ញាធរមូលដ្ឋាន និងសហគមន៍ ពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន និងសហគមន៍ ដើម្បីដោះស្រាយបញ្ហាដែលទាក់ទងនឹងការវាយតម្លៃបរិស្ថានក្នុងលក្ខណៈទាន់ពេលវេលា។<br><br>នៅក្នុងករណីមានហានិភ័យយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ សូមទាក់ទងភ្នាក់ងារទទួលបន្ទុក រួមគ្នារៀបចំផែនការបោសសំអាតយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការបញ្ចប់ការបោសសំអាតស្របតាមផែនការមុនពេលអនុវត្តសកម្មភាពគម្រោង។<br><br>អភិវឌ្ឍនូវគោលការណ៍ណែនាំ ដើម្បីបង្កើតវិធានការបន្ធូរបន្ថយការបំផ្លិចបំផ្លាញជីវកធម្មជាតិនិងសម្បត្តិវប្បធម៌។ អនុវត្តយ៉ាងតឹងរ៉ឹងតាមផែនការគ្រប់គ្រងតំបន់វ៉ាំសា និងពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយក្រសួងបរិស្ថាន និងអង្គការមូលនិធិសត្វព្រៃពិភពលោក (WWF) ។ |
| (៥)កាលានុវត្តភាពដើម្បីលើកកំពស់គុណប្រយោជន៍ផ្នែកបរិស្ថាន និងដោះស្រាយបញ្ហាបរិស្ថានតាមរយៈកិច្ចពិភាក្សាឆ្លងព្រំដែន. | នៅក្រោមសមាសភាគទី ១ នៃ M-IWRMP ១ (សូមមើលតារាងទី១) គឺមានសកម្មភាពក្នុងការគាំទ្រកិច្ចពិភាក្សាឆ្លងព្រំដែន ដែលរៀបចំដោយគណៈកម្មាធិការទន្លេមេគង្គ។ ការគ្រប់គ្រងធនធានជលផល និងការគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ (IWRM) នៅក្នុងតំបន់ស៣ ត្រូវបានគេកំណត់ថាជាប្រធានបទគន្លឹះនៅក្នុងសមាសភាគនេះ។ |

ជាទីបញ្ចប់ លំហូរដែលបានរៀបរាប់ខាងលើនេះត្រូវបានសង្ខេបនៅក្នុងរូបភាពទី ៧ ខាងក្រោម។




**រូបទី៧: តារាងលំហូរដំណើរការត្រួតពិនិត្យ**

## ជំពូកទី ៧ : ការផ្សព្វផ្សាយព័ត៌មាន និងការប្រឹក្សាជាសាធារណៈ

ដំណើរការនៃការអភិវឌ្ឍ គម្រោងដែលបានស្នើឡើងនេះ ត្រូវបានផ្អែកលើការពិគ្រោះយោបល់ទូលំទូលាយជាមួយអ្នកពាក់ព័ន្ធនានា ដែលចម្បងគឺជាមួយរដ្ឋាភិបាលមូលដ្ឋាន និងអ្នកភូមិ ។ ស៊េរីនៃការពិគ្រោះយោបល់មួយបានធ្វើឡើងនៅក្នុងខេត្ត ក្រចេះ និង ខេត្តស្ទឹងត្រែង ចាប់តាំងពីខែមករាឆ្នាំ ២០១០ ភ្ជាប់ជាមួយការរៀបចំរបស់គម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គដំណាក់កាលទី១ (M-IWRMP ១) ដើម្បីបញ្ជាក់ពីការចាប់អារម្មណ៍ និងការគាំទ្ររបស់សហគមន៍ទៅលើគម្រោងនេះ និងដើម្បីទទួលយកទស្សនៈរបស់ពួកគេសម្រាប់ការរៀបចំគម្រោងនេះ។ ការពិគ្រោះយោបល់ជាសាធារណៈបន្ថែមផ្សេងៗទៀតបានធ្វើឡើងកាលពីដើមឆ្នាំ ២០១១ ដើម្បីបង្ហាញសកម្មភាពដែលបានគ្រោងទុកនៅក្រោមសមាសភាគទី ១ និងឯកសារការពារសុវត្ថិភាពដែលបានស្នើឡើង។ កិច្ចពិគ្រោះយោបល់តាមដានជាសាធារណៈជាមួយដៃគូពាក់ព័ន្ធ ត្រូវបានអនុវត្តដោយគណៈកម្មការទន្លេមេគង្គជាតិកម្ពុជា (CNMC) និងរដ្ឋបាលជលផល (FiA) នៅដើមខែធ្នូ ឆ្នាំ ២០១៣ នៅខេត្តក្រចេះដើម្បីជូនដំណឹងដល់ពួកគេពីសកម្មភាពរបស់គម្រោងទាំងមូល ក៏ដូចជាផលប៉ះពាល់សង្គមនិងបរិស្ថានរួមទាំងផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានដែលអាចកើតមានឡើង ក៏ដូចជាវិធានការដើម្បីបង្កើនគុណប្រយោជន៍ដល់សង្គមនិងបរិស្ថាន និងជៀសវាង/កាត់បន្ថយ/សំណងទៅលើផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានទៅលើសង្គមនិងបរិស្ថាន។ ការពិគ្រោះយោបល់ជាសាធារណៈបានបញ្ជាក់ពីការគាំទ្រយ៉ាងទូលំទូលាយសម្រាប់គម្រោងនេះ ហើយយោបល់ទាំងអស់ និងការស្នើសុំពីដៃគូពាក់ព័ន្ធសំខាន់ៗត្រូវបានដាក់បញ្ចូលទៅក្នុងការរៀបចំក្របខណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) ក្របខណ្ឌគោលនយោបាយនៃការតាំងលំនៅដ្ឋានឡើងវិញ (RPF) និងក្របខណ្ឌផែនការជនជាតិដើមភាគតិច (IPPF) (សូមមើលឧបសម្ព័ន្ធទី៤ និងទី៥)

នៅថ្ងៃទី ៣-៤ ខែធ្នូ ឆ្នាំ ២០១៣ សិក្ខាសាលាមួយត្រូវបានធ្វើឡើងដោយមានដៃគូពាក់ព័ន្ធសំខាន់ៗទាំងអស់ចូលរួម រួមទាំងតំណាងមកពីសហគមន៍នេសាទចំនួន២០ដែលបានជ្រើសរើស មន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ខេត្តដែលជាប់ពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិង អង្គការអន្តរជាតិ (រួមទាំងតំណាងមកពីអង្គការ WWF) ដែលពួកគេទាំងអស់បច្ចុប្បន្នកំពុងធ្វើការលើវិស័យជលផល ហើយលើការគ្រប់គ្រងធនធានទឹកនៅក្នុងខេត្តគោលដៅគម្រោង។ គោលបំណងសំខាន់នៃសិក្ខាសាលានេះរួមមាន: ការបញ្ជាក់ឡើងវិញនូវឯកសារស្តីពីសុវត្ថិភាពសង្គម និងបរិស្ថានដែលបានរៀបចំកាលពីឆ្នាំ

២០១០ ការពិភាក្សាអំពីការផ្លាស់ប្តូរដែលអាចកើតមានពីឆ្នាំ ២០១០ ដល់ឆ្នាំ ២០១៣ នៅក្នុងសហគមន៍នេសាទគោលដៅនៅក្នុងខេត្តស្ទឹងត្រែងនិងខេត្តក្រចេះ និងណែនាំពីសមាសភាគទី២ ស្តីពីការគ្រប់គ្រងអាងទន្លេនៅតំបន់អាងរង សព និង ព៤។

សិក្ខាសាលាប្រឹក្សាយោបល់ ស្តីពីការរៀបចំសម្រាប់គម្រោងនេះនឹងត្រូវធ្វើឡើងនៅចុងខែមីនា ឆ្នាំ ២០១៤ នៅខេត្តក្រចេះ។ លទ្ធផលចំនួនបីត្រូវបានគេរំពឹងពីសិក្ខាសាលានេះ : (ក) CSOs និងសហគមន៍នេសាទ យល់ដឹងអំពីគោលបំណងរបស់គម្រោងនេះ (ខ) ការរៀនមេរៀន ( ភាពជោគជ័យនិងភាពបរាជ័យ) នៃសហគមន៍ជលផល ឬការគ្រប់គ្រងធនធានទឹកចម្រុះ និង (គ) គំនិតលើរបៀបទ្រទ្រង់ សហគមន៍នេសាទ ឬការគ្រប់គ្រងធនធានទឹកចម្រុះដែលបានប្រមូល។

ជាទំនាក់ទំនងទៅនឹងក្របខណ្ឌគោលនយោបាយជនជាតិដើមភាគតិច ( IPPF) និងក្របខណ្ឌគោលនយោបាយនៃការតាំងលំនៅដ្ឋានឡើងវិញ (RPF) មានការព្រួយបារម្ភមួយចំនួន ដែលបានលើកឡើងដោយអ្នកចូលរួមមានដូចជា: (ក) ការស្ទង់មតិពេញលេញមួយត្រូវធ្វើឡើងនៅគ្រប់ភូមិទាំងអស់ ដើម្បីធានាថាបញ្ហាទាំងឡាយរបស់ក្រុមងាយរងគ្រោះត្រូវបានទទួលយកមកដោះស្រាយ ជាពិសេសក្នុងអំឡុងពេលដំណើរការបង្កើតឡើងវិញនូវសហគមន៍នេសាទ (ខ) ហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចនៅតាមជនបទ ក្នុងសហគមន៍នេសាទគោលដៅនឹងធ្វើឱ្យមានផលប៉ះពាល់អវិជ្ជមានទៅលើអ្នកភូមិប្រសិនបើមានផលប៉ះពាល់ទៅលើទ្រព្យសម្បត្តិឯកជន វាចាំបាច់ត្រូវមានការពិភាក្សាលើបញ្ហានេះជាមួយទីភ្នាក់ងារពាក់ព័ន្ធ និងផ្តល់សំណងដល់គ្រួសាររងផលប៉ះពាល់ប្រសិនបើចាំបាច់ (គ) វប្បធម៌នៃជនជាតិគួយគួរតែត្រូវបាន និង (ឃ) ជម្រើសនានាសម្រាប់បម្រើជីវភាពគួរតែត្រូវបានផ្តល់ឱ្យរួមទាំងការគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ។

ពត៌មានដែលទទួលបានពីការប្រមូលទិន្នន័យបន្ទាប់បន្សំ និងធាតុចូលនានាដែលបានប្រមូលពី កិច្ចប្រជុំពិគ្រោះយោបល់នេះបានផ្តល់នូវទិន្នន័យដ៏មានតម្លៃដែលអាចផ្តល់នូវយោបល់ត្រឡប់ចំពោះការរៀបចំគម្រោង។ ជាពិសេសខ្លឹមសារនៃក្របខណ្ឌគោលនយោបាយជនជាតិដើមភាគតិច (IPPF) និងក្របខណ្ឌគោលនយោបាយនៃការតាំងលំនៅដ្ឋានឡើងវិញ (RPF) ត្រូវបានធ្វើឲ្យប្រសើរឡើងជាមួយនឹងគំនិត និងទស្សនៈវិស័យដែលបានចែករំលែកដោយអ្នកចូលរួម។ វិធានការកាត់បន្ថយទៅលើផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន ដូចដែលអ្នកចូលរួមបានលើកឡើង ក៏អាចត្រូវយកមកពិចារណាផងដែរ។ ឧទាហរណ៍ដើម្បីជាការណែនាំចំពោះការទិញដី និងការបន្ធូរបន្ថយការដាក់កម្រិតរាំងការប្រើ

ប្រាស់ធនធាន RPF ដែលផ្តល់នូវដំណើរការ និងគោលការណ៍ណែនាំបច្ចេកទេស នៅពេលដែលការទិញដី និង/ឬការដាក់កម្រិតលើការប្រើប្រាស់ធនធានពាក់ព័ន្ធអាចនឹងទទួលបានអត្ថប្រយោជន៍ពីព័ត៌មានដែលបានចែកចាយរំលែកដោយអ្នកចូលរួមទាំងអស់នេះ។ ពួកគេបានស្នើថាគួរតែមានការប្រព្រឹត្តឱ្យបានត្រឹមត្រូវនៃការវាយតម្លៃនូវផលប៉ះពាល់សង្គម និងបរិស្ថាននៅក្នុងតំបន់គោលដៅនៅក្នុងខេត្ត ទាំងបួន។ អ្នកពាក់ព័ន្ធទាំងអស់ទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ថ្នាក់សហគមន៍គួរតែចូលរួម និងត្រូវបានជូនដំណឹង។ រចនាសម្ព័ន្ធដ៏ត្រឹមត្រូវមួយត្រូវតែបង្កើតឡើងដើម្បីអនុវត្តគម្រោងឱ្យមានប្រសិទ្ធភាព។ លើសពីនេះទៀត ការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំដែលអនុវត្តតាមផែនការមេរបស់គម្រោងនឹងមានអត្ថប្រយោជន៍ច្រើន។ គម្រោងនេះអាចធ្វើការរៀបចំកិច្ចប្រជុំប្រចាំឆ្នាំទៀងទាត់ដើម្បីឆ្លុះបញ្ចាំងពីបញ្ហាប្រឈមថ្មី និងវាយតម្លៃអ្វីដែលសម្រេចបានក្នុងអំឡុងពេលនៃការអនុវត្តគម្រោង។ ការរៀបចំគម្រោងនេះត្រូវតែរួមបញ្ចូលទាំងការកសាងសមត្ថភាពមន្ត្រីបុគ្គលិកគម្រោង សហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធដទៃទៀត។ ទន្ទឹមនឹងនេះផងដែរការធ្វើសវនកម្មឯករាជ្យអាចផ្តល់ការវាយតម្លៃប្រកបដោយភាពជឿជាក់ នៃការរីកចម្រើនរបស់គម្រោង។

ក្របខណ្ឌគោលនយោបាយជនជាតិដើមភាគតិច នេះបានផ្តល់អត្ថប្រយោជន៍ផងដែរពីលទ្ធផលនៃការពិភាក្សា ដែលជាកន្លែងដ៏មានសារៈសំខាន់នៃ ភាសា វប្បធម៌ និងរបៀបរស់នៅរបស់ជនជាតិដើមភាគតិចដែលត្រូវបានលើកឡើង។ អ្នកចូលរួមបានចង្អុលបង្ហាញថាក្រុមជនជាតិម្ចាស់ស្រុកផ្សេងៗគ្នាចែករំលែករបៀបនៃការរស់នៅតាមបែបប្រពៃណី ដែលអាចជួយកាត់បន្ថយផលប៉ះពាល់ដែលអាចកើតមានលើវប្បធម៌របស់ពួកគេប្រសិនបើមាន។

រាល់ឯកសារការពារសុវត្ថិភាពទាំងអស់ដែលបានរៀបចំក្នុងអំឡុងពេលអនុវត្តគម្រោង ក៏នឹងត្រូវធ្វើការបង្ហាញជាភាសាខ្មែរ ហើយនឹងត្រូវបញ្ជ្រាបដល់ប្រជាពលរដ្ឋដែលងាយរងផលប៉ះពាល់ ស្របទៅតាមគោលនយោបាយរបស់ធនាគារពិភពលោកស្តីពីសិទ្ធិទទួលបានព័ត៌មាន មុនពេលចាប់ផ្តើមសកម្មភាពរបស់អនុគម្រោង ឬការងារ ។

## ជំពូកទី ៨ : ការបែងចែកទំនួលខុសត្រូវនៅតាមអង្គភាព ស្ថាប័ន

ក្នុងអំឡុងពេលនៃការអនុវត្តគម្រោង ការគ្រប់គ្រងការការពារបរិស្ថាននិងសង្គមរបស់គម្រោងនេះនឹងត្រូវអនុវត្តស្របតាមក្របខណ្ឌគ្រប់គ្រងសង្គម និងបរិស្ថាន (ESMF) និងឯកសារសុវត្ថិភាពសង្គមដែលពាក់ព័ន្ធ។ ដើម្បីធានាការអនុវត្តល្អនូវគោលនយោបាយពាក់ព័ន្ធ តួនាទី និងការទទួលខុសត្រូវរបស់ភ្នាក់ងារពាក់ព័ន្ធ តម្រូវការសម្រាប់ការបណ្តុះបណ្តាល យន្តការសម្រាប់ការតាមដាន និងរាយការណ៍ ការបង្កើតកម្មវិធីទំនាក់ទំនង និងយន្តការដោះស្រាយសារទុក្ខនឹងត្រូវបានលើកឡើងនៅក្នុងអំឡុងពេលនៃការរៀបចំគម្រោង។ តួនាទី និងការទទួលខុសត្រូវរបស់អង្គភាពសម្រាប់ការអនុវត្តគោលនយោបាយសុវត្ថិភាពសង្គមត្រូវបានផ្តល់ឱ្យនូវឧបករណ៍សុវត្ថិភាពសង្គមដូចជាក្របខណ្ឌគោលនយោបាយនៃការតាំងលំនៅដ្ឋានឡើងវិញ (RPF) និងក្របខណ្ឌផែនការជនជាតិដើមភាគតិច (IPPF) ។

### ៨.១. ទំនួលខុសត្រូវ

ការទទួលខុសត្រូវរួម អនុលោមតាមក្របខណ្ឌគ្រប់គ្រងសង្គម និងបរិស្ថាន (ESMF) ជាការងារទទួលខុសត្រូវរបស់ទីភ្នាក់ងារប្រតិបត្តិ (CNMC) តែទោះជាយ៉ាងណា ការអនុវត្តសម្រាប់សមាសភាគទី១ នឹងត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលជលផល (FiA)។ រដ្ឋបាលជលផល និងគណៈកម្មការទន្លេមេគង្គជាតិកម្ពុជានឹងជ្រើសរើសអ្នកសម្របសម្រួលសុវត្ថិភាពដាច់ដោយឡែក ដើម្បីក្លាយជាមនុស្សគោលសំខាន់សម្រាប់សមាសភាគនីមួយៗ។ អ្នកសម្របសម្រួលទាំងនេះនឹងទទួលខុសត្រូវចំពោះការអនុវត្តប្រភេទនៃការការពារសុវត្ថិភាព ជាមួយនឹងការពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន សហគមន៍នេសាទ និងអង្គការមិនមែនរដ្ឋាភិបាល។

ជាផ្នែកមួយនៃការធ្វើរបាយការណ៍តាមកាលកំណត់ ព័ត៌មានអនុលោមតាមច្បាប់ការការពារសុវត្ថិភាពនឹងត្រូវចងក្រងដោយគណៈកម្មការទន្លេមេគង្គជាតិកម្ពុជា (CNMC) ដែលនឹងដាក់ជូនរបាយការណ៍នេះទៅឱ្យធនាគារនិង ក្រសួងបរិស្ថាន។ ព័ត៌មានទាក់ទងនឹងវិធានសុវត្ថិភាណ និងការអនុវត្តគួរតែអាចរកបានដល់សាធារណជន។ ធនាគារពិភពលោកនឹងអនុវត្តជាទៀងទាត់លើការត្រួតពិនិត្យ និងរៀបចំការការពារសុវត្ថិភាពដែលជាធម្មតាធ្វើឡើងជារៀងរាល់ប្រាំមួយខែម្តង។

រដ្ឋបាលជលផល (FiA) និងគណៈកម្មការទន្លេមេគង្គជាតិកម្ពុជា (CNMC) នឹងចូលរួមធ្វើការងារជាមួយសហគមន៍មូលដ្ឋាន ជាពិសេសជាមួយនឹងប្រជាជនដែលរងផលប៉ះពាល់ដែលត្រូវបានលើក

ទឹកចិត្តឱ្យចូលរួមក្នុងការត្រួតពិនិត្យ និងរៀបចំចំពោះការអនុវត្តគម្រោងនេះ តាមដែលអាចធ្វើទៅបាន។ ព័ត៌មានលំអិតមានផ្តល់នៅក្នុងតារាងទី ៥ ។

**តារាងទី ៥: ទំនួលខុសត្រូវសម្រាប់ការអនុវត្តសុវត្ថិភាពបរិស្ថាន**

| សហគមន៍/ភ្នាក់ងារ | ទំនួលខុសត្រូវ |
|---|---|
| FiA និង CNMC | - FiA និង CNMC នឹងបង្កើត CMUs ដើម្បីគ្រប់គ្រងសមាសភាគនានា។ CMUs នឹងបង្កើតអង្គភាពផ្នែកបរិស្ថាន និងសង្គម (ESU) ទទួលខុសត្រូវចំពោះការពង្រឹងការអនុវត្តឱ្យមានប្រសិទ្ធិភាព និងទាន់ពេលវេលានូវសកម្មភាពសុវត្ថិភាពនិងផ្តល់បុគ្គលិកជាន់ខ្ពស់ម្នាក់ និងបុគ្គលិកសុវត្ថិភាពពេញម៉ោងយ៉ាងហោចណាស់មួយនាក់ទទួលខុសត្រូវចំពោះការគ្រប់គ្រង និងការត្រួតពិនិត្យលើផលប៉ះពាល់បរិស្ថាន និងសង្គមនៃអនុគម្រោងដែលមាននៅក្នុងការអនុវត្តគម្រោងនេះ។ ការទទួលខុសត្រូវចម្បងរបស់ ESU នឹងដាក់បញ្ចូល ប៉ុន្តែមិនត្រូវបានកំណត់ចំពោះ: (ក) ពង្រឹងការអនុលោមតាមច្បាប់ រួមទាំងការរៀបចំនិងត្រួតពិនិត្យបរិស្ថាន និងទិដ្ឋភាពសង្គមទាំងអស់និង (ខ) ថាជាអ្នកទទួលខុសត្រូវចំពោះការសម្របសម្រួលទាំងមូលនៅក្នុងការអនុវត្តអនុគម្រោង ដូចជា RAP IPDP EMP/ECOP ។<br>- អ្នកសម្របសម្រួលសុវត្ថិភាពអាចត្រូវបានជួលដោយ CMUs ដើម្បីជួយ ESU ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។ ព័ត៌មានទាក់ទងនឹងវិធានការសុវត្ថិភាពនិងការអនុវត្តគួរតែត្រូវបានបង្ហាញជាទៀងទាត់ដល់សាធារណជន។ |
| CSC និង/ឬ អ្នកជំនាញ | - ជួយដល់អ្នកកាន់ការអនុវត្តអនុគម្រោង ក្នុងការត្រួតពិនិត្យប្រចាំលើការអនុវត្តរបស់អ្នកទទួលម៉ៅការធ្វើ ស្របនឹងសេចក្តីអនុវត្តន៍បរិស្ថាន រួមទាំងការរាយការណ៍និងការរក្សាបាននូវការសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន និងសហគមន៍។ |
| អ្នកទទួលម៉ៅការ | - ទទួលខុសត្រូវអនុវត្តសកម្មភាពដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានទាំងអស់ដែលអាចកើតមាន ស្របនឹងគោលបំណងដែលបានពិព័ណ៌នានៅក្នុង ECOP និង/ឬផែនការគ្រប់គ្រងបរិស្ថាន (EMP) ។ |

| | |
|---|---|
| | - ទំនាក់ទំនងយ៉ាងសកម្មជាមួយអ្នករស់នៅក្នុងតំបន់ និងចាត់វិធានការដើម្បីការពារការរំខានក្នុងអំឡុងពេលសាងសង់។<br>- ធានាថាបុគ្គលិក និងកម្មករទាំងអស់បានយល់ពីនីតិវិធី និងភារកិច្ចរបស់ពួកគេនៅក្នុងកម្មវិធីគ្រប់គ្រងបរិស្ថាន។<br>- រាយការណ៍ទៅអ្នកគ្រប់គ្រងអនុគម្រោង ពីផលលំបាកណាមួយនិងដំណោះស្រាយរបស់ពួកវា។<br>- រាយការណ៍ទៅអាជ្ញាធរមូលដ្ឋាន និងអ្នកគ្រប់គ្រងអនុគម្រោង ប្រសិនបើគ្រោះថ្នាក់ពីបរិស្ថានកើតមានឡើង និងធ្វើការសម្របសម្រួលជាមួយភ្នាក់ងារ និងអ្នកពាក់ព័ន្ធសំខាន់ៗដើម្បីដោះស្រាយបញ្ហាទាំងនេះ។ |
| អាជ្ញាធរមូលដ្ឋាន និងសហគមន៍ | - ចូលរួមក្នុងដំណើរការនៃការរៀបចំអនុគម្រោង ហើយនឹងធានាបានថាទស្សនៈរបស់ពួកគេត្រូវបានយកមកពិចារណា។<br>- ត្រួតពិនិត្យសកម្មភាពអ្នកម៉ៅការនៅក្នុងលក្ខខណ្ឌនៃការអនុលោមតាមច្បាប់គោលនយោបាយសុវត្ថិភាព។<br>- រាយការណ៍ពីបញ្ហាទៅកាន់ CSC/អ្នកជំនាញ |

## ៨.២. ការបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាព

បណ្តុះបណ្តាលស្តីពីគោលការណ៍សុវត្ថិភាព និងឧបករណ៍មួយចំនួនដូចជាក្របខណ្ឌគោលនយោបាយនៃការតាំងលំនៅដ្ឋានឡើងវិញ (RPF) ក្របខណ្ឌផែនការជនជាតិដើមភាគតិច (IPPF) ក្របខណ្ឌគ្រប់គ្រងសង្គម និងបរិស្ថាន (ESMF) និងសៀវភៅប្រតិបត្តិការគម្រោងនឹងត្រូវបានផ្តល់ទៅឱ្យបុគ្គលិកគម្រោង និងអាជ្ញាធរមូលដ្ឋានក្នុងអំឡុងពេលនៃការអនុវត្តគម្រោង។ នេះគឺដើម្បីធានាថា: (ក) សកម្មភាពគម្រោងដែលបានស្នើត្រូវបានបង្ហាញយ៉ាងត្រឹមត្រូវតាមរយៈការក្របខណ្ឌគ្រប់គ្រងសង្គម និងបរិស្ថាននេះ (ខ) ការអនុវត្តបច្ចេកទេសវិស្វកម្មត្រឹមត្រូវ និង កូដបរិស្ថានសម្រាប់ការអនុវត្តត្រូវបានដាក់បញ្ចូលទៅក្នុងឯកសារដេញថ្លៃ និងកិច្ចសន្យា ហើយការត្រួតពិនិត្យ និងមើលការខុសត្រូវទៅលើការអនុវត្តរបស់អ្នកម៉ៅការត្រូវបានធ្វើឡើងដោយទីប្រឹក្សាត្រួតពិនិត្យ និង (គ) ការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយភ្នាក់ងារក្នុងតំបន់ និងសហគមន៍ត្រូវបានអនុវត្តនៅក្នុងការធ្វើផែនការ និងអនុវត្តគម្រោង។ គម្រោងនេះនឹងផ្តល់នូវការបណ្តុះបណ្តាលស្តីពីសុវត្ថិភាពទៅកាន់ភ្នាក់ងារអនុវត្ត និងការបណ្តុះបណ្តាលយ៉ាងហោចណាស់មួយនៅពេលចាប់ផ្តើម និងការបណ្តុះបណ្តាលមួយ/នៅឆ្នាំបន្ត

បន្ទាប់។ ថវិកាសរុបចំនួន ៨០,០០០ដុល្លារសហរដ្ឋអាមេរិកត្រូវបានយកចេញពីថវិការបស់សមាសភាគទី១ និងទី២ ដើម្បីគាំទ្រដល់ការបណ្តុះបណ្តាលសុវត្ថិភាពនេះ។ ខាងក្រោមគឺជាវគ្គបណ្តុះបណ្តាលដែលបានស្នើឡើងដែលនឹងត្រូវបានធ្វើឡើងមុនពេល និងក្នុងកំឡុងពេលការអនុវត្តគម្រោង :

- ***បណ្តុះបណ្តាលស្តីពីការវាយតម្លៃបរិស្ថាននិងសង្គម ការពិនិត្យ និងគ្រប់គ្រង***
  អ្នកពាក់ព័ន្ធត្រូវការនូវសមាសធាតុចូលលើការកសាងសមត្ថភាព ដើម្បីជួយឱ្យពួកគេយល់ដឹងអំពីហានិភ័យសង្គមដែលបានភ្ជាប់ទៅនឹងការវិនិយោគផ្សេងៗគ្នា និងវិធានការបន្ធូរបន្ថយសម្រាប់បរិស្ថាន និងសង្គមដ៏សមរម្យមួយដែលអាចត្រូវបានយកមកប្រើដើម្បីកាត់បន្ថយផលប៉ះពាល់លើតំបន់សហគមន៍គោលដៅ និងតំបន់ជិតខាងនានា។ លើសពីនេះទៀត ពួកគេក៏នឹងត្រូវការឱ្យមានការបណ្តុះបណ្តាលដើម្បីឱ្យពួកគេមានជំនាញដើម្បីវាយតម្លៃអនុគម្រោងលើលក្ខណៈវិនិច្ឆ័យបរិស្ថាននិងសង្គមសំខាន់ៗ និងធានាបានថាពួកគេទទួលបាននូវបរិស្ថាននិងសង្គមល្អមួយដោយផ្អែកលើក្របខណ្ឌគ្រប់គ្រងសង្គម និងបរិស្ថាន (ESMF) ដែលលើកទឹកចិត្តក្នុងការរៀបចំផែនការត្រួតពិនិត្យ និងការគ្រប់គ្រងដ៏រឹងមាំនោះ។

- ***ការបណ្តុះបណ្តាលស្តីពីការពិគ្រោះយោបល់ និងការស្ទង់មតិ***គឺមានសារៈសំខាន់ណាស់ដូចនេះអ្នកទាំងអស់នឹងយល់ពីសារៈសំខាន់នៅក្នុងដំណើរការនានា ដែលពាក់ព័ន្ធទៅនឹងការចូលរួមរបស់សហគមន៍ ការប្រមូលផ្តុំសហគមន៍ ការធ្វើជំរឿន ការស្ទាបស្ទង់ទិន្នន័យមូលដ្ឋាន ។ល។ ការបណ្តុះបណ្តាលស្តីពីដំណើរការពិគ្រោះយោបល់សម្រាប់គម្រោងតូចៗ និងបទពិសោធន៍ចំពោះវិធិសាស្រ្តនៃការពិគ្រោះយោបល់ អាចនឹងផ្តល់ដោយអ្នកពិគ្រោះយោបល់នោះ។ ការបណ្តុះបណ្តាលគួរតែផ្តោតលើការបង្កើនការចូលរួម និងតម្លាភាពក្នុងការធ្វើផែនការ និងការអនុវត្តគម្រោង។

- ***ការបណ្តុះបណ្តាលស្តីពីគោលនយោបាយសុវត្ថិភាព ការសាងសង់លំនៅដ្ឋានឡើងវិញ និងការស្តារឡើងវិញ÷*** តម្រូវការដ៏សំខាន់មួយផ្សេងទៀតគឺលើកឡើងពីបញ្ហាសុវត្ថិភាពបរិស្ថាន និងសង្គមក្នុងអំឡុងពេលអនុវត្តគម្រោង។ អ្នកពាក់ព័ន្ធ ជាពិសេសអ្នកដែលគ្រប់គ្រងការអនុវត្តនៅថ្នាក់ខេត្តនេះ ចាំបាច់ត្រូវធ្វើការកសាងសមត្ថភាពទាក់ទិននឹងរឿងនេះ។ នេះអាចរួមបញ្ចូលទាំងព័ត៌មានស្តីពីច្បាប់ដែលពាក់ព័ន្ធនឹងច្បាប់ និងបទបញ្ញត្តិ

គោលនយោបាយជាតិផ្នែកការពារសុវត្ថិភាពរបស់ប្រទេស និងធនាគារពិភពលោក វិធីសាស្ត្រនៃការអនុវត្ត ការវាយតម្លៃទ្រព្យសកម្ម ការដោះស្រាយសារទុក្ខ ការរៀបចំ និងអនុវត្តផែនការ ខ្លីៗក្នុងការគ្រប់គ្រងបរិស្ថាន (SEMP) ផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច (IPDP) និងផែនការសកម្មភាពនៃការតាំងលំនៅដ្ឋានឡើងវិញ (RAP) ដែលអាចត្រូវការជាចាំបាច់ក្នុងអំឡុងពេលការធ្វើផែនការ និងអនុវត្តគម្រោង។

- ***ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពសម្រាប់ការបង្កើនការយល់ដឹងអំពីយេនឌ័រ និងការចូលរួម÷*** សកម្មភាពការកសាងសមត្ថភាពនឹងត្រូវបានផ្តល់ដល់ភាគីពាក់ព័ន្ធ ដើម្បីបង្កើនការយល់ដឹងអំពីយេនឌ័រ និងការគាំទ្រដល់ការបញ្ជ្រាបយេនឌ័រនៅក្នុងសកម្មភាពគម្រោង។ ការបណ្តុះបណ្តាលដើម្បីគាំទ្រដល់ស្ត្រីជាសមាជិកនៃគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (VDCs) នឹងត្រូវបានផ្តល់ជូនពួកគាត់។ ជាមួយគ្នានេះផងដែរ កិច្ចប្រជុំ និងសកម្មភាពមួយចំនួននឹងត្រូវបានបែងចែកយេនឌ័រ ដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមនៃក្រុមទាំងអស់នៅក្នុងសកម្មភាពគម្រោង និងបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងការសម្រេចចិត្តនៅក្នុងភូមិ។

## ៨.៣. យុទ្ធសាស្ត្រនៃការធ្វើទំនាក់ទំនង

គម្រោងនេះត្រូវបានបង្កើតឡើងដើម្បីលើកកម្ពស់ និងពង្រឹងដល់សហគមន៍នេសាទកនៅតាមភូមិ (CFi) និងដើម្បីគាំទ្រដល់ការគ្រប់គ្រងអាងទន្លេឱ្យប្រសើរឡើងជាមួយនឹងការចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗ។ ដើម្បីបំពេញ និងទាញយកឲ្យបាននូវ អត្ថប្រយោជន៍ពីសក្តានុពលនៃគម្រោងនេះ យុទ្ធសាស្ត្រនៃការធ្វើទំនាក់ទំនងដូចខាងក្រោមនេះដែលផ្តោតលើការចូលរួមដោយផ្ទាល់និងការប្រាស្រ័យទាក់ទងទៅវិញទៅមកនឹងត្រូវបានគេបង្កើតឡើង។ ថវិកាសរុបចំនួន ៦០,០០០ ដុល្លារអាមេរិកត្រូវបានបម្រុងទុកដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រទំនាក់ទំនងនៅក្នុងគម្រោងនេះ។

- សម្រាប់សមាសភាគទី ១ ទំនាក់ទំនងជាមួយនឹងសហគមន៍នេសាត (CFis) នេះនឹងត្រូវបានធ្វើឡើងនៅក្នុងលក្ខខណ្ឌនៃសិក្ខាសាលាប្រចាំឆ្នាំ ដែលនឹងត្រូវធ្វើនៅក្នុងខេត្តក្រចេះនិងខេត្តស្ទឹងត្រែង។ សហគមន៍នេសាទជាង ១១០ ត្រូវបានបង្កើតឡើងជាច្រើនឆ្នាំកន្លងមកហើយនៅក្នុងខេត្តទាំងនេះ ប៉ុន្តែការខ្វះការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីរដ្ឋាភិបាលកម្ពុជាដែលបានធ្វើឱ្យមានការលំបាកដល់សហគមន៍ក្រីក្រ ដើម្បីរក្សាបាននូវកិច្ចប្រឹងប្រែងវិជ្ជមានទាំងនេះ។ សហគមន៍នេសាទ (CFis) ក៏នឹងទទួលបានផលប្រយោជន៍ មិនត្រឹមតែបានពីការគាំទ្រដោយ

ផ្ទាល់ (ហេដ្ឋារចនាសម្ព័ន្ធជនបទ សកម្មភាពចិញ្ចឹមជីវិត ការរៀបចំបទបញ្ញត្តិ)នោះទេ ប៉ុន្តែក៏ទទួលបាននូវសកម្មភាពភ្ញាស់ត្រី ការស្រាវជ្រាវ និងបណ្តុះបណ្តាលផងដែរ។

- សម្រាប់សមាសភាគទី ២ ការគ្រប់គ្រងអាងទន្លេឱ្យប្រសើរឡើងនឹងរួមបញ្ចូលសិក្ខាសាលាសម្រាប់អ្នកពាក់ព័ន្ធ ដែលនឹងធ្វើការផ្សព្វផ្សាយលទ្ធផលនៃគម្រោងនេះ និងទទួលយកការផ្តល់យោបល់ត្រឡប់ពីភាគីពាក់ព័ន្ធទាក់ទងទៅនឹងបញ្ហាសំខាន់នឹងធនធានទឹកនៅក្នុងលក្ខខណ្ឌនៃទិដ្ឋភាពសង្គម និងបរិស្ថាន។ សិក្ខាសាលានេះក៏នឹងគាំទ្រចំពោះសម្លេងរបស់អ្នកពាក់ព័ន្ធក្នុងមូលដ្ឋានក្នុងការសម្រេចចិត្តលើការធ្វើផែនការធនធានទឹកដែលមានឥទ្ធិពលដល់ជីវភាពរស់នៅលើរបស់ពួកគេផងដែរ។

លើសពីនេះទៀតវិធីសាស្រ្តនៃការផ្សាយវិទ្យុរបស់ឃុំ/ស្រុក ទូរទស្សន៍ និងជាពិសេសខិត្តប័ណ្ណជាភាសាខ្មែរនឹងត្រូវដាក់អនុវត្តដើម្បីឱ្យទៅដល់តំបន់ដាច់ស្រយាល ជាពិសេសជាកន្លែងដែលមានកម្រិតទទួលបាននូវសិក្ខាសាលានេះ។

## ឧបសម្ព័ន្ធទី ១. បញ្ជីវាយតម្លៃលើបរិស្ថាន

| សំណួរ | បាទ/ចាស៎ | ទេ | យោបល់ |
|---|---|---|---|
| **ក. ការកំណត់ទីតាំងអនុគម្រោង តើតំបន់អនុគម្រោងស្ថិតនៅក្បែរ ឬស្ថិតនៅក្នុងរង្វង់តំបន់ដែលមានការយកចិត្តទុកដាក់ខ្ពស់ពីបរិស្ថានដែរឬទេ?** | | | |
| តំបន់កេរ្តិ៍ដំណែលវប្បធម៌ | | | គ្មានការវិនិយោគមួយណានឹងធ្វើបានឡើយ ដែលធ្វើឲ្យប៉ះពាល់តំបន់កេរ្តិ៍ដំណែលវប្បធម៌ រួមមានប្រាសាទ និងដីកប់ខ្មោចជាដើម។ |
| តំបន់អភិរក្ស | | | គ្មានការសាងសង់ថ្មីណាមួយនឹងទទួលបានការអនុញ្ញាតឡើយ នៅក្នុងតំបន់រុំសា។ |
| តំបន់ដីសើមក្បែរៗ | | | |
| តំបន់បម្រុងនៃតំបន់ការពារ | | | |
| តំបន់ពិសេសសម្រាប់ការពារជីវចម្រុះ | | | គ្មានការវិនិយោគថ្មីណាមួយនឹងត្រូវបានធ្វើឡើងនៅក្នុងតំបន់ការពារនេះឡើយ។ |
| តើអនុគម្រោងនេះ នឹងពាក់ព័ន្ធទៅនឹង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះដែរឬទេ? | | | ប្រសិនបើមាន សូមភ្ជាប់នូវឈ្មោះអង្គភាពដែលមានសមត្ថកិច្ចសម្រាប់ការធ្វើការស៊ើបអង្កេតបន្ថែម។ |

| សំណួរ | បាទ/ចាស៎ | ទេ | យោបល់ |
|---|---|---|---|
| **ខ. ផលប៉ះពាល់បរិស្ថានដែលអាចកើតមាន តើគម្រោងនឹងបង្កឲ្យ....** | | | |
| សម្លេងពីឧបករណ៍សាងសង់ឬទេ? | | | |
| ធូលីក្នុងពេលសាងសង់ឬទេ? | | | |
| ខ្យោយខាងអនាម័យ និងការចោលនូវសំណល់រឹង នៅក្នុងការដ្ឋាន និងជុំវិញនៅកន្លែងសាងសង់ ហើយចម្លងជម្ងឺទៅប្រជាជនក្នុងតំបន់នោះឬទេ? | | | |
| ការបង្កើតនូវជម្រកបង្កាត់ពូជបណ្តោះអាសន្ននៃជម្ងឺដូចជាបង្កឡើងដោយសត្វមូស ឬសត្វកណ្តុរ ឬទេ? | | | |
| ហានិភ័យគ្រោះថ្នាក់ ដែលពាក់ព័ន្ធទៅនឹងចរាចរគ្រឿងចក្រកើនឡើង ដែលនាំដល់ការធ្លាយនូវសារធាតុពុលឬទេ? | | | |
| ការកើនឡើងនូវសំណឹកដី និងដីល្បាប់ភក់ឬទេ? | | | |
| ការកើនឡើងនូវហានិភ័យដោយសារតែការស្តារ ឬសាងសង់ទំនប់ឬទេ? | | | |
| ការកើនឡើងនូវលំហូរទឹកជំនន់ និងជន់ខ្ពស់ឬទេ? | | | |
| បាត់បង់ការអាស្រ័យផលផ្នែកខាងក្រោម (ការផ្គត់ផ្គង់ជលផល និងទឹក) ដែរឬទេ។ | | | |
| ការថយចុះនូវឱកាសសម្រាប់អេកូឡូហ្ស៊ី និងសម្រាប់ការកំសាន្តឬទេ។ | | | |
| ការថយចុះនូវការអាស្រ័យផលពីព្រៃឈើតាមប្រពៃណីដែរឬទេ។ | | | |

| សំណួរ | បាទ/ចាស៎ | ទេ | យោបល់ |
|---|---|---|---|
| មានការបាត់បង់អេកូឡូហ្ស៊ីណាមួយពីមុនដែរឬទេ។ | | | |
| ការប៉ះទង្គិចដែលអាចកើតមានជាមួយនឹងគោលនយោបាយគ្រប់គ្រងដែលបានបង្កើតឡើងឬទេ? | | | |
| ការផ្លាស់ប្តូរកន្លែង ឬការសាងសង់លំនៅដ្ឋានឡើងវិញដោយបង្ខំដែរឬទេ? | | | គ្មានការវិនិយោគណាមួយនឹងត្រូវធ្វើឡើយលើការសាងសង់លំនៅដ្ឋានឡើងវិញដោយបង្ខំឡើយ។ |
| ការបាត់បង់នូវតួនាទីផ្នែកសេដ្ឋកិច្ច និងអេកូឡូហ្ស៊ីដោយសារតែការសាងសង់ហេដ្ឋារចនាសម្ព័ន្ធច្រើន (ឧ. ផ្លូវ មជ្ឈមណ្ឌលបណ្តុះបណ្តាល ឬពំតិមានការិយាល័យ ឬ លំនៅស្ថាន) ដែរឬទេ? | | | |
| ការផ្លាស់ទីលំនៅរបស់មនុស្ស ឬកាត់បន្ថយការទទួលបាននូវធនធានព្រៃឈើដែរឬទេ? | | | |
| ផលប៉ះពាល់វិសមាមាត្រទៅលើប្រជាជនក្រីក្រ ស្ត្រី និងកុមារ ប្រជាជនម្ចាស់ស្រុក និងក្រុមងាយរងគ្រោះដែរឬទេ? | | | |
| ការចំណាកស្រុកចូលដោយគ្មានការគ្រប់គ្រងត្រឹមត្រូវ រួមមានការហូរចូលនូវកម្មករ និងសាច់ញាតិរបស់ពួកគេ ជាមួយនឹងការចូលទៅក្នុងតំបន់ព្រៃឈើ និងការសង់ហេដ្ឋារចនាសម្ព័ន្ធសង្គមច្រើនលើសលុបដែរឬទេ? | | | |

| សំណួរ | បាទ/ចាស៎ | ទេ | យោបល់ |
|---|---|---|---|
| ការខាតបង់ដែលមិនចាំបាច់នូវតម្លៃអេកូឡូស៊ី និងជីវចម្រុះដោយការជំនួសព្រៃឈើធម្មជាតិ ដោយចំការដែលកម្រិតដល់ចំនួនសត្វមួយចំនួន ដែរឬទេ?។ | | | |
| ការកែសម្រួលបច្ចេកវិទ្យា ឬការប្រើប្រាស់ដី ដែលអាចនឹងធ្វើឱ្យប្រែប្រួលដល់សកម្មភាពសង្គម និងសេដ្ឋកិច្ចនាពេលបច្ចុប្បន្ននេះដែរឬទេ? | | | |
| បញ្ហាអេកូឡូហ្ស៊ី ក៏ដូចជាសុខភាពសហគមន៍ និងគ្រោះថ្នាក់នានាដោយសារតែការសម្អាតដីមុនធ្វើការដាំព្រៃឈើឡើងវិញ (ឧ. សំណឹកដី បញ្ហាវដ្តទឹក ការបាត់បង់សារធាតុចិញ្ចឹមក្នុងដី និងសារធាតុជីខនិករបស់ដី) ដែរឬទេ? | | | |
| បញ្ហាអេកូឡូហ្ស៊ីដទៃផ្សេងទៀត ក៏ដូចជាសុខភាពសហគមន៍ និងគ្រោះថ្នាក់ផ្នែកសុវត្ថិភាព (ឧ. បំពុលទឹកពីជីគីមី ថ្នាំសម្លាប់សត្វល្អិត និងថ្នាំសម្លាប់ស្មៅដែលបានប្រើក្នុងចំការ)ដែរឬទេ? | | | |
| គ្រោះថ្នាក់ទៅលើសុវត្ថិភាព និងសុខភាពបរិស្ថានការងារ ដោយសារតែគ្រោះថ្នាក់ពីសារធាតុជីវសាស្ត្រ គីមី និងរោគក្នុងអំឡុងពេលសាងសង់ និងប្រតិបត្តិការរបស់គម្រោងដែរឬទេ? | | | |
| បញ្ហាសង្គម និងការប៉ះទង្គិចនានាពាក់ព័ន្ធទៅនឹងសិទ្ធិកាន់កាប់ដីធ្លី និងអាស្រ័យផលធនធានដែរឬទេ? | | | |

| សំណួរ | បាទ/ចាស៎ | ទេ | យោបល់ |
|---|---|---|---|
| ការប៉ះទង្គិចសង្គម ប្រសិនបើកម្មករមកពីតំបន់ខុសៗគ្នា ឬប្រទេសផ្សេងៗគ្នាត្រូវបានជួលដែរឬទេ? | | | |
| ហានិភ័យចំពោះសុខភាព និងសុវត្ថិភាពសហគមន៍ ដោយសារតែការដឹកជញ្ជូន ស្តុក និងការចោលកាកសំណល់នូវសម្ភារៈ ដូចជាគ្រឿងផ្ទុះ ឥន្ធនៈ ថ្នាំសម្លាប់សត្វល្អិត និងសារធាតុគីមីផ្សេងៗ ក្នុងអំឡុងពេលនៃការសាងសង់ និងប្រតិបត្តិដែរឬទេ? | | | |
| **គ. សំណួរពីបម្រែបម្រួលអាកាសធាតុ និងហានិភ័យគ្រោះធម្មជាតិ។** | | | |
| តើតំបន់គម្រោងជាប្រធានបទសម្រាប់គ្រោះថ្នាក់ ដូចជារញ្ជួយដី ទឹកជំនន់ បាក់ដី ព្យុះស៊ីក្លូន ព្យុះជំនន់ បន្ទុះភ្នំភ្លើងឬស៊ូណាមី និងបម្រែបម្រួលអាកាសធាតុដែរឬទេ? | | | |
| តើការប្រែប្រួលក្នុងរបបទឹកភ្លៀង, សីតុណ្ហភាព, ជាតិប្រៃក្នុងទឹក ឬហេតុការណ៍ខ្លាំង ទៅលើអាយុគម្រោងអាចនឹងប៉ះពាល់ដល់និរន្តភាព ឬការចំណាយរបស់ខ្លួនវាដែរឬទេ? | | | |
| តើមានទិដ្ឋភាពប្រជាសាស្ត្រ ឬសេដ្ឋកិច្ចសង្គមណាមួយនៃតំបន់គម្រោងដែលទទួលការរងគ្រោះរួចហើយ( ឧ.វិសាលភាពខ្ពស់នៃអត្រាប្រជាជន ដែលបាត់បង់ឱកាស ចំណាកស្រុកតំបន់ជនបទនិងទីក្រុង ការតាំងទីលំនៅខុសច្បាប់ ជនជាតិភាគតិច ស្ត្រីឬកុមារ) ដែរឬទេ? | | | |

| សំណួរ | បាទ/ចាស៎ | ទេ | យោបល់ |
|---|---|---|---|
| តើគម្រោងបង្កើនសក្តានុពលនៃភាពងាយរងគ្រោះគ្រោះមហន្តរាយ ឬអាកាសធាតុទៅលើតំបន់ជុំវិញនោះ (ឧទាហរណ៍ការបង្កើនចរាចរឬលំនៅដ្ឋាននៅក្នុងតំបន់ដែលនឹងងាយនឹងគ្រោះទឹកជំនន់ ដោយលើកទឹកចិត្តការតាំងទីលំនៅនៅក្នុងតំបន់រញ្ជួយដី) ដែរឬទេ? | | | |

# ឧបសម្ព័ន្ធទី ២÷ គ្រោងការណ៍នៃផែនការគ្រប់គ្រងបរិស្ថានសម្រាប់អនុគម្រោង ស្ថានីយ៍ភ្ញាស់កូនត្រី

១. ការពិពណ៌នាពីអនុគម្រោង - ផ្តល់ព័ត៌មានសង្ខេប ប៉ុន្តែច្បាស់លាស់ស្តីពីអនុគម្រោង (ឧ. ឈ្មោះអនុគម្រោង ទីតាំងអនុវត្ត ម្ចាស់គម្រោង កាលវិភាគសាងសង់ និងប្លង់)។

២. ផលប៉ះពាល់ដែលអាចកើតមាន និងវិធានការបន្ធូរបន្ថយ - ផ្តល់នូវលទ្ធផលនៃការត្រួតពិនិត្យសុវត្ថិភាពស្របទៅតាមលក្ខណៈវិនិច្ឆ័យនៅក្នុងក្របខណ្ឌគ្រប់គ្រងសង្គម និងបរិស្ថាន (ESMF) កំណត់ផលប៉ះពាល់ដែលអាចកើតមាន (វិជ្ជមាន និងអវិជ្ជមាន) និងវិធានការកាត់បន្ថយផលប៉ះពាល់ទាំងនេះគួរតែត្រូវបានពណ៌នាមុនពេលសាងសង់ និងតាមដំណាក់កាលសាងសង់ដោយប្រើនូវតារាងម៉ាទ្រីសអាចជួយឲ្យយើងស្វែងយល់ពីទំនាក់ទំនងរវាងផលប៉ះពាល់ និងវិធានការកាត់បន្ថយផលប៉ះពាល់ប្រសើរជាងមុន។

៣. ការត្រួតពិនិត្យ - ការត្រួតពិនិត្យផ្នែកបរិស្ថានក្នុងអំឡុងពេលអនុវត្តអនុគម្រោង ផ្តល់នូវព័ត៌មានអំពីទិដ្ឋភាពគន្លឹះផ្នែកបរិស្ថាននៃអនុគម្រោង ជាពិសេសផលប៉ះពាល់បរិស្ថានដែលកើតចេញពីអនុគម្រោង និងប្រសិទ្ធិភាពនៃវិធានការកាត់បន្ថយផលប៉ះពាល់។ ការត្រួតពិនិត្យផ្តល់នូវ (ក) ការពិពណ៌នាច្បាស់លាស់ និងមានលក្ខណៈបច្ចេកទេសពីវិធានការត្រួតពិនិត្យ រួមទាំងប៉ារ៉ាម៉ែត្រដែលត្រូវវាស់វែង វិធីសាស្ត្រដែលត្រូវប្រើ ទីតាំងគំរូ ប្រេកង់នៃការវាស់វែង ដែនកំណត់នៃការរកឃើញ និងការកំណត់នូវកម្រិតប្រកាសអាសន្នដែលតម្រូវឲ្យមានការកែប្រែសកម្មភាព និង (ខ) នីតិវិធីក្នុងការត្រួតពិនិត្យ និងរាយការណ៍ ដើម្បី (១) ធានាថាវិធានការសម្រាប់កាត់បន្ថយផលប៉ះពាល់ស្របទៅតាមលក្ខខណ្ឌជាក់ស្តែង និង (២) ផ្តល់ព័ត៌មានស្តីពីវឌ្ឍនភាព និងលទ្ធផលនៃការកាត់បន្ថយផលប៉ះពាល់។

៤. ការរៀបចំអនុវត្តន៍ - ពន្យល់ទីភ្នាក់ងារទទួលខុសត្រូវ (អំពីសមត្ថភាពរបស់ពួកគេក្នុងការអនុវត្តសកម្មភាពដែលបានកំណត់នៅក្នុងផែនការគ្រប់គ្រងបរិស្ថាន (EMP) និងតម្រូវការសម្រាប់ការបណ្តុះបណ្តាល) កាលវិភាគសម្រាប់អនុវត្តន៍ ការប៉ាន់ប្រមាណចំណាយ និងរបៀបដែលផែនការគ្រប់គ្រងបរិស្ថាន (EMP) នឹងត្រូវដាក់បញ្ចូលទៅក្នុងអនុគម្រោងនេះ។

៥. ការផ្សព្វផ្សាយព័ត៌មាន និងការពិគ្រោះយោបល់- ផ្តល់នូវសេចក្តីសង្ខេបអំពីសកម្មភាពពិគ្រោះយោបល់ និងអ្នកពាក់ព័ន្ធនឹងផែនការគ្រប់គ្រងបរិស្ថាន (អាចដាក់បញ្ចូលគ្នាជាមួយគោលនយោបាយ

ស្ដីពីការតាំងទីលំនៅដ្ឋានឡើងវិញ ) និងការព្រួយបារម្ភដែលលើកឡើង និងការឆ្លើយតប។ ទីតាំង និងកាលបរិច្ឆេទនៃផែនការគ្រប់គ្រងបរិស្ថាន (EMP) គួរតែត្រូវបង្ហាញ។

# ឧបសម្ព័ន្ធទី ៣. ការអនុវត្តបច្ចេកទេសវិស្វកម្មត្រឹមត្រូវ

## ការអនុវត្តបច្ចេកទេសវិស្វកម្ម និងការរក្សាបានត្រឹមត្រូវ

ការអនុវត្តបច្ចេកទេសក្នុងការថែរក្សាជាប់ពាក់ព័ន្ធទៅនឹងការរក្សាទុក ការប្រើប្រាស់ ការសម្អាត និងការបញ្ចេញចោលនូវសម្ភារៈបានត្រឹមត្រូវ ក្នុងអំឡុងពេលនៃការរៀបចំឲ្យមានសុវត្ថិភាពសម្រាប់មនុស្ស និងបរិស្ថាន។

ការអនុវត្តថែរក្សាត្រឹមត្រូវខាងក្រោមនេះគឺចាំបាច់សម្រាប់សកម្មភាពទាំងអស់ក្នុងការគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គដំណាក់កាលទី៣ (M-IWRM-3):

**គួរធ្វើ:**

១. ចំនួនម៉ោងការងារមានកំនត់ក្នុងពេលថ្ងៃ ជាពិសេសក្នុងតំបន់ដែលមានប្រជាជនរស់នៅ ហើយធ្វើការគ្រប់គ្រងទៅលើល្បឿនក្នុងការបើកបរ។

២. បន្ថយនូវការជីកដី ហើយនឹងការចោលកាកសំណល់អោយបានត្រឹមត្រូវ

៣. កាត់បន្ថយជាអប្បបរមាទៅលើការជីកដើម្បីយកដីទៅប្រើប្រាស់ ហើយធ្វើការបិទតំបន់នោះឲ្យបានត្រឹងត្រូវ។

៤. កាត់បន្ថយជាអប្បបរមាលើការកកស្ទះចរាចរណ៍ ធូលី និងសម្លេង

៥. ការថែរក្សាសម្ភារៈសំណង់ និងគ្រឿងចក្របានត្រឹមត្រូវ

៦. ផ្តល់នូវសញ្ញាសុវត្ថិភាពត្រឹមត្រូវ (ពេលថ្ងៃ និងពេលយប់) ហើយជូនដំណឹងដល់អ្នកភូមិ

៧. បញ្ចៀសការបង្ហូរប្រេងដែលប្រើរួច និងសម្ភាៈពុលទាំងឡាយ ហើយធ្វើការរក្សាទុក និងដឹកជញ្ជូនដោយសុវត្ថិភាព។

៨. ដាក់ចេញនូវការថែរក្សាបានត្រឹមត្រូវនៅក្នុងការដ្ឋានសំណង់ និងកន្លែងឃ្លាំងរក្សាទុក ដើម្បីធានាបានសុវត្ថិភាពដល់កម្មករ និងប្រជាជន (ប្រមូលផ្តុំ និងកំទេចកំទីនានា ដើម្បីរក្សាការដ្ឋានការងារនេះប្រកបដោយសណ្តាប់ធ្នាប់ និងមានសុវត្ថិភាព ផែនការ និងអនុវត្តការបោះចោលកាកសំណល់ សំណល់ និងសម្ភារៈលើសរក្សាកន្លែងធ្វើការ និងសម្ភារៈទាំងអស់មានសណ្តាប់ធ្នាប់។ បង្កើតតំបន់សម្រាប់ដាក់កាកសំណល់ និងផ្តល់ធុង ឱ្យជណ្តើរ ច្រកដើរ និងសម្ភារៈផ្គត់ផ្គង់ និងរបាំងដោយឥតគិតថ្លៃ បំពាក់សម្ភារៈរលុងឬស្រាលលើដំបូលផ្ទះ ឬផ្លូវដើរ រក្សាទុកសម្ភារៈយ៉ាងហោចណាស់ ២ ម៉ែត្រ (៥ ហ្វីត) ពីផ្លូវដើរចូលពីគែមដំបូល រណ្តៅ ឬលេណដ្ឋាន; ដកចេញ ឬពត់ដែកគោលពីឈើអារ ថែរក្សាបំពង់ខ្យល់ថាមពល ខ្សែភ្លើងអគ្គិសនី ជាដើម ឲ្យឆ្ងាយពីផ្លូវសម្រាប់ដឹករបស់ធ្ងន់ៗ ធានាបានថាផ្លូវចូលត្រូវបាន

គ្រប និងការពារត្រឹមត្រូវ ផ្តល់ឧបករណ៍ពន្លត់អគ្គិភ័យ។ កន្លែងទុកឧបករណ៍ពន្លត់អគ្គិសនីត្រូវតែស្អាត និងងាយប្រើប្រាស់ជាដើម)

៩. ធានាឲ្យបានការទទួលបាននូវទឹក និងបង្គន់ស្អាតដល់កម្មករ និងផ្តល់មុង

១០. បញ្ចៀសនូវការប៉ះទង្គិចផ្នែកវប្បធម៌ និងសង្គម រវាងកម្មករ និងប្រជាជនក្នុងតំបន់នោះ

**មិនគួរធ្វើ:**

១. កុំធ្វើឲ្យសម្រាមនៅពាសវាលពាសកាលពីតំបន់គម្រោងនេះ ហើយកុំឲ្យមានសត្វ (ជ្រូក ឆ្មារ ឆ្កែ) ចូលឲ្យសោះ។ សូមប្រើប្រាស់ធុងសម្រាមសមស្រប។

២. កុំបោះចោលឧបករណ៍ ឬសម្ភារៈផ្សេងៗ

៣. សូមកុំលើក ឬដាក់ចុះនូវឧបករណ៍ ឬសម្ភារៈណាមួយដោយប្រើខ្សែ ឬបំពង់របស់វា

៤. បំពាក់នូវខ្សែដីជាមួយឧបករណ៍គៀបនៅលើធុងដើម្បីជៀសវាងការកើតមានអគ្គិសនីធម្មជាតិដោយចៃដន្យ។

៥. កុំអនុញ្ញាតឲ្យមានការបរបាញ់សត្វដោយកម្មករនៅក្នុងតំបន់អភិរក្ស

**ការកត់សម្គាល់សំខាន់ៗសម្រាប់សម្ភារៈដែលងាយឆេះ និងផ្ទុះ**

រក្សាទុកសម្ភារៈដែលងាយឆេះ និងផ្ទុះ ដូចជាសាំង ប្រេង និងសម្ភារៈសំអាត ឲ្យនៅឆ្ងាយពីសម្ភារៈដទៃទៀត។

១. រក្សាសម្ភារៈងាយឆេះ និងផ្ទុះ នៅក្នុងធុងត្រឹមត្រូវ ជាមួយនឹងការបិទព័ត៌មាន (ស្លាកសញ្ញា) អោយបានច្បាស់លាស់។

២. រៀបចំសារធាតុឆេះ ប្រេង ក្រណាត់ និងសម្ភារៈងាយឆេះក្នុងធុងត្រឹមត្រូវ

៣. ទុកធុងដែលមានសារធាតុឆេះពេញឲ្យនៅទីតាំងខ្ពស់

៤. ទុកធុងដែលទទេឲ្យនៅដាច់ចេញពីគេដោយឡែក

៥. ដាក់នូវសញ្ញាហាមឃាត់ការជក់បារី ការប្រើប្រាស់ឧបករណ៍បង្កើតភ្លើង នៅក្នុងតំបន់ដែលមានសម្ភារៈងាយឆេះដែលតាំងនៅទីនោះឡើយ។

៦. ទុក និងចងនូវបំពង់ហ្គាសនៅទីតាំងខ្ពស់

៧. ធ្វើកំណត់សម្គាល់ទៅលើបំពង់ហ្គាសទទេ និងទុកពួកវាឲ្យដាច់ដោយឡែកពីបំពង់ហ្គាសដែលពេញ ឬមិនទាន់ពេញ។

៨. ពិនិត្យទៅលើតំបន់រក្សាទុកទាំងអស់ឲ្យបានត្រឹមត្រូវ

៩. ធានាឲ្យបានថាសម្ភារៈអគ្គិសនីទាំងអស់ និងកុងតាក់មានបំពាក់ឧបករណ៍អង្កេតការផ្ទុះឆេះ ដែលជាកន្លែងដែលសម្ភារៈងាយឆេះត្រូវបានរក្សាទុកនៅទីនោះ។

# ឧបសម្ព័ន្ធ ៤÷ កូដបរិស្ថានសម្រាប់ការអនុវត្ត (ECOP)

## ១. កូដបរិស្ថានសម្រាប់ការអនុវត្ត (ECOP) សម្រាប់សកម្មភាពសាងសង់ភាគច្រើន

| បញ្ហាសុវត្ថិភាព | វិធានការកាត់បន្ថយផលប៉ះពាល់ដែលត្រូវអនុវត្ត |
|---|---|
| ការបាត់បង់ដី ឬការប្រើប្រាស់ដី ការទិញយក ឬការយកចេញនៃទ្រព្យសកម្ម (អាគារ បន្លែ ដើមឈើ)។ | • ពិគ្រោះយោបល់ជាមួយអ្នកជួល និងភាគីពាក់ព័ន្ធផ្សេងទៀត<br>• ពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន និងស្នើសុំការប្រើប្រាស់ដីធ្លីជាថ្មី (ស្របតាមក្របខណ្ឌផែនការនៃការតាំងលំនៅដ្ឋានឡើងវិញ RPF)។<br>• រៀបចំ និងអនុវត្តផែនការសកម្មភាពនៃការតាំងលំនៅដ្ឋានឡើងវិញ (RAP) ស្របតាមក្របខណ្ឌផែនការនៃការតាំងលំនៅដ្ឋានឡើងវិញ (RPF) ។ |
| ការបង្កើតធូលី; ផលប៉ះពាល់ទៅលើគុណភាពខ្យល់ និងភាពរំខាន។ | • បាញ់ទឹកនៅលើផ្ទៃដីកំឡុងពេលស្ងួត<br>• បើចាំបាច់ ដំឡើងផ្ទាំងបាំងធូលីនៅពេលដែលយើងធ្វើការនៅជិតតំបន់លំនៅដ្ឋាន សាលារៀន និងមណ្ឌលសុខភាព។<br>• ធានាថារថយន្តដឹកសម្ភារៈមិនងាយឆេះ ឬត្រូវបានគ្របដោយតង់ ឬវត្ថុធាតុស្រដៀងគ្នា។<br>• គ្របសម្ភារៈទាំងអស់ដើម្បីជៀសវាងការបើងប៉ាត់រប៉ាយ ក្នុងអំឡុងពេលមានខ្យល់។<br>• ចូរកុំដុតកំទេចកំទី ដើម្បីបោសសំអាតទីតាំង (ដើមឈើ រុក្ខជាតិតូចៗ) ឬសម្ភារៈសល់ពីការសាងសង់។<br>• អនុវត្តការត្រួតពិនិត្យតាមការចាំបាច់ដើម្បីធានាថាគុណភាពខ្យល់ស្របស្តង់ដាជាតិ។ |
| សំណឹកដី | • រៀបចំតារាងពេលវេលាសាងសង់ ក្នុងអំឡុងរដូវប្រាំង<br>• សម្រប និងកាត់បន្ថយ ប្រវែង និងចំណោទនៃជម្រាល<br>• ការប្រើប្រាស់ កាកសំណល់រុក្ខជាតិ ស្មៅ ឬដីដើម្បីពង្រាបដី |

| | |
|---|---|
| | • ចាក់ដីស្រទាប់លើ និងដាំរុក្ខជាតិឡើងវិញ (ស្មៅ រុក្ខជាតិ ដើមឈើដែលលូតលាស់លឿន) លើតំបន់សាងសង់ឲ្យបានឆាប់រហ័ស នៅពេលបញ្ចប់ការសាងសង់។<br>• បង្កើតប្រឡាយ និងស្នាមភ្លោះ ក្រោយការសាងសង់ និងគ្របចំណោត /ជម្រាល (ឧទាហរណ៍ ដោយធាងដូង បាវក្រចៅ ។ល។) |
| ផលប៉ះពាល់ដោយសម្លេងរំខានលើសហគមន៍/ សាលារៀន/ មណ្ឌលសុខភាព)។ | • ធានាថារថយន្តដឹកជញ្ជូនសម្ភារៈសម្រាប់ការងារសាងសង់ ត្រូវបានរក្សាយ៉ាងល្អ និងបំពាក់ដោយឧបករណ៍កាត់បន្ថយសម្លេង។<br>• ផ្តល់ព័ត៌មានដល់អ្នកគ្រប់គ្រងតាមកន្លែងមួយចំនួន (សាលា/ មណ្ឌលសុខភាព)ដែលស្ថិតនៅជិតតំបន់សាងសង់អំពីសម្លេងរំខានមួយចំនួនដែលមិនអាចចៀសមិនផុត។<br>• អនុវត្តការងារក្នុងពេលថ្ងៃ និងក្នុងអំឡុងម៉ោងធ្វើការប៉ុននោះ ពោលគឺរវាងម៉ោង ៨ ព្រឹក និង ម៉ោង ៥ ល្ងាច។<br>• ប្រើវិធីសាស្ត្រគ្រប់គ្រងសំលេងរំខាន (រនាំង របាំង) ឬ រក្សាទីតាំងមួយកន្លែងសម្រាប់ខណ្ឌចែក ( ដីទំនេរ ដើមឈើ ) រវាងតំបន់អនុវត្តគម្រោង និងតំបន់លំនៅដ្ឋាន និង<br>• អនុវត្តការត្រួតពិនិត្យតាមការចាំបាច់ដើម្បីធានាថាកម្រិតសំឡេងរំខានស្របតាមស្តង់ដាជាតិ។ |
| ការកាប់ដើមឈើធំដែលផ្តល់ម្លប់ចេញ | • ធ្វើការដោយប្រុងប្រយ័ត្ននៅក្នុងតំបន់នោះ និង<br>• ជៀសវាងការយកដើមឈើចេញ តាមដែលអាចធ្វើទៅបាន។ |
| ក្រួស ខ្សាច់ និងការទាញយកវត្ថុធាតុដើមសម្រាប់ការសាងសង់ | • ប្រើប្រាស់ប្រភពក្រួស ខ្សាច់ដែលបានព្រមព្រៀងរួចរាល់<br>• លុបរណ្តៅ ដើម្បីការដក់ទឹកដែលបណ្តាលឲ្យមានជំងឺ (ឧ. មូសជាដើម)និង<br>• ហាមឃាត់ការទាញយកវត្ថុធាតុដើមសម្រាប់ការសាងសង់ដោយខុសច្បាប់។ |
| កាកសំណល់មិនសមរម្យ | • ប្រើប្រាស់ឡើងវិញនូវកាកសំណល់ សម្រាប់សកម្មភាពសាងសង់ /ជួសជុលផ្លូវតាមដែលអាចធ្វើបាន។ |

| | |
|---|---|
| | • កាកសំណល់ សំរាម ត្រូវរក្សាទុកយ៉ាងហោចណាស់ ១០០ម ពីផ្លូវទឹក<br>• ការពារសំរាម និងកាកសំណល់ដីជីកពីសំណើកដោយគ្រប និងបាំង ប្រសិនបើទុកចោលលើសពីមួយយប់។<br>• ប្រើតំបន់សុវត្ថិភាពសម្រាប់ចាក់បំពេញ និងការផ្ទេរវត្ថុរាវពុល ពីតំបន់លំនៅដ្ឋាន និងធ្វើឡើងលើផ្ទៃកម្រាលដែលរឹងគ្មានប្រហោង។<br>• សំរាមត្រូវរក្សាទុកជាគំនរនៅកន្លែងស្ងួត មានសណ្ដាប់ធ្នាប់ រង់ចាំការប្រមូល។<br>• មិនត្រូវការដុតឬកប់សំរាមនិង<br>• ការបោះចោលសំរាម/កាកសំណល់ ត្រូវធ្វើនៅទីតាំងដែលបានកំណត់ និងបានអនុញ្ញាតប៉ុននោះ។ |
| ការបំពុលប្រភពទឹក ការថយចុះនៃគុណភាពទឹក នៅក្នុងប្រលាយ និងទន្លេ។ | • គំនរសម្ភារៈផ្សេងៗត្រូវរក្សាទុកយ៉ាងហោចណាស់ ១០០ម ពីប្រភពទឹក។<br>• រាល់វត្ថុធាតុដើម កាកសំណល់រឹង សារធាតុពុលឬមានគ្រោះថ្នាក់ទាំងអស់មិនត្រូវបានចាក់ ឬបោះចោលទៅក្នុងទឹកឡើយ។<br>• រាល់យានជំនិះមិនត្រូវបើកបរកាត់ប្រឡាយ ឬបាតទន្លេឡើយហើយមិនត្រូវបានចតនៅជិតផ្លូវទឹក នៅពេលទម្លាក់វត្ថុធាតុដើម។<br>• រាល់ការជ្រុះសម្ភារៈផ្សេងៗត្រូវបានសម្អាតឡើងវិញភ្លាម និង<br>• ចេញឱ្យឆ្ងាយពីទីតាំងឬសកម្មភាព ដែលទាក់ទងនឹងការបង្ហាំងទុកនូវកាកសំណល់នៅក្នុងអាងបណ្ដោះអាសន្នឡើយ។ |
| បញ្ហាចរាចរណ៍ | • ផ្ដល់ព័ត៌មានជូនប្រជាជនក្នុងតំបន់អំពីផែនការសាងសង់<br>• រៀបចំសម្ភារសំណង់ឱ្យមានរបៀបរៀបរយ ដើម្បីជៀសវាងការរំខានចរាចរណ៍។<br>• រចនា និងបង្កើតផ្លូវបណ្ដោះអាសន្នដើម្បីរក្សាចរាចរណ៍ធម្មតាទៅតាមការចាំបាច់។<br>• ប្រើប្រាស់រថយន្តដឹកទំនិញនៅលើផ្លូវក្នុងតំបន់ឱ្យបានត្រឹមត្រូវ និង<br>• គោរពច្បាប់ចរាចរណ៍។ |
| សុខភាព | • បណ្ដុះបណ្ដាល និងផ្ដល់ព័ត៌មានអំពីវិធានការសុវត្ថិភាពដល់កម្មករ |

| | |
|---|---|
| និងសុវត្ថិភាព | • ផ្តល់នូវឧបករណ៍សុវត្ថិភាពសម្រាប់កម្មករកំឡុងពេលសាងសង់<br>• ផ្តល់នូវឧបករណ៍សង្គ្រោះបឋមនៅតំបន់សាងសង់នីមួយៗ និងកំណត់ពីកន្លែង និងរបៀបអនុវត្តការសង្គ្រោះបឋម។<br>• ធ្វើសញ្ញា និងរបងនៅកន្លែងដែលមានគ្រោះថ្នាក់<br>• ហាមឃាត់មនុស្សដែលគ្មានភារកិច្ចមិនឲ្យចូលក្នុងការដ្ឋានសំណង់<br>• ធានាការរៀបចំបច្ចេកទេសស្របទៅតាមវិធានការសុវត្ថិភាព<br>• នៅក្នុងករណីមានការប្រើប្រាស់សម្ភារដែលអាចឆេះ និងផ្ទុះត្រូវអនុវត្តទៅតាមការណែនាំរបស់ក្រុមហ៊ុនផលិត។<br>• ដាក់ស្លាកសញ្ញានៅការដ្ឋានសំណង់<br>• ត្រូវមានពន្លឺនៅការដ្ឋានសំណង់នៅពេលយប់ |
| បញ្ហាអនាម័យ បរិស្ថាន និងស្រះទឹក | • ផ្តល់ជូនកម្មករនូវ (ក) ទឹកស្អាត (ខ) បង្គន់ចល័ត និង (គ) ធុងសំរាម<br>• ជៀសវាងការបង្កើតស្រះទឹកនៅការដ្ឋានសំណង់ដែលជាជំរកមូស<br>• ជៀសវាងការទប់ស្កាត់មិនឲ្យទឹកហូរ ដោយបង្កើតលូបង្ហូរទឹកសមរម្យ និង<br>• អនុវត្តវិធានការបរិស្ថានសមស្របដើម្បីគ្រប់គ្រងសត្វមូស កណ្ដុរ រុយ និងសត្វល្អិតដទៃទៀត។ |
| ការរកឃើញដោយចៃដន្យនៃសម្បត្តិវប្បធម៌ | ប្រសិនបើអ្នកម៉ៅការសាងសង់ រកឃើញទីតាំងបុរាណវត្ថុ ទីតាំងប្រវត្តិសាស្ត្រ ដែលនៅសល់ រួមទាំងកន្លែងកប់ខ្មោច ក្នុងអំឡុងពេលជីក ឬសាងសង់អ្នកម៉ៅការត្រូវ:<br>• បញ្ឈប់សកម្មភាពសាងសង់នៅក្នុងតំបន់ដែលរកឃើញ<br>• កំណត់សម្គាល់ទីតាំង ឬតំបន់ដែលបានរកឃើញ<br>• ការពារសុវត្ថិភាពទីតាំង កុំឲ្យខូចខាត ឬបាត់បង់វត្ថុណាមួយ។ នៅក្នុងករណីមានវត្ថុបូរាណដែលអាចយកចេញបានតម្រូវឲ្យមានការយាមកាមទាំងយប់រហូតដល់អាជ្ញាធរមូលដ្ឋានដែលទទួលខុសត្រូវ ឬមន្ទីរវប្បធម៌ និងព័ត៌មានទទួលយកបន្ត។<br>• ជូនដំណឹងទីប្រឹក្សាត្រួតពិនិត្យការសាងសង់ ដើម្បីឲ្យជូនដំណឹង |

| | |
|---|---|
| | ដល់អាជ្ញាធរមូលដ្ឋាន ឬថ្នាក់ជាតិ ដែលទទួលបន្ទុកនៃសម្បត្តិវប្បធម៌កម្ពុជា (ឱ្យបានក្នុងរយៈពេល ២៤ ម៉ោង ឬតិចជាងនេះ)<br>• អាជ្ញាធរមូលដ្ឋានឬ ថ្នាក់ជាតិពាក់ព័ន្ធនឹងទទួលខុសត្រូវក្នុងការការពារនិង អភិរក្សទីតាំងដែលរកឃើញនេះ មុនពេលចាត់វិធានការសមស្របណាមួយ។ ការងារនេះនឹងតម្រូវឱ្យមាន ការវាយតម្លៃបឋមលើការរកឃើញនេះ។ សារៈសំខាន់នៃការរកឃើញនេះគួរតែកំណត់ ស្របទៅតាមលក្ខណៈវិនិច្ឆ័យនានាដែលពាក់ព័ន្ធទៅនឹងបេតិកភ័ណ្ឌវប្បធម៌ ដែលមានទាំងតម្លៃ ផ្នែកសាភ័ណ្ឌ ផ្នែកប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រ ឬ ការស្រាវជ្រាវសង្គម និងសេដ្ឋកិច្ច។<br>• សេចក្តីសម្រេចលើរបៀបចាត់ចែងការរកឃើញនេះ នឹងត្រូវអនុវត្តដោយអាជ្ញាធរដែលទទួលខុសត្រូវ។ នេះអាចរួមបញ្ចូលទាំងការផ្លាស់ប្តូរទីតាំង (ក្នុងករណីវត្ថុដែលនៅសល់ក្នុងដីមិនអាចទាញចេញមកបាន) ការអភិរក្ស ការថែរក្សា ការស្តារឡើងវិញ និងការជួយសង្គ្រោះ។<br>• បើទីតាំងតំបន់វប្បធម៌ និង/ឬ វត្ថុបុរាណមានតម្លៃខ្ពស់ ដែលអ្នកជំនាញ និងអាជ្ញាធរពាក់ព័ន្ធ ផ្តល់អនុសាសន៍តម្រូវឱ្យមានការអភិរក្សតំបន់នេះ ម្ចាស់គម្រោងត្រូវរៀបចំការផ្លាស់ប្តូរនានា ស្របទៅតាមសំណើដើម្បីអភិរក្សតំបន់នេះ។<br>• សេចក្តីសម្រេចស្តីពីការគ្រប់គ្រងរបស់ការរកឃើញនេះ គួរតែសរសេរជាលាយលក្ខណ៍អក្សរដោយអាជ្ញាធរពាក់ព័ន្ធ។<br>• ការងារសាងសង់អាចបន្តបានលុះត្រាតែមានការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន ពាក់ព័ន្ធនឹងសុវត្ថិភាពនៃសម្បត្តិបេតិកភណ្ឌ។ |

| | |
|---|---|
| យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ | • បើយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះត្រូវបានរកឃើញក្នុងអំឡុងពេលសាងសង់ អ្នកម៉ៅការត្រូវតែបញ្ឈប់ការសាងសង់ ការពារតំបន់នេះ និងត្រូវជូនដំណឹងម្ចាស់វិនិយោគភ្លាម។<br>• ម្ចាស់វិនិយោគត្រូវជូនដំណឹងដល់ការិយាល័យកងរាជអាវុធហត្ថ ដែលនៅជិតបំផុត។<br>• ការិយាល័យពាក់ព័ន្ធនៃកងរាជអាវុធហត្ថ ត្រូវចាត់វិធានការ/បច្ចេកទេសពិសេសដើម្បីស៊ើបអង្កេត គ្រប់គ្រង និងយកគ្រាប់មិនទាន់ផ្ទុះចេញឲ្យបានឆាប់រហ័ស ដើម្បីបន្តដំណើរការសាងសង់។<br>• សំណង់អាចបន្តទៀតបាន នៅពេលមន្ត្រីជំនាញនៃកងរាជអាវុធហត្ថ បានបញ្ជាក់ថាតំបន់នេះមានសុវត្ថិភាព។ |

**២. កូដបរិស្ថានសម្រាប់ការអនុវត្តជាក់លាក់ សម្រាប់ប្រភេទអនុគម្រោងនីមួយៗ (បន្ថែមពីលើ ECOP សម្រាប់ការសាងសង់)**

**ក. ការជួសជុលឡើងវិញនូវផ្លូវ ស្ពានជនបទ**

| ប្រភេទអនុគម្រោង | វិធានការកាត់បន្ថយផលប៉ះពាល់ដែលត្រូវអនុវត្ត |
|---|---|
| ផ្លូវជនបទ | • ដើម្បីជៀសវាងសំណឹកដី ត្រូវជៀសវាងការសាងសង់នៅលើដីដែលមិនរឹងមាំ មានជម្រាលចោទ និងជិតច្រាំងទន្លេ។ វិធានការបន្ថែមទៀតត្រូវអនុវត្តក្នុងករណីគ្មានជម្រើសសម្រាប់ការរៀបចំផ្លូវ (សូមមើលខាងក្រោម)។<br>• បែបបទនៃការគ្រប់គ្រងដីល្បាប់ គួរតែត្រូវបានអនុវត្តនៅកន្លែងដែលចាំបាច់ ដើម្បីពន្យឺតឬប្តូរទិសដៅទឹក និងដើម្បីរក្សាដីល្បាប់សម្រាប់ការដាំដុះ។<br>• បាញ់ទឹកនៅលើផ្លូវដី ចាក់បំពេញ និងបង្ហាប់ដីដើម្បីកាត់បន្ថយសំណឹកដីដោយសារខ្យល់តាមការចាំបាច់។<br>• ដាំស្មៅដែលដុះលឿន និងអាចរកបានតាមមូលដ្ឋាននៅលើជម្រាលដែលងាយនឹងរងសំណឹក។ |

| | |
|---|---|
| | • ផ្តល់ប្រឡាយទប់ទឹកដែលមានប្រសិទ្ធិភាព ជាពិសេសនៅក្នុងតំបន់ដែលមានកម្រិតភ្លៀងធ្លាក់ខ្ពស់ និងជម្រាលងាយនឹងទទួលរងសំណឹក ដើម្បីកាត់បន្ថយសំណឹកលើផ្ទៃដីដែលអាចកើតមាន។<br>• ប្រើច្រាំងដែលមានផ្ទៃរាបស្មើសម្រាប់ជម្រាលដែលចោត<br>• អាចប្រើថ្ម (riprap) បន្ថែមដើម្បីការពារជម្រាល<br>• ប្រើជញ្ជាំង (ដែលមានរន្ធសម្រាប់បង្ហូរទឹក) នៅផ្នែកខាងក្រោមនៃជម្រាលដែលមិនស្មើ។<br>• បង្ការការហូរទឹកពីទឹកពផ្ទៃផ្លូវ ដោយប្រើប្រឡាយបង្ហូរទឹកធំល្មមសម្រាប់បង្ហូរទឹកចេញ។<br>• សកម្មភាពនៃការផ្សារភ្ជាប់កំណាត់ផ្លូវណាមួយដែលនឹងត្រូវបានគ្រប់គ្រងដោយប្រុងប្រយ័ត្ន។ |
| ស្ពានតូច | • ជញ្ជាំងថ្ម (Gabions):<br>○ ចំណោទនៃជញ្ជាំងថ្ម (gabions) គួរតែស្ថិតក្នុងអត្រា ១ បញ្ឈរ ២ផ្ដេក។ ជម្រាលដែលចោទជាងនេះ អាចនឹងត្រូវអនុវត្ត អាស្រ័យលើសណ្ឋានដីតំបន់នោះ។<br>○ លួសរ៉ាត់គួរត្រូវប្រើដើម្បីការពារជញ្ជាំងថ្មកុំឱ្យលៀនចេញ។ លួសរ៉ាត់គួរតែត្រូវបានដាក់នៅត្រង់ កំណាត់នីមួយៗនៃកម្ពស់ជញ្ជាំងថ្មដែលចែក ជាបី។<br>○ ជញ្ជាំងថ្ម គួរតែត្រូវចាក់ឬសក ទៅក្នុងដីឱ្យបាន រឹងមាំនិងជ្រៅ។<br>○ នៅក្នុងករណីគ្មានកម្រាលថ្មទេ ស្រទាប់ខាងលើគួរចាក់បំពេញដោយដីសម្រាប់ឱ្យស្មៅដុះលូតលាស់ និងពង្រាបចំណោទ។<br>○ កម្រាលថ្មអាចត្រូវបានផ្តល់ សម្រាប់ជាវិធានការការពារសំណឹក ក្នុងករណីដែលសំណឹកមានតិចបំផុត។ កម្រាលថ្មគឺមិនមានភាពធន់ទៅនឹងចរន្តទឹកខ្លាំងឡើយ ហើយវាត្រូវបានគេប្រើនៅកំពូលជញ្ជាំង gabion ។ |

| | |
|---|---|
| | • សត្វ និងគុណភាពទឹក÷<br>○ កំហិតរយៈពេល និងពេលវេលានៃសកម្មភាពនេសាទនានាក្នុងរដូវដែលមានទឹកតិច (រដូវប្រាំង) និងជៀសវាងកំឡុងពេលដ៏សំខាន់នៃវដ្តជីវសាស្រ្តនៃរុក្ខជាតិ និងសត្វ (ឧ. រដូវត្រីពង)<br>○ ប្រើបច្ចេកទេស ដើម្បីបង្វែរទិសដៅទឹកហូរ ឬកំណត់ទីតាំងសាងសង់ឆ្ងាយដាច់ដោយឡែក ដើម្បីកាត់បន្ថយលំហូរសារធាតុកំណករក្នុងទឹក។ |
| លូបង្ហូរទឹកកខ្វក់ | • យកចម្រឹង (formwork) ទាំងអស់ចេញពីក្នុងលូទឹក (បន្ទាប់ពីបេតុងរឹងជាប់ហើយ)។ ចម្រឹងដែលមិនយកចេញនឹងត្រូវពុកផុយធ្លាក់ និងស្ទះដល់លំហូរទឹក។<br>• ដាក់ដុំថ្មធំៗនៅតាមមាត់លូដើម្បីបង្ការសំណឹក។<br>• ការពារមាត់លូពីខ្សាច់ និងក្រួសដើម្បីកុំឱ្យស្ទះទឹកហូរ។<br>• ធានាថាទឹកដែលនៅជាប់នឹងផ្លូវ អាចហូរចូលទៅក្នុងស្នាមភ្លោះតាមដងផ្លូវដោយសេរី។ |

## ខ. ការស្តារប្រព័ន្ធធារាសាស្ត្រ/ ប្រឡាយបង្ហូរទឹកខ្នាតតូច

| **បញ្ហាបរិស្ថាន** | **វិធានការណ៍កាត់បន្ថយផលប៉ះពាល់ដែលត្រូវអនុវត្ត** |
|---|---|
| សំណឹកដី | • ជញ្ជាំងឥដ្ឋ (នៅតាមបណ្តោយផ្លូវ) ឬថ្មត្រូវសាងសង់ដើម្បីការពារសំណឹកតាមចំណោតច្រាំង។<br>• អាចប្រើប្ញស្សីសម្រាប់ការពារច្រាំង តាមវាលស្រែដែលមានសណ្ឋានដីទាប។<br>• តម្រង (តម្រងបញ្ឈរដែលមានអង្កត់ផ្ចិតប្រហែល ២០ ស.ម ជា មួយកម្រាស់ប្រហែល ១០ស.ម សម្រាប់ងាយស្រួលក្នុងការថែទាំ) មានសារៈសំខាន់ដើម្បីការពារកុំឱ្យវត្ថុធំៗ និងកំទេចកំទីបង្កឱ្យស្ទះប្រឡាយធារាសាស្រ្តនេះ។ មុំរវាងផ្នែកខាងក្រោមនៃប្រឡាយ និង |

| | |
|---|---|
| | គម្រង់នេះគួរស្ថិតនៅចន្លោះពី ៤៥ ទៅ ៨០ ដឺក្រេ។ |

## គ. គម្រោងផ្គត់ផ្គង់ទឹកស្អាតនៅតាមជនបទ

| ប្រភេទអនុគម្រោង និងបញ្ហាបរិស្ថាន | វិធានការកាត់បន្ថយផលប៉ះពាល់ដែលត្រូវអនុវត្ត |
|---|---|
| លក្ខណៈទូទៅ | • រៀបចំ និងកំណត់ទីតាំងស្តុបទឹកដែលជៀសវាងការបង្កើតជម្រកមូស។<br>• ការធ្វើវិភាគលើគុណភាពទឹករយៈពេលដើម្បីធានាថាស្របតាមស្តង់ដាជាតិ |
| | • ដាក់ថ្មនៅជុំវិញអណ្តូងដើម្បីងាយស្រួលក្នុងការបង្ហូរទឹក និងដាក់ឈើទទឹង និងរ៉ក ដើម្បីងាយស្រួលក្នុងការដងទឹក។ ខ្សែយោង និងធុងដងទឹកត្រូវមានអនាម័យ។<br>• ជណ្តើរដែក (បានដាក់ខាងក្នុងអណ្តូងដែលជ្រៅ) មានសារៈសំខាន់សម្រាប់ការថែរក្សាអណ្តូង ឬក្នុងករណីនៃការសង្គ្រោះបន្ទាន់ណាមួយ។<br>• ប្រើសំណាញ់គម្រប /ដំបូល/ លួសនៅលើដំបូលដើម្បីការពារតំបន់នេះពីស្លឹកឈើ ឬកំទេចកំទីធ្លាក់ចុះ។<br>• កំណត់ទីតាំងអណ្តូងឲ្យស្ថិតនៅខាងលើនៃផ្លូវបង្ហូរទឹកស្អុយឲ្យមានចំងាយអប្បបរមា ១៥ម៉ែត ពីប្រភពទឹកស្អុយ ដើម្បីធានានូវគុណភាពទឹកសម្រាប់ផឹក។ |
| ការប្រមូលទឹកភ្លៀង | • អាងស្តុកទឹកភ្លៀងគួរតែស្ថិតក្នុងស្ថានភាពដដែល ដែលភ្ជាប់ទៅនឹងប្រព័ន្ធទរនៅលើដំបូលផ្ទះ ដោយមានក្បាលរ៉ូប៊ីណេ និងទុយយោទឹក។<br>• បើទុយយោចែកចាយត្រូវបានភ្ជាប់ចូលទៅក្នុងអាងស្តុកទឹក ត្រូវដាក់ទុយយោ ១០ស.ម ខ្ពស់ជាងបាតអាង សម្រាប់ការប្រើប្រាស់កាន់តែប្រសើរលើចំណុះផ្ទុក។<br>• គម្របត្រូវតែស៊ីគ្នានឹងមាត់អាងស្តុកទឹកផ ដើម្បីជៀសវាងកម្តៅខ្លាំង និងកុំឲ្យមានរុក្ខជាតិសារាយដុះ (ពីពន្លឺព្រះអាទិត្យដោយផ្ទាល់) និងដើម្បីបង្ការសត្វល្អិត កំទេចកំទី និងស្លឹកឈើកុំឲ្យចូលអាងទឹក។ |

| | |
|---|---|
| | • ទុយយោខ្យល់ដែលមានសន្ទះបាំង គួរតែដាក់នៅក្នុងគម្របដើម្បីជួយបញ្ចូលខ្យល់ទៅក្នុងធុង/អាងស្តុកទឹក។<br>• ទទឹក (gutter) ចាំបាច់ត្រូវសម្អាតឱ្យបានទៀងទាត់ ព្រោះកាកសំណល់បក្សី និងសំរាមស្លឹកនៅលើដំបូលផ្ទះឬទ អាចបង្កឱ្យមានហានិភ័យដល់សុខភាពប្រសិនសារធាតុទាំងនោះហូរចូលទៅក្នុងធុងអាងស្តុកទឹកនេះ។<br>• អាងស្តុកទឹកចាំបាច់ត្រូវបង្ហូរទឹកចេញ ដើម្បីឱ្យនៅពេលមានភ្លៀងធ្លាក់ខ្លាំងទឹកអាចហូរចេញបាន។ ការបង្ហូរទឹកចេញគួរតែរៀបចំឡើងដើម្បីបង្ការកុំឱ្យមានការហូរត្រឡប់ និងសត្វល្អិត សត្វកកេរចូលក្នុងប្រព័ន្ធបង្ហូរ។ ការរៀបចំបានល្អនឹងអនុញ្ញាតឱ្យអាងស្តុកទឹកដើម្បីសម្អាតសារធាតុកំណរចេញ និងរក្សាបាននូវគុណភាពទឹកល្អ។ |
| ទុយយោបង្ហូរទឹកពីអាង<br>ធម្មជាតិ ឬប្រភពទឹកលើដី។ | • កសាងអាគារដោយមានដំបូលនៅពីលើប្រភពទឹកនេះ ដើម្បីការពារស្លឹកឈើ ឬកំទេចកំទីដទៃទៀតកុំឱ្យចូលទៅក្នុងអាងនេះ។<br>• ប្រើរបងដើម្បីការពារប្រភពទឹក (ជាពិសេសអាងធម្មជាតិ) ពីការចេញចូលជាសាធារណៈ និងហានិភ័យនៃការចម្លងរោគ។<br>• បញ្ចូលតម្រង និងចម្រោះដោយខ្សាច់ដែលចាំបាច់ត្រូវសម្អាតជាទៀងទាត<br>ការដាក់ទុយយោៈ<br>• ការដាក់ទុយយោបញ្ជូន និងចែកចាយទឹក PVC ត្រូវកប់នៅក្រោមដី (ដែលមានជម្រៅអប្បបរមា ៥០ស.ម) ដើម្បីការពារទុយយោកុំឱ្យមានការខូចខាតផ្នែកខាងក្រៅ (ឱ. រថយន្តឆ្លងកាត់ កាំរស្មីUV ជាដើម) ។ ការទទួលរងកាំរស្មី UV នឹងបណ្តាលឱ្យសារធាតុប្លាស្ទិកនៅក្នុងទុយយោ PVC ឡើងកំដៅដែលនឹងបង្កទុយយោបាត់បង់ភាពរឹងមាំ និងងាយបែក។<br>• ទុយយោនឹងត្រូវបានតំរៀបជាបន្ទាត់ត្រង់នៅលើចំណោតចុះ។<br>• នៅពេលដែលលក្ខខណ្ឌមិនអនុញ្ញាតឱ្យកប់ទុយយោទៅក្នុងដី (ឱ. ទុយយោត្រូវប្រើខាងលើដី) ត្រូវប្រើទុយយោដែកជំនួសវិញ ដោយប្រើបច្ចេកទេសគាំទ្របន្ថែម ព្រោះការប្រើប្រាស់លើសលប់អាចនាំឱ្យមានការលេចធ្លាយ និងខូចខាត។ |

| | |
|---|---|
| | • ទុយយោភ្ជាប់ និងទុយយោសម្រាប់បង្ហូរទឹកចេញពីអាងស្តិកទឹក មិនគួរប្រើទុយយោប្រភេទ PVC ឡើយ ដោយសារទុយយោប្រភេទនេះងាយនឹងរងផលប៉ះពាល់ពីកាំរស្មី UV/ពន្លឺព្រះអាទិត្យ។ ទុយយោភ្ជាប់ និងទុយយោបង្ហូរទឹក ធ្វើពីលោហធាតុគួរប្រើជំនួសវិញ។ |

## ឃ. ការសាងសង់សំណង់តូចៗ

| បញ្ហាបរិស្ថាន | វិធានការណ៍កាត់បន្ថយផលប៉ះពាល់ដែលត្រូវអនុវត្ត |
|---|---|
| បញ្ហាទូទៅ | • ផ្តល់នូវប្រព័ន្ធបង្ហូរទឹកសមស្របសម្រាប់បូមទឹកចេញពីតំបន់ជុំវិញ ដើម្បីចៀសវាងការដក់ទឹក សត្វល្អិតបង្កជំងឺ (ជំងឺគ្រុនចាញ់ ជាដើម) និងបញ្ហាកង្វះអនាម័យនានា។<br>• បញ្ចូលនូវសម្ភារៈអនាម័យដូចជាបង្គន់ និងអាងសម្រាប់លាងដៃ។<br>• ជៀសវាងការប្រើប្រាស់គ្រឿងស៊ីម៉ង់ត៍អាបស្ដូ (asbestos) សម្រាប់ប្រក់ដំបូល។<br>• ការប្រក់គ្រឿងផ្តល់ភាពងាយស្រួលក្នុងការសំអាត និងមានអនាម័យ |
| ការព្រួយបារម្ភជាក់លាក់ | • សាលារៀនៈ បង្កលក្ខណៈឱ្យទទួលពន្លឺ និងខ្យល់ធម្មជាតិឱ្យបានច្រើន ដើម្បីកាត់បន្ថយតម្រូវការពន្លឺសិប្បនិម្មិត ប្រើបង្អួចធំៗដើម្បីឱ្យបន្ទប់ភ្លឺ និងមានខ្យល់ចេញចូលបានយ៉ាងល្អ ដាំដើមឈើពណ៌បៃតង ផ្តល់នូវធុងទឹក បង្គន់អនាម័យ ទីធ្លាសម្រាប់លេង និងទុយយោទឹក។<br>• មណ្ឌលសុខភាពៈ ផ្តល់ទីតាំងគ្រប់គ្រាន់សម្រាប់កន្លែងព្យាបាល កន្លែងរង់ចាំ និងបន្ទប់អ្នកជំងឺដែលទីតាំងទាំងអស់នេះគួរតែមានខ្យល់ចេញចូលល្អ រួមទាំងកន្លែងសមស្របសំរាប់ការបោលកាកសំណល់វេជ្ជសាស្ត្រ និងជីវសាស្ត្រ(សីរ៉ាំង ឈាម ជាដើម) ។<br>• ទីផ្សារៈ ផ្តល់នូវម៉ាស៊ីនកម្ទេចសំរាមចោល/កាកសំណល់ ធានាថាតូបលក់/ហាងនានា មានគ្រប/ដំបូល ដើម្បីជៀសវាងុំឱ្យដក់ទឹកក្នុងអំឡុងពេលរដូវវស្សា។ |

## ង. ការស្តារ/សាងសង់ឡើងវិញនូវស្ថានីយ៍ពិនិត្យតាមដានជលសាស្ត្រ

| បញ្ហាបរិស្ថាន | វិធានការកាត់បន្ថយផលប៉ះពាល់ដែលត្រូវអនុវត្ត |
|---|---|
| ឧបសគ្គដល់ចរាចរណ៍ផ្លូវទឹក | • ដាក់ស្លាកសញ្ញានៅតាមទីតាំងស្ថានីយ៍ និងធ្វើឱ្យប្រាកដថាស្ថានីយ៍នឹងមិនប៉ះពាល់ដល់ការដឹកជញ្ជូនតាមផ្លូវទឹក។ |
| ទឹកជំនន់ និងសំណឹកច្រាំងទន្លេ | • ពិនិត្យមើលទិន្នន័យស្ថិតិជលឧតុនិយមវិទ្យានៅទីតាំងស្នើសុំសម្រាប់ការសាងសង់ស្ថានីយ៍ និងធ្វើឱ្យប្រាកដថាទីតាំងដែលបានស្នើឡើងនេះ នឹងមិនទទួលរងផលប៉ះពាល់ដោយទឹកជំនន់និងសំណឹក។ |
| កាកសំណល់ | • ធានាថាស្ថានីយ៍នឹងត្រូវផ្តល់ឲ្យនូវធុងសំរាម ហើយកាកសំណល់ចេញពីស្ថានីយ៍នឹងត្រូវបានប្រមូល និងបោះចោលបានត្រឹមត្រូវ។ |

## ឧបសម្ព័ន្ធទី ៥: របាយការណ៍
## និងការរំលេចពីលទ្ធផលនៃការផ្សព្វផ្សាយជាសាធារណៈនៃការពិភាក្សាក្រុមនៅលើគោលនយោបាយសុវត្ថិភាព ក្នុងខេត្តស្ទឹងត្រែង និងខេត្តក្រចេះ (១២-១៨ កក្កដា ២០១០)

### សេចក្តីផ្តើម

ការពិភាក្សាជាក្រុមលើការផ្សព្វផ្សាយនិងការបង្ហាញជាសាធារណៈទៅលើការវាយតម្លៃគម្រោងនៃគម្រោងគ្រប់គ្រងធនធានទឹកចម្រុះតំបន់ទន្លេមេគង្គ (M-IWRMP) បានត្រូវបានធ្វើឡើងជាមួយនឹងសហគមន៍នេសាទគោលដៅក្នុងខេត្តស្ទឹងត្រែង និងក្រចេះ។ គោលបំណង សំខាន់នៃសិក្ខាសាលាសហគមន៍នេសាទ (CFis) ទាំងនោះគឺជាលទ្ធផលនៃក្របខណ្ឌអភិវឌ្ឍន៍ជនជាតិដើមភាគតិច និងក្របខណ្ឌគោលនយោបាយនៃការសាងសង់ទីលំនៅដ្ឋានឡើងវិញ ដែលត្រូវបានរៀបចំដោយគម្រោង M-IWRMP ចំពោះសមាជិកសហគមន៍, គណៈកម្មការសហគមន៍ និងជាពិសេសអាជ្ញាធរមូលដ្ឋានដូចជាប៉ូលីស មេឃុំ និងក្រុមប្រឹក្សាឃុំសង្កាត់។ ។ ការពិភាក្សាជាក្រុមលើការ និងការផ្សព្វផ្សាយ សាធារណៈបានអនុវត្តឡើងដោយមានភាពបទបែនទាំងនៅការិយាលថ្នាក់ឃុំ ផ្ទះសមាជិកសហគមន៍ ឬវត្តអារ៉ាម ដែលអាចផ្តល់នូវទីតាំងបានល្អប្រសើរសំរាប់ការផ្សព្វផ្សាយនេះ។

### ១. សេចក្តីលម្អិតដំណើរការ - ការធ្វើបទបង្ហាញត្រឹមត្រូវ

➢ **ការចុះឈ្មោះអ្នកចូលរួម**

**សិក្ខាសាលាពិគ្រោះយោបល់និងការផ្សព្វផ្សាយសាធារណៈត្រូវបានគេកំណត់គោលដៅទៅលើអ្នកពាក់ព័ន្ធ និងភ្នាក់ងារសំខាន់ៗមួយចំនួនដែលត្រូវបានចូលរួមយ៉ាងខ្លាំងជាមួយនឹងការអភិវឌ្ឍសហគមន៍នេសាទ និងជាពិសេសអ្នកដែលបានជាប់ពាក់ព័ន្ធជាមួយនឹងជនជាតិដើមភាគតិចនៅក្នុងខេត្តទាំងពីរនោះ។ ដោយសារតែការរៀបចំដឹកជញ្ជូនមួយចំនួន កិច្ចប្រជុំផ្សព្វផ្សាយនិងការផ្សព្វផ្សាយសាធារណៈទទួលបានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិមួយចំនួន ប៉ុន្តែកិច្ចប្រជុំមួយចំនួនគ្រាន់តែធ្វើឡើងដោយផ្ទាល់ ជាមួយគណៈកម្មាធិការ សហគមន៍នេសាទ សមាជិកសហគមន៍នេសាទ និងអាជ្ញាធរមូលដ្ឋាន។ បញ្ជីនៃអ្នកចូលរួមអាចរកបាន ឧបសម្ព័ន្ធ ក។**

➢ មតិស្វាគមន៍

ប្រសាសន៍ស្វាគមន៍ ដោយលោក ផេង ផែន អ្នកសម្របសម្រួលគម្រោងកម្មវិធី M-IWRMP ឬលោក ហេង គង់ បានបង្ហាញពីគោលបំណងនៃគម្រោងនេះក្នុងអំឡុងពេលនៃការវាយតម្លៃ

គម្រោង។ លោកក៏បានលើកឡើងអំពីគោលដៅរួម និងគោលបំណងរបស់គម្រោងដែរថា: ១) គម្រោងនេះនឹងផ្តោតទៅលើការងារមួយចំនួនទាក់ទងនឹងការពង្រឹងសមត្ថភាពសហគមន៍នេសាទ តាមរយៈការផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់សហគមន៍នេសាទដែលមានស្រាប់នៅពីខេត្តចំនួនពីរគឺខេត្តស្ទឹងត្រែងនិងខេត្តក្រចេះ។ ទាក់ទងទៅនឹងការពង្រឹងសកម្មភាពសហគមន៍នេសាទ (CFis) លោកបានបន្ថែមទៀតថាគម្រោងនេះនឹងមើល ហើយកាត់បន្ថយដំណើរការនៃការរៀបចំឯកសារផ្លូវច្បាប់សម្រាប់ការចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ។ ក្រៅពីការពង្រឹងសមត្ថភាពសហគមន៍នេសាទ ក៏នៅមានកិច្ចការមួយចំនួនពាក់ព័ន្ធនឹងជម្រើសនៃការចិញ្ចឹមជីវភាពរស់នៅ ត្រូវបានលើកឡើងក្នុងផែនការដើម្បីផ្តល់ឲ្យដល់ ១០ សហគមន៍នេសាទ។ គម្រោងនេះក៏ត្រូវបានមានគម្រោងផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចទៅនេសាទសហគមន៍ដែលបានជ្រើសទាំងអស់នោះផងដែរ។

- គោលបំណងនៃការធ្វើសិក្ខាសាលាផ្សព្វផ្សាយ និងបង្ហាញជាសាធារណៈ និងការធ្វើបទបង្ហាញ

**ក. ទិដ្ឋភាពរួមនៃកម្មវិធី M-IWRMP និងគោលបំណង**

**លោក ហេង គង់**

ទីប្រឹក្សាជាតិ (សុវត្ថិភាពសង្គម និងបរិស្ថាន)

ក្នុងអំឡុងពេលនៃការផ្សព្វផ្សាយ និងការផ្តល់ព័ត៌មានដែលបានជួបប្រជុំជាមួយសហគមន៍នេសាទ(CFis) នៅក្នុងខេត្តស្ទឹងត្រែងនិងខេត្តក្រចេះ លោកហេង គង់ បានធ្វើបទបង្ហាញសង្ខេបព័ត៌មានស្តីពីកម្មវិធី M-IWRMP។ នៅក្នុងបទបង្ហាញនេះបានគ្របដណ្តប់ចំណុចសំខាន់ៗដូចខាងក្រោម

- គោលបំណងរបស់គម្រោង
- គោលបំណងនៃកិច្ចប្រជុំផ្សព្វផ្សាយ និងបង្ហាញជាសាធារណៈ

លោក ហេង គង់ បានលើកឡើងថា គោលបំណងសំខាន់ នៃគម្រោងនេះគឺព្យាយាមជួយដល់សហគមន៍នេសាទដែលមានស្រាប់នៅក្នុងខេត្តទាំងពីរនេះ ដោយផ្តោតលើការពង្រឹងសហគមន៍នេសាទតាមរយៈការផ្តល់ការជួយគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុក្នុងការរៀបចំឯកសារផ្លូវច្បាប់សម្រាប់ការចុះបញ្ជីនៅក្រសួងកសិកម្ម។ ក្រៅពីសកម្មភាពទាំងនេះគម្រោងក៏នឹងរកនូវអ្វី ដែលជាតម្រូវការរបស់សហគមន៍ និងស្វែងរកជម្រើសចិញ្ចឹមជីវភាព ក្នុងលក្ខខណ្ឌនៃការធ្វើឱ្យប្រសើរឡើងការរស់នៅរបស់ពួកគេនៅក្នុងសហគមន៍។

លោកបានបន្ថែមទៅកាន់អង្គប្រជុំលោកបានលើកឡើងថាគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទ

ទន្លេមេគង្គ (M-IWRMP) ក៏ពិនិត្យមើលទៅលើមធ្យោបាយនានា ដែលអាចផ្តល់សហគមន៍នេសាទ (CFi) នូវហេដ្ឋារចនាសម្ព័ន្ធជនបទ ដូចជាផ្លូវតូចក្នុងភូមិ បង្គន់អនាម័យ និងទឹកស្អាត។

**ខ. ការធ្វើបទបង្ហាញស្តីពីលទ្ធផលនៃក្របខណ្ឌសុវត្ថិភាពបរិស្ថាន និងសង្គម (ESSF)**

**លោក ហេង គង់**

ទីប្រឹក្សាជាតិ ( សុវត្ថិភាពសង្គម និងបរិស្ថាន)

ដើម្បីសម្រេចបាននូវគោលដៅទាំងនោះ ជាពិសេសក្នុងអំឡុងពេលនៃការវាយតំលៃគម្រោង M-IRWP ត្រូវបានទាមទារដោយធនាគារពិភពលោកឲ្យអនុវត្ត និងរៀបចំគោលការណ៍ណែនាំ ឬនីតិវិធីដើម្បីធានាថាការអនុវត្តគម្រោងនេះនឹងមិនមានផលប៉ះពាល់អវិជ្ជមានទៅលើជាតិដើមភាគតិចនៅក្នុងសហគមន៍នេសាទដែលបានជ្រើសឡើយ។ ដូច្នេះក្នុងអំឡុងពេលដំណាក់កាលចរចារនេះ ក្របខណ្ឌអភិវឌ្ឍន៍ជនជាតិដើមភាគតិច (IPDF) ត្រូវបានបង្កើតឡើងដោយអ្នកទីប្រឹក្សាអន្តរជាតិ។ ក្រៅពីនេះ ក្របខណ្ឌគោលនយោបាយនៃការតាំងលំនៅដ្ឋានឡើងវិញ (RPF) ក៏បានបង្កើតឡើងដើម្បីធានាថាអនុគម្រោងទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធជនបទអាចត្រូវបានកាត់បន្ថយ និងបន្ថយជាអប្បបរមានូវផលប៉ះពាល់ទៅលើទំនៀមទំលាប់ របៀបរស់នៅ និងវប្បធម៌របស់ជនជាតិដើមភាគតិចទាំងនោះ។ ក្នុងអំឡុងពេលផ្សព្វផ្សាយ និងបង្ហាញជាសាធារណៈនូវលទ្ធផលរបស់ក្របខណ្ឌអភិវឌ្ឍន៍ជនជាតិដើមភាគតិច (IPDF) និងក្របខណ្ឌគោលនយោបាយនៃការតាំងលំនៅដ្ឋានឡើងវិញ (RPF) ឯកសារដែលបានបកប្រែជាភាសាខ្មែរត្រូវបានចែក ជូនដល់អ្នកចូលរួម។

**គ. បទបង្ហាញស្តីពីក្របខណ្ឌអភិវឌ្ឍន៍ជនជាតិដើមភាគតិច (IPDF)**

**លោក ហេង គង់**

ទីប្រឹក្សាជាតិ ( សុវត្ថិភាពសង្គម និងបរិស្ថានី)

បទបង្ហាញនេះត្រូវបានធ្វើឡើងដោយ លោក ហេង គង់ ដែលជាទីប្រឹក្សាថ្នាក់ជាតិអំពីសុវត្ថិភាពបរិស្ថាន និងសង្គម។ ព័ត៌មានទាក់ទងនឹងក្របខណ្ឌអភិវឌ្ឍន៍ជនជាតិដើមភាគតិច ត្រូវបានគេបានពិព័រណ៌នាក្នុងអំឡុងពេលធ្វើបទបង្ហាញនេះ។ ក្នុងអំឡុងពេលកិច្ចប្រជុំពិភាក្សាជាមួយភាគីពាក់ព័ន្ធបញ្ហានានាពាក់ព័ន្ធទាក់ទងនឹងរបៀបនៃផលប៉ះពាល់ពីគម្រោង(M-IWRMP) នេះមានទៅលើជនជាតិដើមភាគតិចមត្រូវបានលើកមកពិភាក្សាឡើង។ លទ្ធផលនៃការពិភាក្សាដែលត្រូវបានបង្ហាញថានៅក្នុងផ្នែកទី ២ ។

**ឃ. បទបង្ហាញស្តីពីលទ្ធផលនៃក្របខណ្ឌគោលនយោបាយនៃការតាំងលំនៅដ្ឋានឡើងវិញ**

**លោក ហេង គង់**

ទីប្រឹក្សាជាតិ ( សុវត្ថិភាពសង្គម និងបរិស្ថាន)

បទបង្ហាញនេះត្រូវបានធ្វើឡើងដោយលោក ហេង គង់ ដែលទីប្រឹក្សាថ្នាក់ជាតិសុវត្ថិភាព បរិស្ថាននិងសង្គម។ ព័ត៌មានទាក់ទងនឹងលទ្ធផលនៃក្របខណ្ឌគោលនយោបាយនៃការតាំងលំនៅដ្ឋានឡើងវិញត្រូវបានបានពណ៌នាក្នុងអំឡុងពេលធ្វើបទបង្ហាញនេះ។ ក្នុងអំឡុងពេលកិច្ចប្រជុំពិភាក្សាជាមួយភាគីពាក់ព័ន្ធ បញ្ហានានាពាក់ព័ន្ធទាក់ទងនឹងរបៀបដែលផលប៉ះពាល់នៃគម្រោង (M-IWRMP) នេះមានទៅលើជនជាតិដើមភាគតិច ត្រូវបានលើកមកពិភាក្សាឡើង។ លទ្ធផលនៃការពិភាក្សាដែលត្រូវបានបង្ហាញថានៅក្នុងផ្នែកទី ២ ។

**ង. បទបង្ហាញស្តីពីបញ្ជីពិនិត្យលើ KRLP**

**លោក ហេង គង់**

ទីប្រឹក្សាជាតិ ( សុវត្ថិភាពសង្គម និងបរិស្ថាន)

ក្នុងអំឡុងពេលធ្វើបទបង្ហាញ បញ្ហាទាក់ទងនឹងការជាមួយក្រុមជនជាតិដើមភាគតិចមួយចំនួនដែលបានចូលរួមក្នុងសហគមន៍នេសាទត្រូវបានលើកឡើងផងដែរ។ លើសពីនេះទៀត តួនាទីរបស់ជនជាតិភាគតិចនៅក្នុងភូមិ និងក្នុងសហគមន៍នេសាទ ត្រូវបានយកមកពិចារណាផងដែរ។

## ២. លទ្ធផលទទួលបានពីការពិភាក្សាលើក្របខណ្ឌអភិវឌ្ឍន៍ជនជាតិដើមភាគតិចម ( IPDF) និង ក្របខណ្ឌគោលនយោបាយនៃការតាំងលំនៅដ្ឋានឡើងវិញ( RPF)

### ២.១. ក្នុងខេត្តស្ទឹងត្រែង

នៅក្នុងខេត្តស្ទឹងត្រែង សហគមន៍នេសាទចំនួនបួន ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងសិក្ខាសាលាផ្សព្វផ្សាយនិងការបង្ហាញជាសាធារណៈនេះ។ សហគមន៍នេសាទចំនួន ២ ដូចជាអន្លង់កោះកង និងភូមិអូរស្វាយ ដែលមកពីឃុំចំនួនពីរ ត្រូវបានអញ្ជើញសម្រាប់កិច្ចប្រជុំនេះ។ កិច្ចប្រជុំនេះត្រូវបានរៀបចំនៅឯការិយាល័យសង្កាត់សាមគ្គី ដោយមានការចូលរួមពីមេឃុំអូរស្វាយ និងឃុំសាមគ្គី តំណាងសហគមន៍នេសាទចំនួន២ ប៉ូលីស និងតំណាងអង្គការក្នុងស្រុក។ បញ្ជីនៃអ្នកចូលរួមមាននៅក្នុងឧបសម្ព័ន្ធ **ក**។ សម្រាប់សហគមន៍នេសាទ ចំនួន ២ទៀត គឺកោះសំពាយ និងត្បូងខ្លាត្រូវបានពិភាក្សាដោយផ្ទាល់ជាមួយពួកគេនៅក្នុងភូមិរបស់ពួកគេ។

- ***សហគមន៍នេសាទ អន្លង់កោះកង និងភូមិអូរស្វាយ***

*** លទ្ធផលនៃក្របខណ្ឌអភិវឌ្ឍន៍ជនជាតិដើមភាគតិច (IPDF)**

**បញ្ហាមួយចំនួនទាក់ទងទៅនឹង ពិភាក្សាពីក្របខណ្ឌដូចខាងក្រោម:**

- ដោយសារតែការអញ្ជើញសហគមន៍នេសាទពីរ មិនមានប្រជាជនជាតិដើមភាគតិច រស់នៅក្នុងភូមិទាំងនេះ ដូច្នេះការពិភាក្សាស្តីពីផលប៉ះពាល់របស់គម្រោងកម្មវិធី M-IWRMP នេះហាក់ដូចជាមិនត្រូវបានផ្តោតការយកចិត្តទុកដាក់ និងភាគច្រើននៃពួកគេគិតថាមានផលប៉ះពាល់ទេនៅពេលអនុវត្តគម្រោងនេះ។
- លោក **មេន លីហួ** មេឃុំអូរស្វាយ បានស្នើថានៅក្នុងឃុំរបស់គាត់មានភូមិដែលមានក្រុមជនជាតិភាគតិចជនជាតិឡាវ ប៉ុន្តែមិនមានក្រុមជនជាតិដើមភាគតិចនៅក្នុងសហគមន៍នេសាទដែលបានជ្រើសរើសនោះទេ។ ដូច្នេះដើម្បីធ្វើឱ្យប្រាកដទៅលើផលប៉ះពាល់ដែលនឹងអាចកើតមានគម្រោងនេះគួរតែធ្វើការស្ទង់មតិទៅក្នុងភូមិទាំងអស់ ដូច្នេះយើងអាចធានាបានថាបញ្ហាទាក់ទងនឹងក្រុមងាយរងគ្រោះទាំងនេះត្រូវបានគិតគូ ជាពិសេសក្នុងអំឡុងដំណាក់កាលនៃការរៀបចំគម្រោងនេះ។

*** លទ្ធផលនៃក្របខណ្ឌគោលនយោបាយនៃការតាំងលំនៅដ្ឋានឡើងវិញ**

- លោកស្រី **វ៉ន ប៊ុនលី** ដែលជាមេសង្កាត់សាមគ្គី បាននិយាយថាសម្រាប់ហេដ្ឋារចនាសម្ព័ន្ធជនបទខ្នាតតូចនៅសហគមន៍នេសាទគោលដៅអាចមានផលប៉ះពាល់តិចតួចទៅអ្នកភូមិ។ នាងបានរៀបរាប់ថា ប្រសិនបើមានផលប៉ះពាល់ទៅលើសម្បត្តិឯកជន យើងត្រូវធ្វើការពិភាក្សាជាមួយភ្នាក់ងារពាក់ព័ន្ធ ជាពិសេសជាមួយនឹងម្ចាស់ដី មេភូមិ និងអាជ្ញាធរមូលដ្ឋានឃុំ (មេឃុំ ប៉ូលីស និងក្រុមប្រឹក្សាឃុំសង្កាត់)។ នាងបានបន្ថែមទៀតថា វានឹងជាការល្អប្រសិនបើយើងអាចចរចារ និងផ្តល់សំណងណាមួយទៅគ្រួសារដែលរងផលប៉ះពាល់ប្រសិនបើចាំបាច់។ នាងបាននិយាយថា វានឹងជាការល្អប្រសិនបើគម្រោងនេះអាចជួយអ្នកភូមិតាមរយៈការផ្តល់នូវទឹកស្អាតបង្គន់អនាម័យ និងផ្លូវតាមជនបទតូចមួយ។
- លោក **មេន លីហួ** មេឃុំអូរស្វាយ បានលើកឡើងថាលោកស្វាគមន៍យ៉ាងកក់ក្តៅចំពោះគម្រោងកម្មវិធី M-IWRMP ដែលនឹងជួយនៅក្នុងឃុំរបស់គាត់។ នៅក្នុងនាមនៃអាជ្ញាធរមូលដ្ឋាន លោកមានឆន្ទៈក្នុងការជួយដល់គម្រោងនេះ ប្រសិនបើមានបញ្ហាមួយចំនួនកើតមានឡើងនៅក្នុងឃុំ។

➢ លោក **អិន ចន្ទរិទ្ធិ** តំណាងនៃអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ឈ្មោះ CEPA និងជាបុគ្គលដែលមានបទពិសោធន៍មួយនៅក្នុងឃុំទាំងពីរនោះ ក៏បានបញ្ជាក់ដែរថា ដោយផ្អែកលើបទពិសោធន៍របស់គាត់ គាត់គិតថាអ្នកភូមិត្រូវការយ៉ាងខ្លាំងនូវការគាំទ្រទាំងជំនួយការបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីធ្វើឱ្យប្រសើរឡើងការរស់នៅរបស់ពួកគេ។ លោកគិតថាវាមិនមានផលប៉ះពាល់នោះទេ។ ប្រសិនបើមានផលប៉ះពាល់ យើងគួរតែពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីដោះស្រាយបញ្ហានេះតាមរយៈការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ហើយបន្ទាប់មកយើងអាចកាត់បន្ថយផលប៉ះពាល់ទាំងអស់នោះបាន។

- **សហគមន៍នេសាទ ត្បូងខ្លា**

* **លទ្ធផលនៃការពិភាក្សលើក្របខណ្ឌអភិវឌ្ឍន៍ជនជាតិដើមភាគតិច**

